និពន្ធនាយក EDITORIAL

# ស្មារតី២ធ្នូ និងទស្សនៈរបស់យុវវ័យចំពោះប្រវត្តិសាស្ត្រ

# 2-December Spirit and View of Youth on History

ថ្ងៃទី ២ ធ្នូ ឆ្នាំ ២០១៣ នេះ ជាថ្ងៃគម្រប់ខួបលើកទី ៣៥ នៃការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា (២ ធ្នូ ១៩៧៨ - ២ ធ្នូ ២០១៣) ដែលបច្ចុប្បន្នបានប្ដូរឈ្មោះជារណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា គឺជាអង្គការចាត់តាំងខាងនយោបាយតែមួយគត់របស់ប្រជាជនកម្ពុជានៅក្នុងដំណាក់កាលនោះ ដែលបានប្រមូលកម្លាំងអ្នកស្នេហាជាតិពីគ្រប់ទិសទីឱ្យក្រោកឈរឡើងរួបរួមគ្នាដើម្បីដឹកនាំការតស៊ូប្រយុទ្ធប្រឆាំងនឹងរបបប្រល័យពូជសាសន៍ប៉ុលពត រហូតទទួលបានជ័យជម្នះជាប្រវត្តិសាស្ត្រនា ថ្ងៃ ៧ ខែមករា ឆ្នាំ ១៩៧៩ ។ ជ័យជំនះ ៧ មករា បានបញ្ចប់នូវដំណាក់កាលដ៏ខ្មៅងងឹតបំផុតដែលពុំធ្លាប់មានហើយបើកឡើងនូវទំព័រសករាជថ្មីនៃប្រវត្តិសាស្ត្រកម្ពុជា ។

ឆ្លងកាត់រយៈពេល ៣៥ ឆ្នាំមកនេះ ប្រទេសកម្ពុជាបានប្រែក្លាយពីវាលពិឃាតនៅក្រោមរបបប្រល័យពូជសាសន៍ និងពីសមរភូមិនៃសង្គ្រាមដ៏រ៉ាំរ៉ៃ ដែលបានធ្វើឱ្យប្រជាជនរាប់លាននាក់ត្រូវបាត់បង់ជីវិត រចនាសម្ព័ន្ធជាតិទាំងមូលត្រូវបំផ្លាញខ្ទេចខ្ទី ក្លាយមកជាទឹកដីមួយដែលមានសុខសន្តិភាព និងមានការអភិវឌ្ឍលើគ្រប់វិស័យ ។ ព្រមជាមួយនេះ ក៏ជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជារយៈពេលជិត ៥០០ ឆ្នាំ បន្ទាប់ពីសម័យអង្គរដ៏រុងរឿងមក ដែលកម្ពុជាបានសម្រេចនូវការឯកភាពជាតិ ឯកភាពទឹកដី មានសន្តិភាពពេញលេញ មានស្ថិរភាពរឹងមាំ ប្រជាជនបាននិងកំពុងរស់នៅយ៉ាងសុខដុមរមនា ក្រោមដំបូលនៃរដ្ឋធម្មនុញ្ញតែមួយ និងមានរាជរដ្ឋាភិបាល តែមួយ ។ គណបក្សប្រជាជនកម្ពុជា ដែលមានសម្ដេចទាំងបីជាប្រមុខ គឺជាកម្លាំងស្នូលដឹកនាំសង្គមជាតិឱ្យសម្រេចបាននូវសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រទាំងអស់នេះ ដែលបង្កើតបាននូវមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍយូរអង្វែងប្រកបដោយចីរភាព ក្នុងទិសដៅឆ្ពោះទៅរកអនាគតដ៏រុងរឿង ។ នេះជាសច្ចធម៌នៃប្រវត្តិសាស្ត្រ ដែលគ្មាននរណាអាចមកបដិសេធបានឡើយ ។

ប៉ុន្តែក្រុមប្រឆាំង និងមជ្ឈដ្ឋានអគតិមួយចំនួន ទាំងនៅខាងក្នុង និងក្រៅប្រទេស បានខិតខំរកគ្រប់វិធីដើម្បីបំភ្លៃប្រវត្តិសាស្ត្រនេះឥតឈប់ឈរ ជាពិសេសនិយាយកុហកបោកប្រាសស្រទាប់យុវជនឱ្យយល់ច្រឡំពីការពិត សំដៅបដិសេធនូវអត្ថន័យដ៏វិសេសវិសាលនៃជ័យជម្នះ ៧ មករា ដែលបានសង្គ្រោះជាតិឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ។ ពួកគេបានបំផុសញុះញង់ជាប្រចាំនូវគំនិតជាតិនិយមជ្រុល ដើម្បីធ្វើឱ្យមានការយល់ខុសអំពីបុព្វហេតុដ៏ឧត្ដុង្គឧត្ដមនៃការតស៊ូសង្គ្រោះជាតិ និងអំពីតួនាទីដ៏ថ្លៃថ្លារបស់កងទ័ពស្ម័គ្រចិត្តវៀតណាមដែលបានចូលមកជួយរំដោះប្រជាជនកម្ពុជាពីរបបប្រល័យពូជសាសន៍ តាមការអំពាវនាវរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ ទន្ទឹមនេះ គេលើកនិយាយតែអំពីតួនាទីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ ដោយចាត់ទុកថា នោះ

2 December 2013 is the 35th founding anniversary of the National United Front for the Salvation of Kampuchea – NUFSK (2 December 1978 to 2 December 2013), which has now changed to National United Front for the Development of the Cambodian Motherland (NUFDCM). NUFSK had been the only political organization of the Cambodian people at the time when the country mobilized compatriots from all corners to stand up in unity to lead the struggle against the regime of the genocide of Pol Pot until its historic victory on 7 January 1979 ending the darkest stage unprecedented in the history of Cambodia.

Over the past 35 years, Cambodia has transformed from a killing field under the regime of genocide and protracted war resulting in deaths of millions of people, destruction of national infrastructure, to be a land of peace and development in all fields. Along with this, for the first time in the history of Cambodia in the past nearly 500 years, after the prosperous time of Angkor, Cambodia has achieved national unity, fully unified territory and firm stability, whereby people are living in harmony under one Constitution and Royal Government. The Cambodian People's Party, under the leadership of the three leaders is the core force leading the nation to realize various historic achievements that are becoming the foundation for sustainable and long-term development towards prosperity. This historic reality is undeniable.

On the contrary, the opposition and ill-will circle, inside and outside the country, have sought endlessly every means to falsify historical facts and especially deceived the younger age population of the truth aimed at denying the great meaning of the victory day of 7 January that saved the country from the regime of genocide. They have regularly agitated and provoked extreme nationalism resulting in misunderstanding on the supreme cause of the national struggle and the invaluable role of the Vietnamese voluntary army who respond to the call of the NUFSK for them to come rescue the people of Cambodia from the regime of genocide.

At the same time, they only talked about and considered the Paris Peace Agreement on 23 October 1991 as the day that Cambodia achieved peace, freedom and democracy, while in fact the Agreement is one of the historic events in the process of advancement of Cambodia. As the cause of fact, elements of the Agreement have dissolved and incorporated into the Constitution of the Kingdom of Cambodia already. Although it ensures the correct path for Cambodian advancement in accordance with the people's aspiration, the Paris Peace Agreement would not carry weighty meaning as that of the 7-January victory. It would be so for the very simple reason that should there be no 7-January victory, the Cambodian motherland and people could have been vanished at the hands of the genocidal regime already.

In the current state of being, living in the time of advanced information technology, the Cambodian younger population should have a better understanding of the country's history to be able to take up successive role with high responsibility for destiny of the country. That the youth would become strong pillars of the country, they should have knowledge, knowhow, strong physical, unfaltered patriotism, correct understanding of the country's history and know how to ensure inclusive strand in all circumstance.

គឺជាថ្ងៃដែលប្រទេសកម្ពុជាទទួលបានសុខសន្តិភាព សិទ្ធិសេរីភាព និងប្រជាធិបតេយ្យ ។ ជាការពិត កិច្ចព្រមព្រៀងក្រុងប៉ារីស គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយនៅក្នុងដំណើរឈានឡើងរបស់កម្ពុជា ហើយស្មារតីនៃកិច្ចព្រមព្រៀងនេះបានរលាយធាតុទាំងស្រុងចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នរួចហើយ ។កិច្ចព្រមព្រៀងក្រុងប៉ារីសបានធ្វើឱ្យដំណើរឈានឡើងរបស់កម្ពុជាកាន់តែមានទិសដៅត្រឹមត្រូវស្រប ទៅនឹងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាគ្រប់ៗរូប ប៉ុន្តែពុំអាចប្រៀបផ្ទឹមបាននឹងអត្ថន័យដ៏ធំធេងវិសេសវិសាលនៃជ័យជម្នះ ៧ មករាបានឡើយ ។ ព្រោះថា បើគ្មានជ័យជម្នះ ៧ មករា មាតុភូមិ និងប្រជាជាតិកម្ពុជាពិតត្រូវរបបប្រល័យពូជសាសន៍បំផ្លាញឱ្យរលាយសូន្យបាត់ទៅហើយ ។

យុវជនកម្ពុជាបច្ចុប្បន្ន ដែលកំពុងស្ថិតនៅក្នុងសម័យកាលដ៏ជឿនលឿននៃបច្ចេកវិទ្យាព័ត៌មាន គប្បីមានការត្រិះរិះពិចារណាឱ្យបានត្រឹមត្រូវចំពោះប្រវត្តិសាស្ត្រ ដើម្បីរ៉ាប់រងនូវតួនាទីជាអ្នកបន្តវេនប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុតចំពោះជោគវាសនារបស់ប្រទេសជាតិ ។យុវជនយើងនឹងក្លាយជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិទៅបាន ដរាបណាយុវជនយើងមានទាំងចំណេះដឹង ទាំងចំណេះធ្វើ មានកាយសម្បទាមាំទាំ មានទឹកចិត្តស្នេហាជាតិមោះមុត មានការចងចាំដ៏ត្រឹមត្រូវចំពោះប្រវត្តិ-សាស្ត្ររបស់ជាតិ ហើយចេះរួមសាមគ្គី ចងសម្ប្រាច់នឹងគ្នាជាធ្លុងមួយនៅគ្រប់កាលៈទេសៈ ។ ដូច្នេះយុវជនគប្បីខិតខំស្វែងយល់ឱ្យបានច្បាស់លាស់ស៊ីជម្រៅអំពីដំណាក់កាលនីមួយៗនៃការវិវត្តរបស់សង្គមជាតិយើង ដើម្បីចៀសឱ្យផុតពីការធ្លាក់ចូលទៅក្នុងអន្លង់នៃការបោកបញ្ឆោតរបស់ក្រុមអ្នកនយោបាយជ្រុលនិយម និងមជ្ឈដ្ឋានអគតិផ្សេងៗ ។ ក្នុងន័យនេះ ទោះបីជាយុវជនយើងកំពុងស្ថិតនៅក្នុងទីតាំងណា និងពេលវេលាណាក៏ដោយ រាល់ការគិតគូរវិភាគរបស់យុវជនយើងត្រូវប្រកាន់ខ្ជាប់នូវទស្សនៈប្រវត្តិ-សាស្ត្រជាក់ស្តែង និងទស្សនៈគ្រប់ជ្រុងជ្រោយ ព្រោះបើមិនដូច្នោះទេវានឹងធ្វើឱ្យយើងស្ថិតនៅក្នុងជំហរមួយដែលស្រពិចស្រពិល មិនច្បាស់លាស់ ហេីយនឹងនាំទៅដល់ការធ្វើសេចក្តីសម្រេចចិត្តខុស ។

បើគ្មានថ្ងៃម្សិលមិញ គឺពិតជាគ្មានថ្ងៃនេះ ហើយក៏គ្មានថ្ងៃស្អែកដែរ ។ គ្មានអតីតកាល គឺគ្មានបច្ចុប្បន្នកាល គ្មានបច្ចុប្បន្នកាល គឺគ្មានអនាគតកាលឡើយ ។ អាស្រ័យហេតុនេះ យុវជនយើងដែលជាទំពាំងស្នងឫស្សី ជាអ្នកបន្តវេនរៀមច្បងជំនាន់មុនៗត្រូវតែយល់ឱ្យច្បាស់ថា ប្រជាជាតិយើងបានចេញដំណើរមកពីណា ? បានឆ្លងកាត់ដំណាក់កាលធំៗដូចម្តេចខ្លះ ? ឥឡូវកំពុងឈរនៅទីតាំងណាដែលប្រកបដោយកត្តាអនុគ្រោះ និងបញ្ហាប្រឈមដូចម្តេចខ្លះ ? ហើយប្រុងឆ្ពោះទៅរកទិសដៅណា ? គឺមិនអាចសម្លឹងមើលត្រឹមតែបច្ចុប្បន្ន តែប្រយោជន៍ផ្ទាល់ខ្លួនចំពោះមុខ រួចបោះជំហានទៅមុខទៀតដោយមិនមានទិសដៅច្បាស់លាស់នោះឡើយ ។

រយៈពេល ៣៥ ឆ្នាំកន្លងមកនេះ ជំនាន់រៀមច្បងរបស់យើងបានខិតខំតស៊ូយ៉ាងលំបាកវេទនា និងធ្វើពលិកម្មយ៉ាងអង់អាចបំផុតដើម្បីសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ និងការពារការរស់ឡើងរបស់ប្រជាជាតិ ។ ពេលដែលប្រទេសជាតិបានរំដោះចេញផុតពីរបបដ៏យង់ឃ្នងនោះហើយ ប្រទេសជាតិនៅតែត្រូវបន្តឆ្លងកាត់ភ្លើងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ ការបាត់បង់ជំនឿទុកចិត្តរវាងគ្នានិងគ្នា ការបែងចែកពណ៌សម្បុរគ្នា និងការបាត់បង់សាមគ្គីភាព ។ ប៉ុន្តែចុងក្រោយយើងដណ្តើមបានមកវិញនូវសន្តិភាពពេញលេញជូនជាតិ តាមរយៈនយោបាយ ឈ្នះ ឈ្នះ យើងបានរួបរួមគ្នាឡើងវិញសាមគ្គីជាធ្លុងមួយ ក្រោមបាវចនា ជាតិសាសនាព្រះមហាក្សត្រ ខិតខំកសាង និងអភិវឌ្ឍប្រទេសឱ្យមានការរីកចម្រើនដូចសព្វថ្ងៃ ។ ពេលបានយល់ដឹងពីប្រការទាំងអស់នេះ យុវជនកម្ពុជាគ្រប់ៗរូប គប្បីចូលរួមសកម្មជួយថែរក្សានូវសមិទ្ធផលទាំងឡាយដែលរៀមច្បងជំនាន់មុនៗបានកសាងទុក និងរួមចំណែកបង្កើនស្នាដៃកសាងសមិទ្ធផលថ្មីៗបន្តទៀត ។

ស្មារតី ២ ធ្នូ និង ៧ មករាពិតជាស្ថិតស្ថេរអមតៈក្នុងបេះដូងរបស់ប្រជាជនកម្ពុជាគ្រប់ៗរូប ទាំងអ្នកសល់ពីស្លាប់ដោយរបបប្រល័យពូជសាសន៍ ទាំងយុវជនជំនាន់នេះ ក៏ដូចជំនាន់ក្រោយៗទៀត ។ មានរណសិរ្សសាមគ្គីសង្គ្រោះជាតិនាថ្ងៃ ២ ធ្នូ ទើបមានជ័យជម្នះ ៧ មករា មានជ័យជម្នះ ៧ មករា ទើបយើងមានអ្វីៗនៅថ្ងៃនេះ និងមានអ្វីៗតទៅមុខទៀត ។

យើងទាំងអស់គ្នាគួរចងចាំថា "ពេលផឹកទឹកត្រូវគិតដល់ប្រភពពេលបានផ្លែឈើហូបត្រូវគិតដល់អ្នកដាំ" ។/

ទស្សនាវដ្តីប្រជាជន

The younger age of the population should seek to reach deep and clear understanding of each phase of the country's evolution to save themselves from the abyss of deceptions by extremist politicians and ill-willed circles. In this meaning, in whatever place or time they maybe, our youth must base their analysis on concepts of historic reality and comprehension or they would stand on losing ground of illusion and uncertainty, which leads to wrong decision making.

Should there were no yesterday, it is definite that there would not be today or tomorrow. Should there were no past, there would not be present, and similarly, without the present, there would not be future. To take successive role from the elder generation, the youth should clearly understand from where and through how many serious phases our country has taken its journey, where does the country stand, what favoring factors and challenges she has and which direction she will take. We could not afford to see only the present time and make unsure step forward for immediate personal interest.

Over the past 35 years, the elder generations have made difficult efforts and brave sacrifices in the struggle to save the country from the regime of genocide and to defend her rebirth. Saved from the perfidious regime, the country continued to go through protracted war, distrust, discrimination and loss of unity. Towards lately, through implementation of the win-win policy we have regained full peace, reunited as one strand under the motto of nation, religion and King, while making efforts to attain present construction and development achievements of the country. Digesting on these thoughts, every Cambodian youth should actively help maintain achievements scored by former generations, while contributing to more achievements.

The spirit of 2 December and 7 January will continue to exist forever in every Cambodian heart, both those who survived the regime of genocide and those belong to the younger generations. That we had NUFSK on 2 December, we scored the 7 January victory. That we scored the 7 January victory we have everything today and many more to come. We should remember to "always think of where your drink and/or fruit come from."

*THE PRACHEACHUN MAGAZINE*

# កម្ពុជាប្រារព្ធទិវាបុណ្យឯករាជ្យជាតិ ខួបលើកទី ៦០



*ព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងជាព្រះរាជាធិបតី-ភាពដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី ៦០ ថ្ងៃបុណ្យឯករាជ្យជាតិ និងថ្ងៃបង្កើតកងយោធពលខេមរភូមិន្ទ*

នៅព្រឹកថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០១៣ នៅមុខព្រះបរម រាជវាំង មានប្រារព្ធពិធីមិទ្ទីងមហាជនអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៦០ ថ្ងៃបុណ្យឯករាជ្យជាតិ និងថ្ងៃបង្កើតកងយោធពលខេមរភូមិន្ទ (ថ្ងៃ៩វិច្ឆិកាឆ្នាំ១៩៥៣-ថ្ងៃ៩វិច្ឆិកាឆ្នាំ២០១៣) យ៉ាងមហោឡារិក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានិងលោកជំទាវ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ១ ព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំនៅក្នុងស្ថាប័នព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល នាម៉ឺនសព្វមុខមន្ត្រី អង្គទូត កងកម្លាំងប្រដាប់អាវុធ ព្រមទាំងមហាជនយ៉ាងច្រើនកុះករ បានអញ្ជើញចូលរួមនៅក្នុងពិធីនេះ ។

ពិធីមិទ្ទីញមហាជននេះបានប្រារព្ធឡើង បន្ទាប់ពី **ព្រះមហាក្សត្រ** ព្រះអង្គទ្រង់បានយាងប្រទានភ្លើងជ័យនៅវិមានឯករាជ្យជាការបញ្ជាក់នៃថ្ងៃដំបូងសម្រាប់ទិវាបុណ្យឯករាជ្យដែលមានរយៈពេល ៣ ថ្ងៃនោះ ។

នៅក្នុងឱកាសដ៏វិសេសវិសាលនោះ ក្នុងនាមសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងក្នុងនាមរូបសម្តេចផ្ទាល់ សម្តេចតេ-ជោ **ហ៊ុន សែន** បានថ្លែងសុន្ទរកថាដ៏មានអត្ថន័យជ្រាលជ្រៅសម្តែងនូវមនោសញ្ចេតនារីករាយក្រៃលែង ដោយបានចូលរួមជាមួយប្រជា-ពលរដ្ឋគ្រប់រូបក្នុងទូទាំងប្រទេស និងជាពិសេសប្រជាពលរដ្ឋនៅរាជ-ធានីភ្នំពេញដើម្បីប្រារព្ធមិទ្ទីងឧទ្ទិសដល់ខួប៦០ឆ្នាំនៃថ្ងៃប្រកាសឯក-រាជ្យជាតិ ៩ វិច្ឆិកា ឆ្នាំ ១៩៥៣ បន្ទាប់ពីជោគជ័យនៃព្រះរាជបូជនីយកិច្ចដ៏ឧត្តុង្គឧត្តមរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីទាមទារឯករាជ្យពីអាណានិគមនិយមបារាំង ។

សម្តេចតេជោបានថ្លែងថា សម្តេចក៏ដូចប្រជារាស្ត្រខ្មែរគ្រប់រូបចងចាំជាប់ជានិច្ចក្នុងក្រអៅបេះដូងនូវ **ព្រះមហាករុណាធិគុណ** ប្រកបដោយព្រហ្មវិហារធមិដ៏ជ្រាលជ្រៅបំផុតរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ដែលព្រះអង្គបានបូជាព្រះកាយពល និងព្រះបញ្ញាញាណដ៏ឈ្លាសវៃបំផុត ដើម្បីបុព្វហេតុឯករាជ្យជាតិ បូរ-ណភាពទឹកដី សេចក្តីសុខសាន្ត និងការរីកចម្រើននៃ សង្គមជាតិ ។ ព្រះអង្គបានស្ថាបនាសង្គមរាស្ត្រនិយមដែលជាស្នាព្រះហស្តដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ព្រះអង្គបានត្រួសត្រាយមាគ៌ាសន្តិភាព និងសាមគ្គីភាព ព្រមទាំងការអភិវឌ្ឍសម្រាប់សង្គមជាតិខ្មែរទាំងមូល ដែលយើងទាំងអស់គ្នាជាកូន ជាចៅ ចៅទួត របស់ព្រះអង្គ តែងតែដង្ហែតាមមាគ៌ាដ៏ថ្លៃថ្លានេះជារៀងរហូតមក ។ ព្រះករុណាទិគុណដ៏ជ្រាលជ្រៅ និងធំធេងបំផុតនេះ ត្រូវបានប្រជារាស្ត្រកម្ពុជាចារឹកទុកជាអមតៈនៅក្នុងទំព័រក្រាំងមាសនៃប្រវត្តិសាស្ត្រកម្ពុជា ដោយមិនមានពេលណាមួយរលុបទៅវិញបានឡើយ ។

សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានសម្តែងនូវកតញ្ញូតាធមិដ៏ជ្រាលជ្រៅបំផុតថ្វាយសម្តេច **ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** និងព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលជានិច្ចកាលព្រះអង្គតែងតែគង់ប្រថាប់នៅក្បែរ និងបានដង្ហែថ្វាយការគាំពារ គាំទ្រ និងបន្តព្រះរាជសកម្មភាពដ៏ថ្លៃវិសេស ដែលជាស្នាព្រះហស្តរបស់ **ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។ ជាពិសេសព្រះករុណាថ្លៃវិសេសព្រះអង្គបានប្រោសព្រះរាជទាននូវការគាំទ្រសព្វបែបយ៉ាងដល់រាជរដ្ឋាភិបាល ដើម្បីបុព្វហេតុនៃសុខសន្តិភាព និងស្ថិរភាពរបស់ប្រទេសជាតិ សាមគ្គីភាពទូលំទូលាយ ការរីកចម្រើនរបស់សង្គម ជាតិ ព្រមទាំងការលើកស្ទួយជីវភាព សុខុមាលភាព និងភាពសុខដុមរមនារបស់ប្រជារាស្ត្រ ។

សម្តេចតេជោមានប្រសាសន៍ថា ប្រការនេះបានក្លាយទៅជាមូលដ្ឋានដ៏រឹងមាំសម្រាប់ឱ្យរាជរដ្ឋាភិបាលបន្តខិតខំអភិវឌ្ឍសមិទ្ធផលរបស់ជាតិថែមទៀតក្នុងគ្រប់ផ្នែក គ្រប់វិស័យ ដែលបានធ្វើឱ្យកិត្យានុភាពរបស់ប្រទេសមានការផ្លាស់ប្តូរស៊ីជម្រៅ ។កម្ពុជាដែលពីមុនជាប្រទេស



*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ១ ព្រឹទ្ធសភា ក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី ៦០ ថ្ងៃបុណ្យឯករាជ្យជាតិ និងថ្ងៃបង្កើតកងយោធពលខេមរភូមិន្ទ*

ត្រូវទទួលរងការហ៊ុំព័ទ្ធ និងឯកោ ទាំងខាងនយោបាយ និងសេដ្ឋកិច្ច បច្ចុប្បន្ននេះបានក្លាយជាប្រទេសមួយដែលកំពុងសមាហរណកម្មខ្លួនយ៉ាងសកម្មទៅក្នុងរចនាសម្ព័ន្ធ និងនិម្មាបនកម្មតំបន់ និងពិភពលោក និងជាប្រទេសដែលកំពុងតែដើរតួនាទីយ៉ាងសកម្ម ដោយស្មើសិទ្ធិ និងស្មើភាពក្នុងគ្រប់កិច្ចការតំបន់ និងនៅលើឆាកអន្តរជាតិ ។ កម្ពុជា ដែលពីមុនជាប្រទេសអន់ថយខាងផ្នែកសេដ្ឋកិច្ច និងគ្របដណ្តប់ទៅដោយភាពក្រីក្រ មានអសន្តិសុខស្បៀង ឥឡូវនេះបានក្លាយជាប្រទេសនាំស្បៀងចេញ ហើយស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ១១ ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់លើពិភពលោកក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ និងជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់ទី ៥ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដែលអាចសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្ស-



*ទិដ្ឋភាពរួមក្នុងឱកាសប្រារព្ធពិធីមិទ្ទីងមហាជនអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៦០ ថ្ងៃបុណ្យឯករាជ្យជាតិ និងថ្ងៃបង្កើតកងយោធពលខេមរភូមិន្ទ*



*ទិដ្ឋភាពនៃវិមានឯករាជ្យ និងវិមាន **ព្រះបរមរូប ព្រះបរមរតនកោដ្ឋ** ក្នុងថ្ងៃបុណ្យឯករាជ្យជាតិ*

វត្សរ៍ ព្រមទាំងជាប្រទេសជាប់ចំណាត់ថ្នាក់លេខ ១ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច ។

សម្តេចតេជោថ្លែងថា វឌ្ឍនភាពទាំងអស់នេះជាកត្តាមុតស្រួចជួយទ្រទ្រង់បន្ថែមទៀតដល់កំណើនសេដ្ឋកិច្ចកម្ពុជា ទាំងក្នុងពេលចំពោះមុខទាំងសម្រាប់អនាគតជាពិសេសនឹងជួយកម្ពុជាឱ្យអាចក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅ ឆ្នាំ ២០៥០ ។ ជាក់ស្តែងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបន្តធានាបាននូវការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រកបដោយស្ថិរភាព និងប្រកបដោយភាពអនុគ្រោះសម្រាប់ការអភិវឌ្ឍ ដែលក្នុងនោះ កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០១២ សម្រេចបានក្នុងអត្រា ៧,៣% ហើយចំណូលមនុស្សម្នាក់ជាមធ្យមចំនួន ៩៧៣ ដុល្លារអាមេរិក ។ ដោយឡែកនៅឆ្នាំ ២០១៣ នេះ កម្ពុជារំពឹងថា នឹងអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាប្រមាណ ៧,៦% ហើយផលិតផលក្នុងស្រុកសរុបសម្រាប់ ប្រជាជនម្នាក់ៗអាចនឹងឡើងដល់ចំនួន ១ ០៣៦ ដុល្លារអាមេរិក ។

សម្តេច **ហ៊ុន សែន** មានប្រសាសន៍ថា យ៉ាងណាក៏ដោយ យើងក៏នៅតែទទួលស្គាល់ថា ថ្វីត្បិតតែកម្ពុជាមានឯករាជ្យពេញលេញ មានសុខសន្តិភាពនិងមានភាពអនុគ្រោះដល់ការលូតលាស់ ប៉ុន្តែយើងក៏នៅតែមានបញ្ហាប្រឈមចំពោះមុខផងដែរ ពិសេសគឺភាពចាំបាច់ក្នុងការពង្រឹងកិច្ចអភិវឌ្ឍន៍នានារបស់ខ្លួនឱ្យប្រកបដោយចីរភាពសម្រាប់រយៈពេលវែងទៅមុខទៀត ការបែងចែកផលនៃកំណើនសេដ្ឋកិច្ចឱ្យប្រកបដោយសមធម៌ និងការធានាបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ ។ ជាងនេះទៀត កម្ពុជាក៏ត្រូវត្រៀមលក្ខណៈឱ្យ បានល្អ ក្នុងការបន្តធ្វើសមាហរណកម្មខ្លួនយ៉ាងពេញលេញទៅក្នុងសហគមន៍តំបន់និងពិភពលោក ពិសេសគឺសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ ២០១៥ ខាងមុខ ឆ្ពោះទៅរកវិបុលភាពចម្រើនរុងរឿងស្របតាមស្មារតីនៃបាវចនា "សហគមន៍តែមួយ-វាសនាតែមួយ" ដែលនេះជាបេសកកម្មថ្មីទៀត



របស់កម្ពុជាទន្ទឹមនឹងភាពចាំបាច់ក្នុងការបន្តខិតខំការពារឯករាជ្យភាព សុខសន្តិភាព ព្រមទាំងការខិតខំលើកកម្ពស់កិច្ចអភិវឌ្ឍន៍ ដែលកម្ពុជាសម្រេចបានក្នុងរយៈពេលកន្លងមកនោះ។

មានព្រះរាជឱង្ការនៅក្នុងមហាមិទ្ទីងនេះ ព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គទ្រង់បានលើកឡើងថា នៅក្នុងឱកាសដែលយើងទាំងអស់គ្នាកំពុងតែសប្បាយរីករាយ និងទទួលផលជាវិជ្ជមាន ដែលផ្តើមចេញពីកម្លាំងកសាង និងការពារជាតិមាតុភូមិប្រកបដោយសុខដុមរនារបស់ជនរួមជាតិយើងនោះ ព្រះអង្គអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋកម្ពុជាគ្រប់មជ្ឈដ្ឋាន សូមរួបរួមសាមគ្គីគ្នាជាធ្លុងមួយស្ថិតក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់រដ្ឋ ដើម្បីចូលរួមចំណែកការពារ និងកសាងមាតុភូមិលើគ្រប់វិស័យ។ លើមូលដ្ឋាននៃសាមគ្គីភាព ក្នុងស្ថានភាពសង្គមជាតិមានសុខសន្តិភាព និងស្ថិរភាពនយោបាយនេះហើយដែលយើងអាចបន្តជំរុញការអភិវឌ្ឍលើវិស័យនានាឱ្យកាន់តែខ្លាំងក្លាឡើង ជាពិសេស សេដ្ឋកិច្ចដែលជាដង្ហើមរស់របស់ជាតិយើង។ ព្រះមហាក្សត្រមានព្រះរាជឱង្ការថា សមិទ្ធផលដ៏ធំធេងទាំងឡាយដែលយើងសម្រេចបាននេះ ពិតជាបានមក តាមរយៈការ ខិតខំពង្រីកនូវសន្តិសុខ និងសន្តិភាព ការផ្សះផ្សារ បង្រួបបង្រួមជាតិ ការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការការពារសន្តិសុខ សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ការកែលម្អអភិបាលកិច្ច ដើម្បីលើកស្ទួយវិស័យសាធារណៈ និងសមធម៌សង្គម និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ដើម្បីបម្រើនូវសំណូមពរនៃការអភិវឌ្ឍជាតិ។

នៅក្នុងឱកាសនោះដែរ **ព្រះមហាក្សត្រ** បានសព្វព្រះរាជហឫទ័យថ្លែងសរសើរ និងគាំទ្រសុន្ទរ កថារបស់ សម្តេចតេជោ **ហ៊ុន សែន** ថាមានអត្ថន័យ និងខ្លឹមសារដ៏ ជ្រាលជ្រៅណាស់ ដែលព្រះអង្គសូមចាត់ទុកថា នេះគឺជាសារនយោបាយមួយមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងការវាយតម្លៃ សភាពការណ៍នៃសង្គមជាតិ ជាពិសេសលើវិស័យសេដ្ឋ-



*ព្រះករុណាព្រះបាទសម្តេច*
***ព្រះបរមនាថ នរោត្តម សីហមុនី***
*យាងពន្លត់ភ្លើងជ័យនៅវិមានឯករាជ្យ*

កិច្ច និងសង្គមកិច្ច។

គួររំឭកថា ស្របពេលដែលព្រះរាជាណាចក្រកម្ពុជាកំពុងប្រារព្ធទិវាបុណ្យឯករាជ្យជាតិលើកទី៦០នេះ មានប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងប្រមុខការទូតនៃបណ្តាប្រទេសជាច្រើននៅលើពិភពលោកបានផ្ញើសារលិខិតសម្តែងការអបអរសាទរ យ៉ាងកក់ក្តៅចំពោះព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ។ តាមរយៈសារលិខិតទាំងនេះនៅបានបង្ហាញច្បាស់នូវការរីកចម្រើនឥតឈប់ឈរនៃចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រកបដោយផ្លែផ្ការវាងព្រះរាជាណាចក្រកម្ពុជា និងបណ្តាប្រទេស ជាពិសេសទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា ជាមួយរដ្ឋាភិបាលនៃបណ្តាប្រទេសលើពិភពលោក ។ បុណ្យឯករាជ្យជាតិខួបទី ៦០ ត្រូវបានបញ្ចប់នៅរសៀលថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ បន្ទាប់ពីព្រះករុណា ព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានស្តេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីពន្លត់ភ្លើងជ័យនៅវិមានឯករាជ្យ ដោយមានព្រះរាជវង្សានុវង្ស ថ្នាក់ដឹកនាំរដ្ឋ បណ្តាអង្គទូតប្រទេសជាមិត្តប្រចាំព្រះរាជាណាចក្រកម្ពុជា កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ត្រីរាជការ និងប្រជាជនយ៉ាងច្រើនកុះករបានចូលរួម ។/



# សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ទទួលគ្រឿងឥស្សរិយយស ថ្នាក់ខ្ពស់បំផុត ពីព្រះចៅអធិរាជជប៉ុន






*ឯកឧត្តម **គូម៉ាម៉ារ៉ូយូជិ** ប្រគល់គ្រឿងឥស្សរិយយសលំដាប់ថ្នាក់ខ្ពស់បំផុតនៃប្រទេសជប៉ុន Grand Cordon of the Order of the Rising Sun ជូនសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម***

សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា បានអញ្ជើញទទួលគ្រឿងឥស្សរិយយសលំដាប់ថ្នាក់ខ្ពស់បំផុតនៃប្រទេសជប៉ុន Grand Cordon of the Order of the Rising Sun កាលពីរសៀលថ្ងៃទី ២៨ វិច្ឆិកា ឆ្នាំ ២០១៣ នៅក្នុងពិធីដ៏មហោឡារិកមួយដែលបានប្រារព្ធនៅស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តម **គូម៉ាម៉ារ៉ូយូជិ** ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះចៅអធិរាជជប៉ុនបានប្រគល់គ្រឿងឥស្សរិយយសដ៏ឧត្តុង្គឧត្តមនេះជូនសម្តេចអគ្គមហាធម្មពោធិសាល ។

ថ្លែងនៅក្នុងពិធីនេះ ឯកឧត្តមឯកអគ្គរាជទូតជប៉ុនបានមានប្រសាសន៍ថា ការផ្តល់ជូនគ្រឿងឥស្សរិយយសលំដាប់ថ្នាក់ខ្ពស់បំផុតរបស់ប្រទេសជប៉ុន ប្រភេទ Grand Cordon of the Order of the Rising Sun ជូនដល់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជានាពេលនេះ គឺជាការគាំទ្រយ៉ាងសកម្មដល់កិច្ចខិតខំប្រឹងប្រែងផ្នែកការទូតរវាងប្រទេសទាំងពីរជប៉ុន-កម្ពុជា និងជាការរួមចំណែកលើកស្ទួយមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំទ្បើង ។

ឯកឧត្តម **គូម៉ាម៉ារ៉ូយូជិ** បន្តថា គ្រឿងឥស្សរិយយសលំដាប់ថ្នាក់ខ្ពស់បំផុតរបស់ប្រទេសជប៉ុននេះ គឺជាការផ្តល់ជូនជាលើកទី ១ ហើយ ក្នុងប្រវត្តិសាស្ត្រទំនាក់ទំនងរវាងប្រទេសទាំងពីរជប៉ុន-កម្ពុជា ហើយការផ្តល់ជូននេះ ស្របពេលដែលប្រទេសទាំងពីរជប៉ុន-កម្ពុជា កំពុងប្រារព្ធខួបអនុស្សាវរីយ៍លើកទី ៦០ ឆ្នាំ នៃទំនាក់ទំនងការទូត ។ ការផ្តល់ជូនគ្រឿងឥស្សរិយយសនេះ ក៏ជាការទទួលស្គាល់នូវការរួមចំណែកដ៏ធំធេងរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ក្នុងការកសាងគ្រឹះសម្រាប់ជំរុញការផ្លាស់ប្តូរសភាតំណាងរាស្ត្រនៃប្រទេសទាំងពីរ តាមរយៈដំណើរទស្សនកិច្ចរបស់សម្តេចមកកាន់ប្រទេសជប៉ុនចំនួន ៥ លើក រវាងឆ្នាំ ១៩៩៣ និង ១៩៩៩ និងការផ្តួចផ្តើមគំនិតបង្កើតក្រុមមិត្តភាពសភា កម្ពុជា-ជប៉ុន នៅក្នុងរដ្ឋសភា និងព្រឹទ្ធសភា រវាង ឆ្នាំ ១៩៩៤ និង ១៩៩៩ ។ ឯកឧត្តមបានបញ្ជាក់ថា ប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានការផ្តល់គំនិតពីសំណាក់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា លើការអភិវឌ្ឍទំនាក់ទំនងផ្នែកសេដ្ឋកិច្ចរវាងប្រទេសទាំងពីរជប៉ុន-កម្ពុជា ទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ ជប៉ុន-កម្ពុជា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។

មានប្រសាសន៍នៅក្នុងឱកាសនោះ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** បានសម្តែងនូវការអរគុណ និងដឹងគុណដ៏ជ្រាលជ្រៅ ប្រកបដោយកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ថ្វាយព្រះចៅអធិរាជជប៉ុន និងជូនចំពោះរាជរដ្ឋាភិបាលជប៉ុន ដែលបានសម្រេចផ្តល់នូវគ្រឿងឥស្សរិយយសថ្នាក់ខ្ពស់បំផុតនៃប្រទេសជប៉ុន Grand Cordon of the Order of the Rising Sun ជូនដល់សម្តេចនាពេលនេះ ។

សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** បានមានប្រសាសន៍ថា ការសម្រេចផ្តល់ជូននូវគ្រឿងឥស្សរិយយសដ៏មានតម្លៃខ្ពង់ខ្ពស់នាពេលនេះ គឺជាការផ្តល់នូវមហាកិត្តិយសដ៏ធំធេងបំផុតសម្រាប់ប្រជាជន រាជរដ្ឋាភិបាល និងសភាកម្ពុជា ។ ម្យ៉ាងវិញទៀត ការផ្តល់នូវគ្រឿងឥស្សរិយយសនេះ គឺជានិមិត្តរូបដ៏រឹងមាំ ឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃដែលមានពីយូរលង់ណាស់មកហើយរវាងប្រជាជន និងប្រទេសទាំងពីរ និង

តទៅទំព័រទី ២៧

# សម្ដេចចក្រី ហេង សំរិន ជួបសន្ទនាការជាមួយ ប្រធានរដ្ឋសភានៃសាធារណរដ្ឋកូដឌីវ័រ




*សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ទទួលស្វាគមន៍យ៉ាងកក់ក្ដៅ និងជួបសន្ទនាការជាមួយឯកឧត្តម **គ្រីយូម គីតបាហ្វ៊ី សូរ៉ូ***

នៅព្រឹកថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៣ សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានជួបសន្ទនាការជាមួយឯកឧត្តម **គ្រីយូម គីតបាហ្វ៊ី សូរ៉ូ** ( Guillaume Kigbafori SORO) ប្រធានរដ្ឋសភានៃសាធារណរដ្ឋកូដឌីវ័រ នៅវិមានរដ្ឋសភា។

នៅក្នុងជំនួបនោះ ឯកឧត្តម **គ្រីយូម គីតបាហ្វ៊ី សូរ៉ូ** ប្រធានរដ្ឋសភានៃសាធារណរដ្ឋកូដឌីវ័របានកោតសសើរចំពោះសម្ដេច **ហេង សំរិន** ដែលបានចំណាយពេលជិត ៥០ ឆ្នាំ ក្នុងការកសាងប្រទេសកម្ពុជា។ ឯកឧត្តមបានជម្រាបជូនពីគោលបំណងចម្បងនៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅកម្ពុជានាពេលនេះ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា កូដឌីវ័រ ជាពិសេសជាមួយស្ថាប័ននីតិបញ្ញត្តិនៃប្រទេសទាំងពីរ ។ ឯកឧត្តមបានចាត់ទុកសម្ដេចចក្រី **ហេង សំរិន** ជាវៀមច្បង និងសុំហៅសម្ដេចជាមហាវីរបុរស ដោយសារសម្ដេចបានប្រើប្រាស់មួយជីវិតរបស់សម្ដេចដើម្បីរំដោះ និងកសាងប្រទេស។ ឯកឧត្តមក៏បានជម្រាបជូនសម្ដេចថា ប្រទេសកូដឌីវ័រក៏ជាប្រទេសមានស្ថានភាពប្រហាក់ប្រហែលទៅនឹងប្រទេសកម្ពុជាដែរ ធ្លាប់ទទួលរងនូវការជិះជាន់ពីអាណានិគមនិយមបារាំង ទទួលបានឯករាជ្យនៅឆ្នាំ ១៩៦០ ។ ក្រោយទទួលបានឯករាជ្យ ប្រទេសត្រូវបន្តធ្លាក់ក្នុងវិបត្តិនយោបាយទៀត ហើយទើបតែនឹងឆ្លងផុតវិបត្តិនយោបាយផ្ទៃក្នុងពីឆ្នាំ ២០១០ មក។

បច្ចុប្បន្ន ប្រទេសកូដឌីវ័រជាប្រទេសកសិកម្មមួយដែលនាំចេញកាហ្វេកាកាវលំដាប់លេខ ១ លើពិភពលោក ឆ្នាំ ២០១៣ នេះ កម្លាំងសេដ្ឋកិច្ចសង្ឃឹមថានឹងកើនឡើងប្រមាណ ១០% ។ដោយឡែកនៅក្នុងសភាកូដឌីវ័រមានសមាជិកសភាសរុបចំនួន ២៥៥ រូប ក្នុងនោះមានស្ត្រីចំនួន ២៥ រូប និងមានប្រជាជនសរុបជាង ២១ លាន នាក់ ។ ឆ្លៀតឱកាសនោះដែរ ឯកឧត្តម **គ្រី យូមគីតបាហ្វ៊ី សូរ៉ូ** ក៏បានសុំគោរពអញ្ជើញសម្ដេចចក្រី **ហេង សំរិន** ដឹកនាំគណៈប្រតិភូទៅធ្វើទស្សនកិច្ចជាផ្លូវការ និងជាមិត្តភាពនៅសាធារណរដ្ឋកូដឌីវ័រនាពេលខាងមុខនេះផងដែរ។

សម្ដេចចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាបានមានប្រសាសន៍ថា តាមរយៈកិច្ចសហប្រតិបត្តិការនេះ ប្រទេសទាំងពីរគ្រោងនឹងចុះកិច្ចព្រមព្រៀងជាមួយគ្នា ដោយសេចក្ដីព្រាងនៃខ្លឹមសារកិច្ចព្រមព្រៀងនោះរដ្ឋសភាប្រទេសទាំងពីរនឹងដាក់ឆ្លងគ្នាទៅវិញទៅមកនៅពេលខាងមុខនេះ ។ សម្ដេចចក្រី **ហេង សំរិន** បន្តថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅពេលនេះ គឺស្របពេលដែលប្រជាជនកម្ពុជាទើបបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ ដែលបានប្រព្រឹត្តទៅកាលពីចុងខែកក្កដាប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សាដែលអាចនិយាយបានថា លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាបានវិវត្តជាវិជ្ជមាន។

សម្ដេចប្រធានរដ្ឋសភាបានបន្តថា ប្រទេសកម្ពុជាបានបន្តប្រកាន់ខ្ជាប់នយោបាយការបរទេសអព្យាក្រឹតសន្តិសហវិជ្ជមាននិងមិនចូលបក្សសម្ព័ន្ធ កម្ពុជាចូលរួមយ៉ាងសកម្មជាមួយបណ្ដាប្រទេសផ្សេងៗក្នុងការដោះស្រាយបញ្ហាប្រឈមសំខាន់ៗជាអន្តរជាតិដូចជាការប្រយុទ្ធប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន កិច្ចការពារបរិស្ថានជាដើម ។

គួរបញ្ជាក់ថា ឯកឧត្តម **គ្រីយូម គិតបាហ្វ៊ី សូរ៉ូ** បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជាចំនួន ៤ ថ្ងៃ ចាប់ពីថ្ងៃទី ២៣ ដល់ ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ តាមការអញ្ជើញរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងដំណើរទស្សនកិច្ចនេះដែរ ឯកឧត្តម **គ្រីយូម គិតបាហ្វ៊ី សូរ៉ូ** បានចូលក្រាបបង្គំគាល់ព្រះមហាក្សត្រព្រះករុណា ព្រះបាទសម្ដេច **ព្រះបរមនាថ នរោត្តម សីហមុនី** ជួបសម្ដែងការគួរសមជាមួយសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនៃក្រសួងមួយចំនួន និងឯកឧត្តមឧកញ៉ា **គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា ។/

# កម្ពុជា_ជប៉ុន ធ្វើការរួមគ្នាដើម្បីឈានជាបណ្ដើរៗទៅជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ

## វត្តមានរបស់ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកនៅកម្ពុជាបញ្ជាក់ពីគោលនយោបាយរបស់អាមេរិកបន្តគាំទ្រកម្ពុជា






*ឯកឧត្តម **ស៊ិនហ្សូ អាបេ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រជប៉ុន*
*និងសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*

*ចាប់តាំងពីក្រោយថ្ងៃបោះឆ្នោតថ្ងៃ ២៨ ខែកក្កដា ឆ្នាំ ២០១៣ ដែលគណបក្សប្រជាជនកម្ពុជាបានទទួលជ័យជម្នះ និងក្រោយពេលដែលរដ្ឋសភា និងរាជរដ្ឋាភិបាលនីតិកាលទី ៥ បានបដិសន្ធិឡើងស្របតាមរដ្ឋធម្មនុញ្ញ និងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា គណបក្សប្រឆាំងបានធ្វើការជំទាស់យ៉ាងងងើលបដិសេធលទ្ធផលនៃការបោះឆ្នោត ធ្វើពហិការមិនចូលប្រជុំរដ្ឋសភា មិនទទួលស្គាល់រដ្ឋសភា និងរាជរដ្ឋាភិបាល ហើយថែមទាំងបានអំពាវនាវឱ្យសហគមន៍អន្តរជាតិមិនទទួលស្គាល់ និងដាក់សំពាធគ្រប់យ៉ាងថែមទៀត ។ នេះជានយោបាយទុច្ចរិតរបស់គណបក្សប្រឆាំងដែលព្យាយាមបន្ទុះបង្អាប់រាជរដ្ឋាភិបាល និងរដ្ឋសភា ហើយមានបំណងដ៏ខ្មៅកខ្វក់ក្នុងការរារាំងមិនឱ្យសហគមន៍អន្តរជាតិពង្រីកកិច្ចសហប្រតិបត្តិការ និងផ្ដល់ជំនួយមកកម្ពុជា ។ ទង្វើដ៏អាក្រក់នេះបានដើរផ្ទុយទាំងស្រុងទៅនឹងឆន្ទៈរបស់ប្រជាពលរដ្ឋកម្ពុជាជាម្ចាស់ឆ្នោត ។ ប៉ុន្ដែរាល់ការអំពាវនាវរបស់មេដឹកនាំបក្សប្រឆាំងទៅកាន់មេដឹកនាំនៃបណ្ដាប្រទេសនានា និងអ្នកវិនិយោគទុនបរទេសកុំឱ្យមកបណ្ដាក់ទុន និងកុំឱ្យផ្ដល់ជំនួយដល់កម្ពុជាគឺគ្មានតម្លៃឡើយ ។ សហគមន៍អន្តរជាតិបានបន្តទទួលស្គាល់ និងបន្តគាំទ្ររាជរដ្ឋាភិបាលកម្ពុជាយ៉ាងច្រើនលើសលប់ តាមរយៈការផ្ញើសារអបអរសាទរចំពោះជោគជ័យនៃការបោះឆ្នោតនៅកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយសម្ដេចតេជោ **ហ៊ុន សែន** រួមទាំងដំណើរទស្សនកិច្ចរបស់មន្ត្រីដឹកនាំជាន់ខ្ពស់នៃប្រទេសនានាមកកាន់កម្ពុជាទៀតផង ។*

ជាក់ស្ដែងនៅថ្ងៃទី១៦-១៧ខែវិច្ឆិកាឆ្នាំ២០១៣ឯកឧត្តម **ស៊ិនហ្សូ អាបេ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រជប៉ុនបានអញ្ជើញមកបំពេញទស្សនកិច្ចជាមិត្តភាពផ្លូវការនៅកម្ពុជាយ៉ាងឧឡារិក ។ ឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុន បានជួបពិភាក្សាការងារយ៉ាងស្និទ្ធស្នាលកក់ក្ដៅជាមួយសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ចូលថ្វាយបង្គំគាល់ព្រះករុណាព្រះបាទ **សម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងបានបំពេញការងារសំខាន់ៗមួយចំនួនទៀត ។

នៅពេលជួបពិភាក្សាការងារជាមួយសម្ដេចតេជោ **ហ៊ុន សែន** ឯកឧត្តម **ស៊ិនហ្សូ អាបេ** បានសម្ដែងការរីករាយក្រៃលែងហើយបញ្ជាក់ថា រូបលោកមានកិត្តិយសណាស់ដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជាឆ្នាំនេះ ព្រោះជាខួបអនុស្សាវរីយ៍ឆ្នាំទី៦០ នៃទំនាក់ទំនងជប៉ុន-កម្ពុជា ។ ឯកឧត្តម **អាបេ** បានថ្លែងថា នៅក្នុងវិស័យសេដ្ឋកិច្ចជប៉ុនមិនត្រឹមតែបន្តអនុវត្តនូវកិច្ចសហប្រតិបត្តិការតាមរយៈជំនួយអភិវឌ្ឍន៍ជាផ្លូវការប៉ុណ្ណោះទេ ប៉ុន្ដែជប៉ុនមានបំណងជំរុញឱ្យក្រុមហ៊ុនជប៉ុនមកធ្វើការវិនិយោគកាន់តែច្រើនផងដែរ ។ លើសពីនេះ ឯកឧត្តម **អាបេ** បានសម្ដែងនូវការស្វាគមន៍ចំពោះលទ្ធផលនៃការបោះឆ្នោតកន្លងមកដែលបានប្រព្រឹត្តទៅដោយសន្តិភាព ។ ជប៉ុនបន្តយកចិត្តទុកដាក់ដល់ការបោសសំអាតគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅកម្ពុជាតាមរយៈការប្រកាសផ្ដល់ជំនួយមានទឹកប្រាក់ ៥០០ លានយ៉េន ។ ជប៉ុនបន្តជួយដល់ដំណើរការរបស់សាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហមតាមរយៈការផ្ដល់ថវិកាចំនួន ១,៨ លានដុល្លារ ក្នុងឆ្នាំ ២០១៤ ។ ឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុនបានអញ្ជើញយុវជនកម្ពុជាចំនួន ៣ ពាន់នាក់ទៅបំពេញទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន សម្រាប់រយៈពេល ៥ ឆ្នាំ ដោយចាប់អនុវត្តពីឆ្នាំ ២០១៤ តទៅ ។ ក្នុងឱកាសនោះ សម្ដេចតេជោ **ហ៊ុន សែន** ក៏បានស្នើឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុនពិចារណាបញ្ជូនជំនាញការដើម្បីចូលរួមកែទម្រង់ការបោះឆ្នោតនៅកម្ពុជានាពេលខាងមុខ ។ ជប៉ុនជាប្រទេសទីមួយដែលកម្ពុជាបានស្នើសុំ ព្រោះជប៉ុនគឺ

ជាប្រទេសប្រជាធិបតេយ្យចាស់ទុំ ហើយមានបទពិសោធន៍យ៉ាងច្រើនលើការបោះឆ្នោត ។ សម្តេចតេជោក៏បានថ្លែងផងដែរថា រូបសម្តេច និង ឯកឧត្តម **អាបេ** បានលើកយកមកពិភាក្សាបញ្ហាជាច្រើនទាក់ទិនជាមួយការរួមគ្នាធ្វើការដើម្បីពិចារណា ឈានជាបណ្តើរៗទៅជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ។ មេដឹកនាំទាំងពីរបានពិភាក្សា ប្រកបដោយផ្លែផ្កាគ្របដណ្តប់ស្ទើរតែគ្រប់ទិដ្ឋភាពនៃទំនាក់ទំនងទ្វេភាគីក៏ដូចជាបញ្ហាតំបន់ និងបញ្ហាអន្តរជាតិ ។ សម្តេចតេជោបានថ្លែង ទៀតថា ការផ្តល់ជំនួយហិរញ្ញប្បទាន ក៏ដូចជាការទាក់ទាញវិនិយោគជប៉ុនមកកាន់កម្ពុជា គឺជាគោលដៅ និងជាទំនាក់ទំនងរវាងប្រជាជន នឹងប្រជាជន ការភ្ជាប់ការហោះហើរគឺជាប្រធានបទនៃការពិភាក្សាយ៉ាងសំខាន់ ។ តួនាទីរបស់ជប៉ុននៅក្នុងការថែរក្សាសន្តិភាពតំបន់ និងពិភពលោក ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ ។ សម្តេចតេជោ **ហ៊ុន សែន** បានសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះជប៉ុន ដែលបានគាំទ្រកម្ពុជាតាំងពីដំណើរការស្វែងរកសន្តិភាពរហូតមកដល់ការអភិវឌ្ឍប្រទេសជាតិនាពេលបច្ចុប្បន្ន ។ សម្តេចបានមានប្រសាសន៍ថា យើង បានលើកវិធានការជាច្រើនជាមួយគ្នាដើម្បីពង្រឹងនូវចំណងទាក់ទង នេះឱ្យកាន់តែប្រសើរថែមទៀត ។

នៅក្នុងដំណើរទស្សនកិច្ចរបស់ឯកឧត្តម **អាបេ** នាពេលនេះក៏មានការចុះហត្ថលេខាលើឯកសារចំនួនពីរគឺ ទី១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានឹងរាជរដ្ឋាភិបាលជប៉ុនស្តីពីកិច្ចសហប្រតិបត្តិការ អប់រំ និងបណ្តុះបណ្តាលក្នុងវិស័យប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងទី២-អនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពជប៉ុន ។

ក្នុងឱកាសស្នាក់អាស្រ័យនៅកម្ពុជាឯកឧត្តម **ស៊ីន ហ្សូអាបេ** ក៏បានអញ្ជើញចូលរួមក្នុងសិក្ខាសាលាស្តីពីសុខភាព និងសេវាកម្មវេជ្ជសាស្ត្រក្រោមប្រធានបទ"ដាច់សរសៃឈាមខួរក្បាល"ដោយឯកឧត្តមបានសម្តែងនូវការគាំទ្រចំពោះការបង្កើតឱ្យមានមន្ទីរពេទ្យមួយរបស់ជប៉ុននៅលើទឹកដីកម្ពុជាក្នុងពេលឆាប់ៗនេះ ។ មន្ទីរពេទ្យថ្មីនេះនឹងមានសកម្មភាពនាពេលខាងមុខក្នុងរាជធានីភ្នំពេញ ហើយមន្ទីរពេទ្យជប៉ុនព្យាបាលជំងឺប្រភេទនេះគឺជាលើកទី ១ ហើយ ដែលត្រូវបានកសាងនៅក្រៅប្រទេសជប៉ុន ។ នេះជាផលនៃកិច្ចសហប្រតិបត្តិការថ្មីមួយទៀតរវាងជប៉ុន និងកម្ពុជា ។ មន្ទីរនេះនឹងព្យាបាលវេជ្ជសាស្ត្រតាមរបៀបជប៉ុន ហើយការព្យាបាលនេះមិន ត្រឹមតែជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺបេះដូង និងគ្រោះថ្នាក់ចរាចរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងព្យាបាលជំងឺផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃវេជ្ជសាស្ត្រប្រចាំថ្ងៃផងដែរ ។ យើងនឹងមានសេវាកម្មជប៉ុនកម្រិតខ្ពស់នៅក្នុងប្រទេសកម្ពុជា ហើយប្រជាជនកម្ពុជាទាំងអស់អាចថែទាំសុខភាពដោយមិនចាំបាច់ទៅក្រៅប្រទេសដើម្បីពិនិត្យ និងព្យាបាលនោះទេ ។ ឯកឧត្តម **អាបេ** បានថ្លែងទៀតថា គម្រោងមន្ទីរពេទ្យថ្មីនេះ



*ឯកឧត្តម **អ៊ឹច បូរិទ្ធ** ទទួលជួបសវនាការ ជាមួយឯកឧត្តម Scot T Marciel*

នឹងក្លាយជាស្ពានមេត្រីភាពរវាងជប៉ុន និងកម្ពុជា ដោយវិស័យវេជ្ជសាស្ត្រ វិស័យឧស្សាហកម្ម សហការគ្នាដោយម៉ត់ចត់ ។

គួរបញ្ជាក់ថា នៅក្នុងដំណើរទស្សនកិច្ចនេះ ឯកឧត្តម ស៊ីន ហ្សូអាបេ បានអញ្ជើញសម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន ទៅបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រជប៉ុននាខែធ្នូ ឆ្នាំ ២០១៣ នេះ ហើយដែលសេចក្តីអញ្ជើញនេះ ត្រូវបានទទួលការយល់ព្រមពីសម្តេចតេជោរួចហើយ ។

ដោយឡែកកាលពីថ្ងៃទី០៤ខែវិច្ឆិកា ឯកឧត្តមScot T Marciel ឧបការីរងរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកក៏បានអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជាដែរ ហើយបានជួបសន្ទនាជាមួយឯកឧត្តម **អ៊ឹច បូរិទ្ធ** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ ដំណើរទស្សនកិច្ចរបស់ឯកឧត្តម Scot T Marciel នៅកម្ពុជាបានបង្ហាញច្បាស់អំពីការបន្តកិច្ចសហប្រតិបត្តិការបន្តទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាមេរិក ហើយជាសញ្ញាមួយបញ្ជាក់ថា ការអំពាវនាវទាំងឡាយរបស់បក្ស ប្រឆាំងដែលរារាំងមិនឱ្យបរទេសទទួលស្គាល់កម្ពុជាត្រូវ ទទួលបរាជ័យ និងកាន់តែសាបរលាបទៅៗ មិនមានឥទ្ធិពលអ្វីទាំងអស់ ។ ក្នុងពេលឯកឧត្តម Scot T Marciel ជួបជាមួយឯកឧត្តម **អ៊ឹច បូរិទ្ធ** ភាគីទាំងពីរបានពិភាក្សាគ្នាទាក់ទិនទៅនឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាច្រើនទៀតនៅអាស៊ីអាគ្នេយ៍ក៏ដូចជានៅលើពិភពលោក ។ ចំណុចដែលសំខាន់នោះគឺលោកឧបការីរងរដ្ឋមន្ត្រីការបរទេសអាមេរិកបានលើកឡើងពីគោលនយោបាយរបស់សហរដ្ឋអាមេរិកដែលបានគាំទ្រកម្ពុជាយើងនៅក្នុងវិស័យសេដ្ឋកិច្ច និងនយោបាយ ។ ឯកឧត្តម Scot T Marciel បានថ្លែងប្រាប់ឯកឧត្តម **អ៊ឹច បូរិទ្ធ** ថា វត្តមានរបស់លោកនៅក្នុងប្រទេសកម្ពុជា ហើយដែលបានជួបពិភាក្សាជាមួយគណបក្សប្រឆាំងដែរនោះ មិនមែនមានន័យថាជាការគាំទ្រទេ សំខាន់បំផុតនោះគឺជានយោបាយរបស់អាមេរិកក្នុងការគាំទ្រលទ្ធិប្រជាធិបតេយ្យ ហើយសហរដ្ឋអាមេរិកនឹងបន្តគាំទ្រកម្ពុជាក្នុងការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ។/

# គ្រួសាររងគ្រោះទឹកជំនន់ ៥៣.៧០១ គ្រួសារ ទទួលអំណោយពីកាកបាទក្រហមកម្ពុជា





*សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ក្នុងឱកាសជួបសំណេះសំណាលសួរសុខទុក្ខ និងផ្ដល់អំណោយសង្គ្រោះបន្ទាន់ដល់គ្រួសាររងគ្រោះដោយទឹកជំនន់នៅខេត្តសៀមរាប បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន និងព្រះវិហារ*

*ក្នុងរយៈពេលនៃទឹកជំនន់ភ្លៀង និងជំនន់ដោយការបាក់ទំនប់( សៀមរាប បាត់ដំបង) ក្នុងភាគពាយព្យ និងភាគឧត្តររបស់ប្រទេស ព្រមទាំងទឹកជំនន់តាមដងទន្លេមេគង្គដែលបានធ្វើឱ្យប្រជាពលរដ្ឋចំនួន៤១៨.៧៣៦ គ្រួសាររងផលប៉ះពាល់ និងបានធ្វើឱ្យមនុស្សស្លាប់ ១៣៩ នាក់ របួស ១៨ នាក់ នៅតាមឃុំចំនួន ៧១០ ក្នុងស្រុកចំនួន ១៣០ នៃរាជធានី-ខេត្ត ចំនួន ២០ នោះ ( យោងតួលេខរបស់ គ.ជ.គ.ម ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣) កាកបាទក្រហមកម្ពុជា ដែលជាជំនួយការឱ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌ បានធ្វើប្រតិបត្តិការផ្ដល់ អំណោយមនុស្សធម៌ពីថ្ងៃទី ៨ ខែសីហា រហូតមកដល់ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ នេះ សម្រេចបានដល់ដៃគ្រួសាររងគ្រោះរស់នៅតាមទួលសុវត្ថិភាព និងគ្រួសាររងគ្រោះធ្ងន់ធ្ងរចំនួន ៥៣.៧០១ គ្រួសារ( លើចំនួនគ្រួសារបានទទួលអំណោយសរុបពីគ្រប់មជ្ឈដ្ឋានចំនួន ១១៣. ៩០៣ គ្រួសារ) ។*

ក្នុងប្រតិបត្តិការផ្ដល់អំណោយមនុស្សធម៌ខាងលើនេះ ដោយឈរលើគោលការណ៍វិមជ្ឈការ សាខានីមួយៗបានយកអស់លទ្ធភាពធនធានរបស់ខ្លួន ចូលរួមជាមួយអាជ្ញាធរមូលដ្ឋានក្នុងការជួយជម្លៀសប្រជាពលរដ្ឋរងគ្រោះមកកាន់ទួលសុវត្ថិភាព ការដោះស្រាយផ្ដល់ទីជម្រក និងការអប់រំថែទាំសុខភាពអនាម័យនៅតាមទួលសុវត្ថិភាពនានា។ នៅតាមគោលដៅមួយចំនួនដែលការដឹកជញ្ជូនពីរាជធានីភ្នំពេញមិនអាចទៅដល់ភ្លាមៗបាន សាខាធ្វើការជាមួយវិស័យឯកជនក្នុងខេត្តដោះស្រាយអង្ករជូនបងប្អូនរងគ្រោះ រួចថ្នាក់កណ្ដាលធ្វើការទូទាត់ថវិកាជូនតាមក្រោយ។ បន្ទាប់មក គឺជាការចុះធ្វើប្រតិបត្តិការដោយផ្ទាល់ពីថ្នាក់កណ្ដាល ដោយមានការចូលរួមជួយគាំទ្រពីសាខាកាកបាទក្រហមកម្ពុជា អាជ្ញាធរខេត្ត-ស្រុក នៅក្នុងខេត្តរងគ្រោះនីមួយៗ។

សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា បានចុះចែកអំណោយដោយផ្ទាល់ដល់គ្រួសាររងគ្រោះនៅក្នុងខេត្តសៀមរាប បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិននិងព្រះវិហារ ជាមួយនឹងការបែងចែកកម្លាំងរបស់ក្រុមប្រតិបត្តិដែលមាន អគ្គលេខាធិការ អគ្គលេខាធិការរង នាយកនាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ ចុះធ្វើប្រតិបត្តិការចែកបានដល់ដៃប្រជាពលរដ្ឋរងគ្រោះ ដោយពុំមានការបែងចែកវណ្ណៈ ពូជសាសន៍ និន្នាការនយោបាយ និងការធានាឱ្យបានថា គ្រួសាររងគ្រោះពិតប្រាកដ គឺជាអ្នកទទួលផលពិតនៃអំណោយសប្បុរសធម៌របស់កាកបាទក្រហមកម្ពុជា។

គ្រួសារទទួលផលពីកាកបាទក្រហមកម្ពុជា មានខេត្តព្រះវិហារចំនួន ៤.៨៤០ គ្រួសារ ខេត្តឧត្តរមានជ័យចំនួន ១.៣៦៤ គ្រួសារ ខេត្តបន្ទាយមានជ័យចំនួន ៦.៦២៦ គ្រួសារ ខេត្តប៉ៃលិនចំនួន ៤.២៤០ គ្រួសារ ខេត្តបាត់ដំបងចំនួន ៦.៤៩៧ គ្រួសារ ខេត្តសៀមរាបចំនួន ១០.៨៧០ គ្រួសារ ខេត្តពោធិសាត់ចំនួន ២.៨៥១ គ្រួសារ ខេត្តរតនគីរីចំនួន ១.៩៧០ គ្រួសារ ខេត្តស្ទឹងត្រែងចំនួន ១.៤២២ គ្រួសារ ខេត្តក្រចេះចំនួន ៩៤១ គ្រួសារ ខេត្តកំពង់ចាមចំនួន ៤.៧៧៧ គ្រួសារ ខេត្តកំពង់ឆ្នាំងចំនួន ១.៣០៨ គ្រួសារ រាជធានីភ្នំពេញចំនួន ២៥០ គ្រួសារ និងខេត្តព្រៃវែងចំនួន ១១៧ គ្រួសារ ។

ជាមួយនឹងមនោសញ្ចេតនាស្រឡាញ់ និងគិតគូរជានិច្ចដល់សុខទុក្ខរបស់បង-ប្អូនប្រជាពលរដ្ឋ សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** បានផ្ដល់អនុសាសន៍ដល់ក្រុមប្រតិបត្តិនិងសាខាកាកបាទក្រហមកម្ពុជាថា ក្នុងពេលដែលរាជរដ្ឋាភិបាលកម្ពុជាអនុវត្តវិធានការ និងចំណាត់ការផ្សេងៗ ដើម្បីស្ដារ និងកសាងប្រទេសឡើងវិញនូវផល

វិបាកនានាបង្កដោយទឹកជំនន់ឆ្នាំ ២០១៣ នេះ កាកបាទក្រហមកម្ពុជាត្រូវបន្តបំពេញតួនាទីរបស់ខ្លួនជាជំនួយការឱ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌ទៅតាមអាណត្តិ ដែលផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយបានដាក់ចុះ នោះគឺជាការផ្តល់ស្បៀងក្នុងជុំទី ២ ដែលនោះគឺការជួយដល់ក្រុមគោលដៅងាយរងគ្រោះបំផុតមាន ដូចជា គ្រួសារចាស់ជរាគ្មានទីពឹង ស្ត្រីមេម៉ាយ គ្រួសារមានកូនច្រើនក្នុងបន្ទុក កុមារកំព្រា ជនពិការ ។ល។ ដែលសាខា-អនុសាខានីមួយៗត្រូវចុះពិនិត្យមើលការខ្វះខាតជាក់ស្តែងនៅតាមមូលដ្ឋានដើម្បីលើកសំណើមកថ្នាក់កណ្តាល ។

ក្នុងការវាយតម្លៃខ្ពស់ដល់ជោគជ័យរបស់កាកបាទក្រហមកម្ពុជា សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន**ប៊ុន រ៉ានី ហ៊ុនសែន** បានគូសបញ្ជាក់ថា កត្តាជោគជ័យរបស់កាកបាទក្រហមកម្ពុជា គឺស្ថិតនៅលើព្រះរាជគំរូសកម្មភាពមនុស្សធម៌នៃ **ព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា** ភាពជាអ្នកដឹកនាំតាមគោល-ការណ៍អភិបាលកិច្ចល្អ គ្រប់គ្រងមានតម្លាភាពនៅគ្រប់លំដាប់ថ្នាក់របស់កាកបាទក្រហមកម្ពុជា ការជឿទុកចិត្តពីសប្បុរសជន អ្នករងគ្រោះពិតបានទទួលអំណោយដោយពុំមានការបែងចែកពូជសាសន៍ ពុំមានការរើសអើង ការគោរពតាមគោលការណ៍គ្រឹះទាំង ៧ របស់ចល-នាកាកបាទក្រហម អឌ្ឍចន្ទក្រហម ។

បើទោះបីជាមានមតិខ្លះរិះគន់ថា កាកបាទក្រហមកម្ពុជាមានការយឺតយ៉ាវក្នុងការផ្តល់អំណោយមនុស្សធម៌របស់ខ្លួនយ៉ាងណាក៏ដោយ ក៏ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជានៅគ្រប់លំដាប់ថ្នាក់ នៅតែបន្តការលះបង់ពេលវេលា កម្លាំងកាយចិត្ត ប្រកបដោយទឹកចិត្តមនុស្សធម៌ និងការទទួលខុសត្រូវខ្ពស់ ពុះពារជួយអ្នកងាយរងគ្រោះទាំងឡាយ តាមគោលការណ៍គ្រឹះរបស់កាកបាទក្រហមកម្ពុជា ។



*សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ក្នុងឱកាសជួបសំណេះសំណាលសួរសុខទុក្ខ និងផ្តល់អំណោយសង្គ្រោះបន្ទាន់ដល់គ្រួសាររងគ្រោះដោយទឹកជំនន់*

សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន តែងតែអំពាវនាវឱ្យសប្បុរសជនគ្រប់មជ្ឈដ្ឋានជាតិ-អន្តរជាតិ ចូលរួមបន្តជួយដល់បងប្អូនប្រជាពល-រដ្ឋយើងតាមរយៈកាកបាទក្រហមកម្ពុជា ឬតាមការចុះផ្ទាល់របស់ខ្លួន ដែលនេះជាការរួមកម្លាំងមនុស្សធម៌ គាំទ្រ និងជាសក្ខីកម្មក្នុងការ ប្រើប្រាស់កម្លាំងសរុប ធនធានសរុប ដើម្បីជំនះលើគ្រប់បញ្ហាក្នុង សង្គម-ជាតិ ជាពិសេស ការជម្នះលើផលវិបាកនានាដែលបង្កដោយការប្រែប្រួលអាកាសធាតុ ហើយដែលនេះក៏ជាក្តីកង្វល់របស់ពិភពលោកទាំងមូល ។/

*ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជានៅគ្រប់លំដាប់ថ្នាក់ នៅតែបន្តការលះបង់ពេលវេលា កម្លាំងកាយចិត្ត ប្រកបដោយទឹកចិត្តមនុស្សធម៌ និងការទទួលខុសត្រូវខ្ពស់ ពុះពារជួយអ្នកងាយរងគ្រោះទាំងឡាយ*







# ឯកឧត្តម សាយ ឈុំ ណែនាំការងារមួយចំនួនក្នុងពិធីផ្ទេរតំណែង ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ



*ឯកឧត្តម **សាយ ឈុំ** អញ្ជើញជាអធិបតីដ៏ក្នុងពិធីផ្ទេរ តំណែងប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ*

នៅថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកឧត្តម **សាយ ឈុំ** ប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីផ្ទេរតំណែងប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ដែលបានប្រព្រឹត្តទៅនៅទីស្នាក់ការនៃគណបក្សរាជធានី។

ឯកឧត្តម **កែប ជុតិមា** សមាជិកគណៈកម្មាធិការកណ្ដាល ប្រធានគណៈកម្មាធិការគណបក្សរាជធានីដែលត្រូវបានគណៈអចិន្ត្រៃយ៍សម្រួលភារកិច្ចទៅទទួលមុខតំណែងថ្មី បានរាយការណ៍ជូនអង្គពិធីអំពីលទ្ធផលការងារសំខាន់ៗដែលគណបក្សរាជធានីសម្រេចបានក្នុងរយៈពេលដែលឯកឧត្តមបានដឹកនាំពីឆ្នាំ២០០៣-២០១៣និងទិសដៅការងារសំខាន់ៗចំពោះមុខដែលគណបក្សរាជធានីកំពុងអនុវត្ត។ ឯកឧត្តម **ប៉ា សុជាតិវង្ស** ប្រធានគណៈកម្មាធិការគណបក្សរាជធានីថ្មី បានសម្ដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅចំពោះគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ដែលបានផ្ដល់ជំនឿទុកចិត្ត និងតែងតាំងឯកឧត្តមជាប្រធានគណៈកម្មាធិការគណបក្សរាជធានី និងបានធ្វើការប្ដេជ្ញាចិត្តប្រឹងប្រែងអនុវត្តនូវតួនាទី និងភារកិច្ចរបស់ឯកឧត្តមឱ្យបានសម្រេច។

មានមតិទៅកាន់អង្គពិធីនាឱកាសនោះ ឯកឧត្តម **សាយ ឈុំ** បានពាំនាំនូវប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខ និងសព្ទសាធុរពរពីសំណាក់សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានគណបក្ស សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អនុប្រធានគណបក្ស និងសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានកិត្តិយសគណបក្សជូនដល់អង្គពិធី និងគណបក្សរាជធានី។

ឯកឧត្តម **សាយ ឈុំ** បានថ្លែងកត់សម្គាល់ថា ពិធីផ្ទេរតំណែងនៅថ្ងៃនេះ គឺស្របពេលដែលកម្ពុជាយើងបានដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃរដ្ឋសភានីតិកាលទី ៥ កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅនេះប្រកបដោយជោគជ័យ ហើយក្នុងនោះគណបក្សប្រជាជនកម្ពុជាយើងបានទទួល ៦៨ អាសនៈ លើ ១២៣ អាសនៈ ដែលជាសំឡេងគ្រប់គ្រាន់អាចរៀបចំក្បាលម៉ាស៊ីនចាត់តាំងរបស់រដ្ឋសភា និងបោះឆ្នោតផ្ដល់ការទុកចិត្តដល់រាជរដ្ឋាភិបាលថ្មីបានស្របតាមរដ្ឋធម្មនុញ្ញ។ ពេលនេះយើងកំពុងដំណើរការពិធីផ្ទេរតំណែងរវាងឯកឧត្តម **កែប ជុតិមា** ប្រធានគណៈកម្មាធិការគណបក្សរាជធានីដែលត្រូវចេញ និងឯកឧត្តម **ប៉ា សុជាតិវង្ស** ជាប្រធានគណៈកម្មាធិការគណបក្សចូលក្នុងបរិយាកាសសុទិដ្ឋិនិយម និងទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ចដែលគណបក្ស និងប្រជាជនបានប្រគល់ជូន។ ក្នុងនាមគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល និងក្នុងនាមឯកឧត្តមផ្ទាល់ ឯកឧត្តមបានថ្លែងអំណរគុណ និងអំណរសាទរចំពោះឯកឧត្តម **កែប ជុតិមា** ដែលក្នុងពេលទទួលតំណែងជាប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ បានយកអស់ពីកម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា និងកម្លាំងធនធាន ដើម្បីកសាងពង្រឹង និងពង្រីករាជធានីភ្នំពេញយើង ហើយទទួលបានជោគជ័យជាបន្តបន្ទាប់ ទាំងលើកិច្ចការបម្រើប្រជាជនក្នុងការងាររដ្ឋ ទាំងក្នុងការងារគណបក្ស។ ចំពោះការងារគណបក្ស ទាក់ទងទៅនឹងលទ្ធផលនៃការបោះឆ្នោត ឯកឧត្តមបានគូសបញ្ជាក់ថា គឺមិនមែនតែគណបក្សរាជធានីភ្នំពេញទេដែលមានសំឡេងក៏ដូចជាចំនួនអាសនៈថយចុះ គណបក្សនៅខេត្តមួយចំនួនទៀតក៏មានលក្ខណៈដូចរាជធានីភ្នំពេញនេះដែរ ហើយនេះគឺជារឿងធម្មតានៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅក្នុងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស។ ប៉ុន្តែគណបក្សយើងមិនអត្តនោម័តទេ គណបក្សចាត់ទុកនេះជាមេរៀន ជាបទពិសោធន៍របស់គណបក្ស ដែលយើងទាំងអស់គ្នាត្រូវតែខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គទាំងអស់ ដើម្បីកាត់បន្ថយភាពអសកម្មដែលប៉ះពាល់ទៅនឹងផលប្រយោជន៍ផ្ទាល់របស់ប្រជាជន ក្នុងគោលដៅដើម្បីលើកកម្ពស់ប្រជាប្រិយភាពរបស់គណបក្សសម្រាប់ការបោះឆ្នោតទាំងអស់នាពេលខាងមុខទៀត។ ឯកឧត្តម **សាយ ឈុំ** បានបន្តថា អ្វីដែលគណបក្សរាជធានីភ្នំពេញសម្រេចបាន គឺមិនអាចកាត់ផ្ដាច់បានពីការជួយឧបត្ថម្ភគាំទ្រ ទាំងស្មារតី និងសម្ភារៈរបស់ឯកឧត្តម អស់លោក លោកស្រី ជាថ្នាក់ដឹកនាំគណបក្សតាមបណ្ដាថ្នាក់ ក៏ដូចជាសមាជិក សមាជិកាគណបក្សប្រជាជនយើង ហើយជាពិសេស ការចូលរួមពីប្រជាជននៅក្នុងរាជធានីភ្នំពេញដែល ស្រឡាញ់សន្តិភាព និងយុត្តិធម៌។ ជាមួយនោះ ជ័យជម្នះនេះក៏មិនអាចកាត់ផ្ដាច់បានពីការជួយឧបត្ថម្ភយ៉ាងទាន់ពេលវេលា និងមានប្រសិទ្ធភាពពីក្រុមការងារថ្នាក់កណ្ដាលចុះជួយរាជធានីភ្នំពេញ ដែលមានសម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ជាប្រធាន ។ ឯកឧត្តមមានជំនឿថា ឯកឧត្តម **កែប ជុតិមា** ពិតជានឹងបន្តសម្រេចបានជោគជ័យក្នុងការបំពេញភារកិច្ចថ្មីដែលគណបក្ស និងប្រជាជនប្រគល់ជូន។ ទន្ទឹមនេះ ឯកឧត្តមបានរំឭក



*ឯកឧត្តម **សាយ ឈុំ** ប្រគល់ត្រាជូនឯកឧត្តម **ឃឹ សុជាតិវឌ្ឍ** ជាប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ បន្តពីឯកឧត្តម **កែប ជុតិមា** ដែលបានចេញទៅទទួលភារកិច្ចថ្មី*

ដល់គណបក្សរាជធានីភ្នំពេញត្រូវចងក្រងទុកជាប្រវត្តិនូវរាល់ស្នាដៃរបស់គណបក្សតាំងពីប្រធានគណបក្សដំបូងមកដើម្បីជាការយល់ដឹង ក៏ដូចជាការអប់រំដល់កូនចៅយើងជំនាន់នេះ និងជំនាន់តរៀងទៅផងដែរ ។

ក្នុងមតិផ្តាំផ្ញើដល់ឯកឧត្តម **ឃឹ សុជាតិវឌ្ឍ** និងគណបក្សរាជធានី ឯកឧត្តម **សាយ ឈុំ** បានសង្កត់ធ្ងន់លើចំណុចមួយចំនួនដូចខាងក្រោម:

ទី១.អំពីការងារខាងផ្លូវរដ្ឋ សូមយកចិត្តទុកដាក់ដល់ការពង្រឹង និងពង្រីកគ្រប់ការងារទាំងអស់ ដោយឈរលើមូលដ្ឋានដែលមានស្រាប់ ហើយនិងឈរលើគោលនយោបាយរបស់រាជរដ្ឋាភិបាលថ្មី ដែលដឹកនាំដោយសម្តេចតេជោ **ហ៊ុន សែន** ព្រមទាំងត្រូវឈរឱ្យបានរឹងមាំលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋាននានាដែលមានជាធរមាន ។ ចំពោះការងារគណបក្ស ក្នុងឋានៈជាអ្នកដឹកនាំដំបូងបង្អស់ត្រូវតែក្តាប់ឱ្យជាប់លក្ខន្តិកៈគណបក្ស កម្មវិធីនយោបាយរបស់គណបក្ស គោលការណ៍ គោលនយោបាយរបស់គណបក្ស របៀបរបបធ្វើការងាររបស់គណបក្ស ដែលត្រូវអនុវត្តជាប្រចាំនោះគឺរបបប្រជុំ របបសន្និបាត របបចុះមូលដ្ឋាន របបរៀនសូត្រ របបត្រួតពិនិត្យ និងរបបរាយការណសុំយោបល់ ។ ជាមួយនេះ ក្នុងនាមជាប្រធានគណបក្សត្រូវតែក្តាប់ឱ្យបានជាប់នូវគោលការណ៍ដឹកនាំមួយចំនួនជាអាទិ៍ គោលការណ៍សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ ហើយពេលសម្រេចកិច្ចការអ្វីក៏ដោយភាគតិចត្រូវតែគោរពភាគច្រើន ។

ទី២-ដឹកនាំត្រូវឈរលើមាគ៌ានយោបាយ ឈរលើមាគ៌ាសតិអារម្មណ៍ និងឈរលើមាគ៌ាចាត់តាំងរបស់គណបក្ស ។

ទី៣-ដឹកនាំត្រូវឈររឹងមាំលើសាមគ្គីភាព ឯកភាពផ្ទៃក្នុងគណបក្ស ក្នុងនោះត្រូវអនុវត្តឱ្យបានល្អនូវពាក្យស្លោកគណៈអចិន្ត្រៃយ៍គណបក្ស ត្រូវធ្វើជាស្នូលនៃការសាមគ្គីឱ្យគណៈកម្មាធិការគណបក្សរាជធានី គណៈកម្មាធិការគណបក្សរាជធានីត្រូវធ្វើជាស្នូលនៃការសាមគ្គីឱ្យគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក ហើយសាខាគណបក្សត្រូវធ្វើជាស្នូលនៃការសាមគ្គីឱ្យ សមាជិក សមាជិកាគណបក្សទាំងមូល ។ ក្នុងសភាពការណ៍បច្ចុប្បន្ននេះ បញ្ហាសាមគ្គីភាព ឯកភាពផ្ទៃក្នុងគណបក្ស មានសារៈសំខាន់ជាអាយុជីវិតរបស់គណបក្ស ។

ចំពោះការងារនយោបាយ និងសតិអារម្មណ៍នៅក្នុងដំណាក់កាលបច្ចុប្បន្ននេះ ឯកឧត្តមបានលើកឡើងនូវចំណុចមួយចំនួនគឺ :

-សូមបន្តឃោសនាឱ្យបានស៊ីជម្រៅអំពីភាពត្រឹមត្រូវនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃរដ្ឋសភានីតិកាលទី ៥ ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃរដ្ឋសភានីតិកាលទី ៥ បានប្រព្រឹត្តទៅត្រឹមត្រូវ និងទៀងទាត់តាមកាលកំណត់របស់រដ្ឋធម្មនុញ្ញ ។ ដំណើរការនៃការបោះឆ្នោតទាំងមូលបានប្រព្រឹត្តទៅយ៉ាងរលូន ដោយសុខសន្តិភាព គ្មានការគំរាមកំហែង គ្មានអំពើហិង្សា មានលក្ខណៈសេរី និងយុត្តិធម៌ ហើយត្រូវបានអង្គការជាតិ និងអន្តរជាតិជាច្រើនបានទទួលស្គាល់ ។

-បន្តឃោសនាឱ្យបានស៊ីជម្រៅអំពីភាពត្រឹមត្រូវ និងស្របច្បាប់នៃរដ្ឋសភានីតិកាលទី ៥ និងរាជរដ្ឋាភិបាលថ្មី ។ រដ្ឋសភាកោះប្រជុំដំបូងគឺក្នុងរយៈពេលមិនលើសពី ៦០ ថ្ងៃក្រោយពីការបោះឆ្នោត ដោយ**ព្រះមហាក្សត្រ** ព្រះអង្គបានកោះប្រជុំ ហើយព្រះអង្គលោកយាងទៅធ្វើជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតនៃការប្រជុំនេះផ្ទាល់ ។ ដូច្នេះ កិច្ចប្រជុំដំបូងរបស់រដ្ឋសភាបានប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ហើយការប្រជុំជាបន្តបន្ទាប់មកទៀតរបស់រដ្ឋសភាក៏បានដំណើរការយ៉ាងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ទោះបីជាគណបក្សប្រឆាំងមិនព្រមចូលរួមប្រជុំក្តី ។

-បន្តឃោសនាអប់រំ ដើម្បីឱ្យប្រជាជនយើងបានយល់ច្បាស់អំពីផលវិបាកនៃបាតុកម្មដែលដឹកនាំដោយគណបក្សប្រឆាំង ។ បាតុកម្មមិនមែនជាដំណោះស្រាយឡើយ មានតែការចរចាទេទើបជាដំណោះស្រាយពិតប្រាកដ ហើយបើខ្មែរមិនត្រូវគ្នាទេនោះ គ្មាននរណាមកត្រូវគ្នាជំនួសខ្មែរទេ ។

-គណបក្សយើងទទួលបានជោគជ័យក្នុងការបោះឆ្នោត ជាគណបក្សកាន់អំណាច ដូច្នេះយើងត្រូវខិតខំធ្វើជាស្នូលនៃការបង្រួបបង្រួមជាតិ ធ្វើយ៉ាងណាឱ្យជនរួមជាតិយើងទាំងអស់បានរួបរួមគ្នា ចៀសវាងកុំឱ្យការបោះឆ្នោតនេះរួចហើយវាក្លាយទៅជាការបែកបាក់ជាតិ ។

-បន្តធ្វើវេទិកាសាធារណៈ ដែលមិនមែនធ្វើតែក្នុងរាជធានីភ្នំពេញទេ គឺគណបក្សបានណែនាំទៅគ្រប់ខេត្តទាំងអស់បន្តធ្វើនៅតាមមូលដ្ឋាន ដើម្បីស្តាប់សំណូមពររបស់ប្រជាពលរដ្ឋ រួមចំណែកជួយដោះស្រាយជូនប្រជាពលរដ្ឋទៅតាមសមត្ថកិច្ច ទៅតាមលទ្ធភាពរបស់យើងតាមថ្នាក់តាមផ្នែក ហើយបើហួសពីសមត្ថភាពត្រូវស្នើឡើងតាមថ្នាក់មក គឺខិតខំធ្វើឱ្យអស់ពីលទ្ធភាពរបស់យើង ។

នៅចុងបញ្ចប់ ឯកឧត្តម **សាយ ឈុំ** បានអំពាវនាវដល់សមាជិក សមាជិកាគណបក្សរាជធានីទាំងអស់ សូមសាមគ្គីជាធ្លុងមួយជុំវិញគណៈកម្មាធិការគណបក្សរាជធានី ដែលមានឯកឧត្តម **ឃឹ សុជាតិវឌ្ឍ** ជាប្រធាន ដើម្បីជាគុណប្រយោជន៍ដ៏ឧត្តុង្គឧត្តមក្នុងការសម្រេចភារកិច្ចដែលគណបក្ស និងប្រជាជនប្រគល់ជូន ។/

# តុលាការយុត្តិធម៌អន្តរជាតិ

## បកស្រាយលើសាលដីកាឆ្នាំ ១៩៦២ ពាក់ព័ន្ធនឹងរឿងក្ដីប្រាសាទព្រះវិហារ

### –តំបន់ជុំវិញប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនអធិបតេយ្យនៃប្រទេសកម្ពុជា



*តុលាការយុត្តិធមិអន្តរជាតិដែលហៅកាត់ថា ICJ ( នៅទីក្រុងឡាអេនៃប្រទេសហុល្លង់) បានប្រកាសចេញនូវសាលដីការបស់ខ្លួនលើបណ្ដឹងសុំរបស់ព្រះរាជាណាចក្រកម្ពុជាឱ្យបកស្រាយលើសាលដីកាថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៦២ ពាក់ព័ន្ធនឹងរឿងក្ដីប្រាសាទព្រះវិហារ*

នៅវេលាម៉ោង ៤ រសៀល (ម៉ោងនៅប្រទេសកម្ពុជា) ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ តុលាការយុត្តិធមិអន្តរជាតិដែលហៅកាត់ថា ICJ (នៅទីក្រុងឡាអេនៃប្រទេសហុល្លង់) បានប្រកាសចេញនូវសាលដីការបស់ខ្លួនលើបណ្ដឹងសុំរបស់ព្រះរាជាណាចក្រកម្ពុជាឱ្យបកស្រាយលើសាលដីកាថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៦២ ពាក់ព័ន្ធនឹងរឿងក្ដីប្រាសាទព្រះវិហារ ។ ខ្លឹមសារនៃការបកស្រាយលើសាលក្រមនោះមានដូចតទៅគឺ :

១-ប្រកាសដោយសំឡេងឯកច្ឆន្ទថា តុលាការមានសមត្ថកិច្ចដោយផ្អែកតាមមាត្រា ៦០នៃលក្ខន្តិកៈរបស់ខ្លួនដើម្បីសម្រេចលើបណ្ដឹងសុំបកស្រាយសាលដីកាឆ្នាំ ១៩៦២ ដែលប្ដឹងសុំដោយព្រះរាជាណាចក្រកម្ពុជា ហើយទទួលស្គាល់ថា បណ្ដឹងសុំនេះអាចទទួលយកមកពិនិត្យដោះស្រាយបាន ។

២-ប្រកាសដោយសំឡេងឯកច្ឆន្ទថា ក្នុងក្របខណ្ឌនៃការបកស្រាយសាលដីកាចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៦២ តុលាការសម្រេចនៅក្នុងសាល-ដីកានេះថា ព្រះរាជាណាចក្រកម្ពុជាមានអធិបតេយ្យពេញលេញលើបូរណ-ភាពទឹកដីលើតំបន់ពយភ្នំ(Eperon / Promontory) នៃប្រាសាទព្រះវិហារ ដូចដែលមានកំណត់ក្នុងកថាខណ្ឌទី ៩ នៃសាលដីកានេះ ហើយជាបច្ច័យ តុលាការប្រកាសថា ព្រះរាជាណាចក្រថៃមានកាតព្វកិច្ចដកចេញពីទឹកដីនេះនូវគ្រប់កងកម្លាំងប្រដាប់អាវុធ ឬកងនគរបាល ឬអ្នកថែរក្សា ឬឆ្មាំយាមផ្សេងទៀតរបស់ថៃដែលបោះទីតាំងនៅក្នុងទឹកដីនោះ ។

ភ្លាមៗក្រោយពីតុលាការធ្វើការបកស្រាយសាលដីកាឆ្នាំ ១៩៦២ នោះរួចហើយ ឯកឧត្ដម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដែលបានដឹកនាំគណៈប្រតិភូទៅចូលរួមស្ដាប់ការប្រកាសសាលដីកាដោយផ្ទាល់នៅឯតុលាការទីក្រុងឡាអេ បានថ្លែងថា សាលដីកានេះមានលក្ខណៈល្អប្រសើរច្រើនសម្រាប់កម្ពុជាយើង។ ឯកឧត្ដម **ហោ ណាំហុង** បានថ្លែងថា ជាការគួរឱ្យកត់សម្គាល់គឺថា ការសម្រេចរបស់តុលាការយុត្តិធមិអន្តរជាតិជាការសម្រេចឯកច្ឆន្ទ គឺចៅក្រមទាំង ១៥ នាក់ ជាអ្នកធ្វើសេចក្ដីសម្រេចដោយឯកភាពគ្នាទាំងអស់។ ឯកឧត្ដម **ហោ ណាំហុង** បានបញ្ជាក់នូវចំណុចខ្លីៗដែលក្នុងនោះរួមមានទី ១-តុលាការបានទទួលស្គាល់ជាឯកច្ឆ័ន្ទថាផែនទីឧបសម្ព័ន្ធ ១ ដែលគូសដោយគណៈកម្មការចម្រុះបារាំង-សៀម ឆ្នាំ ១៩០៤ និងឆ្នាំ ១៩០៨ ជាផែនទីកំណត់ព្រំដែនកម្ពុជា-ថៃ នៅតំបន់ប្រាសាទព្រះវិហារ ហើយនេះគឺជាអ្វីដែលយើងចង់បាន ទី ២ -តុលា-ការបានអនុម័តជាឯកច្ឆ័ន្ទទាត់ចោលផែនទីឯកតោភាគី ដែលគណៈរដ្ឋមន្ត្រីថៃបានសម្រេចធ្វើឡើងនៅខែកក្កដា ឆ្នាំ ១៩៦២ ក្រោយពីសាលដីកានៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៦២ ទី ៣-តុលាការបានសម្រេចថា ផ្លូវឡើងទៅកាន់ប្រាសាទព្រះវិហារត្រូវធានាសេរីភាពឡើងទៅកាន់ប្រាសាទព្រះវិហារវិញ ហើយដោយត្រូវធ្វើដំណើរជាធម្មតាមិនមានអ្នកណាមួយមកហាមឃាត់នោះទេ ទី ៤-ដោយសារតុលាការកំណត់ថា ផែនទីឧបសម្ព័ន្ធ ១ កំណត់ព្រំដែនកម្ពុជា-ថៃ ហើយនោះ វាលឥន្ទ្រីយ៍នៅជិតប្រាសាទព្រះវិហារដែលថៃទាមទារនោះគឺស្ថិតនៅក្នុងទឹកដីនៃប្រទេសកម្ពុជាយើង និងទី ៥-វត្តកែវសិក្ខាគីរីស្វរៈ គឺស្ថិតនៅក្នុងទឹកដីនៃប្រទេសកម្ពុជាយើងដែរ។ ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** បានបញ្ជាក់ថាចំណុចទាំងអស់នេះជាសេចក្ដីសម្រេចរបស់តុលាការយុត្តិធមិអន្តរជាតិដែលភាគីទាំង ២កម្ពុជា-ថៃ ត្រូវតែអនុវត្ត។

នៅយប់ថ្ងៃទី ១១ ខែវិច្ឆិកា សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានធ្វើសេចក្ដីថ្លែងការណ៍ទាក់ទិនទៅនឹងសាលដីការបស់តុលាការយុត្តិធមិអន្តរជាតិលើបណ្ដឹងសុំរបស់កម្ពុជា ដោយសម្ដេចបានបញ្ជាក់ថា នេះជាជំហានទៅមុខដ៏មានសារៈសំខាន់ និងមានអត្ថន័យជាប្រវត្តិសាស្ត្រមួយទៀតនៅក្នុងការខិតខំរបស់រាជរដ្ឋាភិ-បាលកម្ពុជា សំដៅដោះស្រាយដោយសន្តិវិធី និងផ្អែកលើច្បាប់អន្តរជាតិ នូវវិវាទរវាងកម្ពុជា និងថៃលើបញ្ហាប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រាសាទនេះ ។ ជាពិសេសការ ដែលតុលាការយុត្តិធមិអន្តរជាតិយកផែនទីឧបសម្ព័ន្ធ ១ ខ្នាត ១/២00000 ដែលភាគីកម្ពុជាដាក់ជូនតុលាការនៅឆ្នាំ ១៩៦២ មកធ្វើជាសម្អាងក្នុងការបកស្រាយធ្វើសេចក្ដីសម្រេចរបស់ខ្លួន ពិតជានឹងផ្ដល់នូវភាពច្បាស់លាស់ដ៏សំខាន់បំផុតដល់ភាគីទាំងពីរសម្រាប់ការអនុវត្តបន្ត។ សម្ដេចតេជោ **ហ៊ុន សែន** ក៏បានបញ្ជាក់អំពីការប្ដេជ្ញាចិត្តរបស់កម្ពុជាក្នុងការប្រកាន់ខ្ជាប់នូវជំហររួម ដែលសម្ដេចក្នុងនាមជានាយករដ្ឋមន្ត្រីនៃព្រះរាជា

ណាចក្រកម្ពុជា និងលោកជំទាវ **យីងឡាក់ ស៊ីណាវ៉ាត់ត្រា** នាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិនៃព្រះរាជាណាចក្រថៃ ដែលបានឯកភាពកន្លងមកថា ទោះបីជាសាលដីកានៃតុលាការយុត្តិធម៌អន្តរជាតិនាថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ នេះ ចេញមកបែបណាក៏ដោយ ក៏ប្រទេសទាំងពីរត្រូវតែគោរពតាមសេចក្តីសម្រេចនេះ ហើយខិតខំថែរក្សាឱ្យខាងតែបាននូវមិត្តភាពរវាងប្រទេស និងប្រជាជនទាំងពីរ ព្រមទាំងសន្តិភាព និងស្ថិរភាព នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ រាជរដ្ឋាភិបាលកម្ពុជានឹងគោរព ព្រមទាំងអនុវត្តតាមស្មារតីនៃកិច្ចប្រជុំរបស់រដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរកម្ពុជា-ថៃ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលទាំងសងខាងបានឯកភាពគ្នាថានឹងបន្តកិច្ចពិភាក្សានៅក្នុងក្របខ័ណ្ឌនៃយន្តការដែលមានស្រាប់ ដើម្បីជំរុញអនុវត្តសាលដីការបស់តុលាការយុត្តិធម៌អន្តរជាតិ ដោយក្នុងនេះ រាជរដ្ឋាភិបាលទាំងសងខាងប្តេជ្ញាមិនធ្វើសកម្មភាពណាមួយដែលនាំឱ្យមានភាពតានតឹងរវាងប្រទេសទាំងពីរ ព្រមទាំងផ្តល់ការយកចិត្តទុកដាក់ជាពិសេសលើការរក្សា និងពង្រឹងពង្រីកទំនាក់ទំនងជាមិត្តភាព និងសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរ ចៀសវាងការប៉ះទង្គិចដល់ការធ្វើចរាចរទៅវិញទៅមករបស់ប្រជាជនទាំងសងខាង ការផ្លាស់ប្តូរពាណិជ្ជកម្ម និងការវិនិយោគ ការដឹកជញ្ជូន និងកិច្ចសហប្រតិបត្តិការផ្សេងៗទៀត ។ សម្តេចតេជោ **ហ៊ុន សែន** ក៏បានសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅជាទីបំផុតឧទ្ទិសថ្វាយ **ព្រះវររាជបិតាជាតិ ព្រះបរមរតនកោដ្ឋ សម្តេចព្រះនរោត្តម សីហនុ** ដែលព្រះអង្គបានបន្សល់នូវមរតកជាប្រវត្តិសាស្ត្រដ៏មហាថ្លៃថ្លា ដល់កូនចៅជំនាន់ក្រោយសម្រាប់ធ្វើជាសម្អាងបន្តដោះស្រាយបញ្ហាប្រាសាទព្រះវិហារនេះ ហើយដែលត្រូវបានតុលាការយុត្តិធម៌អន្តរជាតិយកមកធ្វើជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន ។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតថ្វាយព្រះករុណា សម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលជានិច្ចកាលព្រះអង្គតែងប្រទាននូវការគាំទ្រយ៉ាងពេញទំហឹងចំពោះរាជរដ្ឋាភិបាលនៅក្នុងរាល់ការខិតខំដើម្បីបុព្វហេតុនៃការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ សម្តេចតេជោ **ហ៊ុន សែន** ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រុមការងាររបស់រាជរដ្ឋាភិបាលនៅក្រោមការដឹកនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** ដែលបានខិតខំបូជាកម្លាំងចិត្ត កម្លាំងកាយ ប្រាជ្ញា និងស្មារតី ធ្វើការយ៉ាងសកម្មក្នុងរយៈពេលជាងពីរឆ្នាំកន្លងមក ដើម្បីបុព្វហេតុដ៏ថ្លៃថ្លាជាប្រវត្តិសាស្ត្រនេះ។ សម្តេចតេជោ **ហ៊ុន សែន** បានវាយតម្លៃខ្ពស់ និងសម្តែងការដឹងគុណចំពោះកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ ដែលបានរួមចំណែកដ៏ឧត្តុង្គឧត្តមក្នុងការការពារអធិបតេយ្យ បូរណភាពទឹកដី ចូលរួមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ទាំងជាសម្ភារៈ ហិរញ្ញវត្ថុ និងស្មារតីក្នុងបុព្វហេតុនៃកិច្ចការពារអធិបតេយ្យជាតិ។ ជាមួយគ្នានេះ សម្តេចតេជោ **ហ៊ុន សែន** ក៏បានអំពាវនាវដល់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលកំពុងបំពេញភារកិច្ចការពារព្រំដែន សូមបន្តប្រកាន់ការអត់ធ្មត់រក្សាស្ថានភាពឈរជើងនៅដដែល និងចៀសវាងសកម្មភាពទាំងឡាយណាដែលអាចបង្កភាពតានតឹង ឬការប៉ះទង្គិចជាយថាហេតុ ហើយទុកលទ្ធភាពជូនយន្តការនៃរាជរដ្ឋាភិបាលប្រទេសទាំងពីរ បន្តការពិភាក្សាគ្នា ដើម្បីជំរុញអនុវត្តសាលដីកានេះរបស់តុលាការយុត្តិធម៌អន្តរជាតិ ។ សម្តេចតេជោ **ហ៊ុន សែន** បានអំពាវនាវឱ្យបងប្អូនជនរួមជាតិទាំងអស់ បន្តរក្សាភាពស្ងប់ស្ងៀម ចូលរួមរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងប្រទេស ក៏ដូចជាបន្តរក្សា និងលើកកម្ពស់ស្មារតីនៃទំនាក់ទំនងជាអ្នកជិតខាងល្អ សាមគ្គីភាព មិត្តភាព ភាពសុខដុមរមនា និងកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធរវាងប្រទេស និងប្រជាជនទាំងពីរ កម្ពុជា-ថៃ ដើម្បីផលប្រយោជន៍រួមនៃប្រជាជាតិទាំងសងខាង ទាំងសម្រាប់រយៈពេលចំពោះមុខទាំងសម្រាប់រយៈពេលយូរអង្វែងទៅមុខទៀត ។



*លោកចៅក្រម និងក្រឡាបញ្ជីនៃតុលាការយុត្តិធម៌អន្តរជាតិ ICJ*

គួររំឭកថា ក្រោយពេលដែលតុលាការយុត្តិធម៌អន្តរជាតិប្រកាសសាលក្រមថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៦២ រាជរដ្ឋាភិបាលថៃតែងតែបដិសេធមិនគោរពតាម ។នៅពេលដែលកម្ពុជាទទួលបាននូវការដាក់ប្រាសាទព្រះវិហារទៅក្នុងបញ្ជីសម្បត្តិបេតិកភ័ណ្ឌពិភពលោកនាថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០៨ ក្រោមការដឹកនាំរបស់អតីតនាយករដ្ឋមន្ត្រី អាប់ភីស៊ិត ថៃបានបង្ហាញពីមហិច្ឆតារបស់ខ្លួនដោយការបញ្ចេញកម្លាំងយោធា។ ចាប់តាំងពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៨ ថៃបានបើកការឈ្លានពានផ្នែកយោធាជាច្រើនលើកច្រើនគ្រានៅតាមបណ្តោយព្រំដែនក្នុងតំបន់ប្រាសាទព្រះវិហារ ហើយបានរីករាលដាលដល់ទីតាំងខាងក្រៅនៃតំបន់ប្រាសាទព្រះវិហារ ធ្វើឱ្យតួប្រាសាទជាច្រើនកន្លែងទទួលរងការបែកបាក់ប្រេះស្រាំយ៉ាងធ្ងន់ធ្ងរបំផុត ។ ហេតុនេះហើយបានជាកម្ពុជាសម្រេចចិត្តស្នើសុំឱ្យតុលាការយុត្តិធម៌អន្តរជាតិធ្វើការសម្រេចដាក់ចេញនូវវិធានការរក្សាទុកជាបន្ទាន់មួយដើម្បីការពារ និងរក្សាសិទ្ធិរបស់កម្ពុជាលើទឹកដីរបស់ខ្លួន និងដើម្បីចៀសវាងកុំឱ្យវិវាទយោធានេះកាន់តែធ្ងន់ធ្ងរឡើងថែមទៀត ហើយក៏ដើម្បីអនុញ្ញាតឱ្យតុលាការធ្វើការកាត់ក្តីលើវិវាទនេះពោលគឺស្នើសុំឱ្យតុលាការយុត្តិធម៌អន្តរជាតិធ្វើការបកស្រាយលើសាលក្រមឆ្នាំ ១៩៦២ ។ តាមរយៈការបកស្រាយសាលក្រមនេះដែលធ្វើឡើងដោយតុលាការយុត្តិធម៌អន្តរជាតិថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ គឺបានបង្ហាញច្បាស់លាស់ហើយសម្រាប់ទាំងប្រជាជនកម្ពុជា ទាំងប្រជាជនថៃ ទាំងសហគមន៍អន្តរជាតិថា ប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនដីនៃអធិបតេយ្យរបស់កម្ពុជា ហើយកងកម្លាំងថៃត្រូវតែដកចេញទាំងអស់ពីតំបន់នោះ ។ នេះជាជោគជ័យថ្មីមួយទៀតដែលមានអត្ថន័យជាប្រវត្តិសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** ក្នុងការការពារអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា ។/

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៣ ឯកឧត្តម **ស ខេង** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **សុខ អាន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានសំណេះសំណាលជាមួយសិក្ខាកាមលោកគ្រូ អ្នកគ្រូនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រះវិហារយ៉ាឡាយ ដែលស្ថិតនៅក្នុងភូមិធម្មជាតិសម្តេចតេជោ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។

ឯកឧត្តម **ស ខេង** និងឯកឧត្តម **សុខ អាន** បានស្ងើចសរសើរដល់អាជ្ញាធរមូលដ្ឋានដែលបានខិតខំប្រឹងប្រែងធ្វើការអភិវឌ្ឍតំបន់ព្រំដែននេះ ឲ្យក្លាយជាតំបន់មួយមានការរីកចម្រើន ទោះបីក្រោមកាលៈទេសៈណា និងមានការខ្វះខាតយ៉ាងណាក្តី មិនតែប៉ុណ្ណោះបានគៀងគរឲ្យខេត្តយ៉ាឡាយប្រទេសវៀតណាមជួយបានអាគារមួយខ្នងព្រមទាំងបំពាក់សម្ភារៈជាច្រើន ។ នេះជាការខិតខំដើម្បីភាពរីកចម្រើនរបស់ប្រជាពលរដ្ឋក្នុងតំបន់ជាយដែន និងជាពិសេសបន្តទុកឲ្យកូនចៅជំនន់ក្រោយៗ ។ ឯកឧត្តម **ស ខេង** និងឯកឧត្តម **សុខ អាន** បានឧបត្ថម្ភមេគោចំនួន១០ក្បាល និងម៉ាស៊ីនគោយន្ត ព្រមទាំងថវិកាមួយចំនួនដល់មជ្ឈមណ្ឌល លោកគ្រូ អ្នកគ្រូ សិក្ខាកាមទាំងអស់ ដោយចំណាយអស់ថវិកាជាច្រើន ។



*ថ្ងៃទី១៧-១៨ខែវិច្ឆិកាឆ្នាំ២០១៣ឯកឧត្តមបណ្ឌិត**ខួន ញឹល**សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានរដ្ឋសភាស្តីទី អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ធំ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយជាអង្ករបស់រដ្ឋសភាដែលជាអំណោយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ផ្តល់ជូនដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ២០០៨ គ្រួសារ រស់នៅក្នុងស្រុកស្ទោង ក្រុងស្ទឹង-សែន និងស្រុកបារាយណ៍ ខេត្តកំពង់ធំ ដោយក្នុងមួយគ្រួសារៗទទួលបានអង្ករ ២៥ គីឡូក្រាម ។ ក្នុងឱកាសនោះដែរ ឯកឧត្តមបណ្ឌិត **ខួន ញឹល** បានឧបត្ថម្ភថវិកាផ្ទាល់របស់ឯកឧត្តមជូនដល់សាលាស្រុកស្ទោង ក្រុងស្ទឹងសែន និងស្រុកបារាយណ៍ ក្នុង ១ ស្រុក ចំនួន ២ លានរៀល ។ ប្រគេនបច្ច័យដល់ គណៈកម្មការវត្តសម្រាប់កសាងសមិទ្ធផលក្នុងឥន្ទវិសាល ហៅវត្តអ្នកវាំងក្នុងឃុំក្រឡៅ ស្រុកបារាយណ៍ចំនួន ១៥០០ ដុល្លារអាមេរិក ។ ប្រគេនចៅអធិការវត្តចំនួន ៣ វត្ត ក្នុង ១ វត្ត បច្ច័យ ១ លានរៀល ព្រមទាំងគ្រឿង បរិក្ខាសង្ឃមួយចំនួន ក្នុងនោះមានចៅអធិការវត្តឥន្ទវិសាល ហៅវត្តអ្នកវាំង ចៅអធិការវត្តឈើទាល ឃុំកំពង់ ចិនត្បូង ស្រុកស្ទោង និងចៅអធិការវត្តធម្មយុតិ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។*



*ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៣ លោកជំទាវ **ឃួន សុដារី** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាអនុប្រធានទី២រដ្ឋសភាបានផ្តួចផ្តើមធ្វើអង្គកឋិនទានសាមគ្គី ដើម្បីប្រមូលបច្ច័យបន្តការសាងសង់ព្រះវិហារ ថ្មី វត្តព្រែកទន្លាប់ ស្ថិតក្នុងស្រុកលើកដែក ខេត្តកណ្តាល ។*

*បច្ច័យដែលទទួលបានពីអង្គកឋិនទានសាមគ្គីនេះមានចំនួន ៥០.៤២២.៨០០ រៀល និង ៨៧៨ ដុល្លារ ព្រមទាំងទេយ្យទានជាច្រើនទៀត បានវេរប្រគេនព្រះចៅអធិការវត្ត និងលោកតាអាចារ្យគណៈកម្មការវត្តចាត់ចែងប្រើប្រាស់កសាងសំណង់ព្រះវិហារថ្មីបន្ត និងកសាងសមិទ្ធ-ផលនានាក្នុងវត្តព្រែកទន្លាប់ទៅតាមគន្លងប្រពៃណីព្រះពុទ្ធសាសនា សម្រាប់ពុទ្ធបរិស័ទគោរពបូជាក្នុងទីវត្តអារាម៕*

ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ២០១៣ លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច អ្នកតំណាងរាស្ត្រមណ្ឌលស្វាយរៀង រួមជាមួយពុទ្ធបរិស័ទទាំងឡាយ បានមូលមតិផ្តួចផ្តើមដង្ហែអង្គកឋិនទានដើម្បីប្រមូលបច្ច័យ និងទេយ្យទានសម្រាប់កសាងសមិទ្ធផលនានា និងវេរប្រគេនព្រះសង្ឃក្នុងវត្តចំនួនពីរ គឺវត្តព្រះវិហារសរសរ ១០០ និងវត្តសិរីសុន្ទរវង្ស ស្ថិតក្នុងសង្កាត់ក្រុងក្រចេះ ខេត្តក្រចេះ ។ បច្ច័យដែលវេរប្រគេនព្រះសង្ឃនាពេលនោះមានចំនួន ៤ ម៉ឺន ១ ពាន់ដុល្លារអាមេរិក ។



# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ឯកឧត្តម **ត្រាំ អ៊ីវតឹក** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសា-ធារណការ និងដឹកជញ្ជូន ព្រមទាំងសហការី បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និង នាំយកអំណោយសម្ភារៈបរិក្ខារ ថវិកា គ្រឿងឧបភោគបរិភោគ ជូនវីរយុទ្ធជនក្នុងអង្គភាពសម្ព័ន្ធមេត្រីភាព គឺវរៈសេនាតូចលេខ ៤១៥ នៃកងពលតូចថ្មើរជើងលេខ ៤១ នៅលើភ្នំច្រកជាំ( ព្រំដែនកម្ពុជា-ថៃ) ស្រុកអន្លង់វែង និងវរៈសេនាតូចលេខ ៤២៥ នៃកងពលតូចថ្មើរជើងលេខ ៤២ នៅសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។



*ថ្ងៃទី ១១ ខែវិច្ឆិកាឯកឧត្តម **នឹម ថូត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយស្រុកថ្មគោល ខេត្តបាត់ដំបង បានអញ្ជើញជួបសំណេះសំណាល និងផ្តល់អំណោយជូនជនចាស់ជរាក្រីក្រដែលមានអាយុចាប់ពី ៧០ ឆ្នាំចំនួន ៥៥ នាក់ នៅភូមិវាលទ្រាស្រុកថ្មគោល ។*



ថ្ងៃទី ៧ ខែវិច្ឆិកាឆ្នាំ ២០១៣ ឯកឧត្តម **ហ៊ុន ម៉ានី** តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** បានអញ្ជើញសួរសុខទុក្ខ និងនាំយកអំណោយមួយចំនួនរួមមាន ស្បៀង អាហារ ថវិកា និងសម្ភារៈប្រើប្រាស់ផ្តល់ជូនដល់កងទ័ពនៅសមរភូមិមុខ និងគ្រួសារកងទ័ពចំនួន ១.៧១៧ គ្រួសារនៅចំណុច ៣ គោលដៅដាច់ដោយឡែកពីគ្នា រួមមានកងពលតូចថ្មើរជើងលេខ ៤១ ចំនួន ២ គោលដៅ( វរសេនាតូច លេខ ៤១២ និងវរសេនាតូចលេខ ៤១១) និងមួយគោលដៅទៀតគឺអង្គភាពកងពលតូចថ្មើរជើងលេខ ៤២ ។





*នៅថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកឧត្តម **ម៉ម ប៊ុននាង** សមាជិកគណៈកម្មការទី ៩ នៃព្រឹទ្ធសភា លោកជំទាវ **ឌី ប៊ូរ៉ាស៊ី**ប្រធានគណៈកម្មការទី ៥ ព្រឹទ្ធសភា និងជាអនុប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី ៣ ( ខេត្តកណ្តាល) ឯកឧត្តម **ប្រាក់ ចំរើន** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី ៣ ប្រធានគណៈពង្រឹងមូលដ្ឋានឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល បានអញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ ព្រមទាំងនាំយកអំណោយចែកជូនដល់ប្រជាពលរដ្ឋចំនួន ១០១គ្រួសារ ដែលទទួលរងគ្រោះដោយទឹកជំនន់ នៅក្នុងឃុំកោះខ្សាច់ទន្លា ស្រុកស្អាង ខេត្តកណ្តាល ដែលក្នុង ១ គ្រួសារៗទទួលបានទទួលបានអង្ករ ២០ គីឡូក្រាម មី ១ កេស ទឹកត្រី ៣ ដប ទឹកស៊ីអ៊ីវ ៣ ដប ត្រីខ ៦ កំប៉ុង ប៊ីចេង ២ កញ្ចប់ និងថ្នាំពេទ្យ ១ កញ្ចប់ ។ ឆ្លៀតក្នុងឱកាសនោះ គណៈប្រតិភូបានប្រគេនទេយ្យទានដល់វត្តបទុមសាគរនូវអង្ករ ២០ គីឡូក្រាម មី ៥ កេស ទឹកស៊ីអ៊ីវ ២ យួរ ទឹកត្រី ២ យួរ ត្រីខ ២ យួរ និងបច្ច័យ ១០ ម៉ឺនរៀល ។*

ថ្ងៃទី ២១ ខែវិច្ឆិកា ឯកឧត្តម **ប៉ា សុជាតិវង្ស** ប្រធានគណៈកម្មាធិការគណបក្សរាជធានីអភិបាលរាជធានីភ្នំពេញ បានអញ្ជើញបើកការដ្ឋានស្ថាបនាផ្លូវវែងស្រេង ហៅផ្លូវចោមចៅ មានប្រវែងជាង ៦ គីឡូម៉ែត្រ ស្ថិតនៅសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ជាប់នឹងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ក្នុងគម្រោងទឹកប្រាក់ជាង ១០ លានដុល្លារអាមេរិក តាមរូបមន្ត BOT ដោយគ្រោងចំណាយរយៈពេល ១៤ ខែ និងវិនិយោគដោយក្រុមហ៊ុនថូលវេ( Tollway) ។ផ្លូវនេះនឹងពង្រីកដល់ទទឹង ២២ ម៉ែត្រ ដែលមានបីគន្លងទៅបីគន្លងមកស្ថាបនាជាផ្លូវបេតុងឆ្អឹងដែកកម្រាស់ ២ តឹក ។



# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច



ដំណាំស្រូវនៅកម្ពុជា កំពុងកើនឡើងទាំងបរិមាណ និងគុណភាព

**ទេសចរណ៍ ៩ ខែដើមឆ្នាំ ២០១៣ :**

ទេសចរអន្តរជាតិមកទស្សនាកម្ពុជាក្នុងខែកញ្ញា ឆ្នាំ ២០១៣ មានចំនួន ២៨៣ ៧៨៧ នាក់ កើនឡើង ១៦,៩% ធៀបនឹងខែ កញ្ញា ឆ្នាំ ២០១២ ។

ក្នុងរយៈពេល ៩ ខែដើមឆ្នាំ ២០១៣ នេះ មានចំនួន ៣ ០៥៧ ២១១ នាក់ កើនឡើង ១៨,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១២ ។ទីផ្សារទេសចរណ៍សំខាន់ៗមកកម្ពុជា ក្នុងអំឡុងពេលនេះមាន វៀតណាម ៦៤៤ ៨៨៩ នាក់ ចិន ៣៣៩ ៨៩៤ នាក់ កូរ៉េ ៣១៧ ៤៥៨ នាក់ ឡាវ ៣០២ ៤០៩ នាក់ ថៃ ១៦៣ ២៣៩ នាក់ ជប៉ុន ១៥០ ៣៤៧ នាក់ អាមេរិក ១៣២ ៧១៤ នាក់ បារាំង ៩៣ ៩៧៥ នាក់ អូស្ត្រាលី ៩២ ៥៩៣ នាក់ និង ម៉ាឡេស៊ី ៩១ ៣៤២ នាក់ ។

**វិនិយោគក្នុងវិស័យសំណង់ ៩ ខែដើមឆ្នាំ ២០១៣ :**

ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់បានឱ្យដឹងថាក្នុងរយៈពេល ៩ ខែដើមឆ្នាំនេះ ចំនួនទឹកប្រាក់វិនិយោគក្នុងវិស័យសំណង់បានកើនឡើង ២៤% ដល់ ២,២៧ ពាន់លានដុល្លារ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២។ គិតពីខែមករា ដល់ខែកញ្ញានេះ ក្រសួងបានអនុម័តគម្រោងចំនួន ១ ២៤២ គម្រោង ។

ដោយឡែកទេសចរកម្ពុជាចេញទៅក្រៅប្រទេសរយៈពេល ៩ ខែ ដើមឆ្នាំ ២០១៣ មានចំនួន ៦៤៤ ៣៩៣ នាក់ កើនឡើង ១០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១២ ។

**ការនាំចេញរបស់កម្ពុជាទៅទីផ្សារក្រៅប្រទេសរយៈពេល ១០ ខែ:**

យោងតាមទិន្នន័យរបស់ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ថា តម្លៃនៃការនាំចេញទៅកាន់ទីផ្សារក្រៅប្រទេសរបស់កម្ពុជារយៈពេល ១០ ខែនៃឆ្នាំ២០១៣ នេះ (មករា-តុលា) មានទឹកប្រាក់ប្រមាណ ៥,៨ ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើងជាង ៣០% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ ដែលមានត្រឹមតែប្រមាណ ៤,៤ ពាន់លានដុល្លារ ។

ផលិតផលដែលនាំចេញចម្បងរបស់កម្ពុជាគឺនៅតែជាផលិតផលកាត់-ដេរ ។នៅក្នុងចំណោមតម្លៃនាំចេញ រយៈពេល ១០ ខែនេះ តម្លៃនៃការនាំចេញផលិតផលសម្លៀកបំពាក់ និងវាយនភណ្ឌកាត់ដេរមានទឹកប្រាក់ចំនួន ៤,៧ ពាន់លានដុល្លារ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ មានចំនួន ៣,៨ ពាន់លានដុល្លារ ពោលគឺកើនឡើងជាង ២៤,៧% ។សហរដ្ឋអាមេរិក និងសហ-គមន៍អឺរ៉ុបនៅតែជាទីផ្សារធំរបស់កម្ពុជា ប៉ុន្តែនៅទីផ្សារផ្សេងទៀតដូចជា ចិន ជប៉ុន កូរ៉េ និងបណ្តានៅក្នុងអាស៊ានក៏សុទ្ធតែមានកំណើនគួរឱ្យកត់សម្គាល់ ។

ក្រៅពីផលិតផលកាត់ដេរ កម្ពុជានៅមានផលិតផលមួយចំនួនទៀតដែលរួមមានដូចជា កៅស៊ូ អង្ករ ជលផល ដំឡូងមី គ្រាប់ស្វាយចន្ទី ពោត សណ្តែកសត្វរស់ និងគ្រឿងសង្ហារិមជាដើម ។

នៅក្នុងរយៈពេល៩ខែនេះដែរបើធៀបនឹង៩ខែឆ្នាំ២០១២គឺការធានារ៉ាប់រងវិស្វកម្មមានកំណើន ៦០% អគ្គិភ័យកើន ៣០ % ធានារ៉ាប់រងផ្សេងៗកើន ១៥,១៥% យានយន្តកើន ៥ % ។

នៅក្នុងចំណោមសេវាកម្មធានារ៉ាប់រងទាំងនេះ សេវាកម្មដែលមានការទារសំណងខ្លាំងជាងគេគឺវិស្វកម្ម ដោយការទាមទារសំណងមានចំនួន ៣,២៣ លានដុល្លារ បន្ទាប់មកគឺយានយន្តដែលមានតម្លៃ ១,៩៥ លានដុល្លារ និងសុខ-ភាពចំនួន ១៨៦ លានដុល្លារ ។

ក្នុងរង្វង់ ៩ ខែនេះដែរ ក្រុមហ៊ុនធានារ៉ាប់រងទាំង ៦ ប្រមូលបានប្រាក់ធានារ៉ាប់រងសរុបចំនួន ៣១,៣ លានដុល្លារ គឺកើនឡើងប្រមាណ ២០% ។ ដោយឡែក ប្រាក់សំណងដែលគេទាមទារវិញនោះមានតម្លៃប្រមាណ ៨,៤៥ លានដុល្លារ ពោលគឺកើនឡើង១៦៧%ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំ២០១២ កន្លងទៅនេះ ។

នៅក្នុងឆ្នាំ ២០១៣ នេះ សេវាកម្មធានារ៉ាប់រងទូទៅនៅកម្ពុជាត្រូវបានគេអះអាងថា នឹងមានការកើនឡើងចំនួនប្រមាណ ២០% ។ នៅកម្ពុជា បច្ចុប្បន្នក្រៅពីក្រុមហ៊ុនធានារ៉ាប់រងទាំង ៦ កម្ពុជានៅមានក្រុមហ៊ុនធានារ៉ាប់រងជីវិតចំនួនបីផ្សេងទៀត ។

**ពាណិជ្ជកម្ម កម្ពុជា_ជប៉ុន រយៈពេល ៩ ខែ :**

អង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុនបានបញ្ជាក់ថា រយៈពេល ៩ ខែ ឆ្នាំ ២០១៣(មករា-កញ្ញា) កម្ពុជាបាននាំចេញទៅជប៉ុនមានតម្លៃប្រមាណ ៤៣២ លានដុល្លារអាមេរិក ពោលគឺមានការកើនឡើងប្រមាណ ៤៤,២ %បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ ។

ដោយឡែកទំហំនៃការនាំចេញរបស់ជប៉ុនមកកាន់ទីផ្សារកម្ពុជាវិញ មានតម្លៃសរុបប្រមាណ ១៥៩ លានដុល្លារ គឺមានការថយចុះ ៧,៩ % បើធៀបនឹងរយៈពេលដដែលកាលពីឆ្នាំ២០១២ ។

ទំហំនៃការនាំចេញរបស់កម្ពុជាចូលទៅទីផ្សារជប៉ុន បើធៀបនឹងបណ្តាប្រទេសផ្សេងនៅក្នុងអាស៊ានដូចកម្ពុជាដែរនោះ គឺកម្ពុជាមានទំហំធំជាងប្រទេសឡាវតែមួយប៉ុណ្ណោះ។ ឡាវនាំចេញទៅកាន់ទីផ្សារជប៉ុនមានចំនួនត្រឹម ៨៨ លានដុល្លារ ។សូម្បីតែប្រទេសមីយ៉ាន់ម៉ា បាននាំចេញទៅកាន់ទីផ្សារជប៉ុនមានទឹកប្រាក់រហូតដល់ទៅ ៤៩៧ លានដុល្លារ ។

ទំនិញរបស់កម្ពុជានាំចេញទៅកាន់ទីផ្សារជប៉ុនមានផលិតផលឧស្សាហ-កម្មកាត់ដេរ និងផលិតផលកសិកម្ម ដែលរួមមានដូចជាជលផលសមុទ្រ អង្ករ

ម្រេចជាដើម ។ ចំពោះទំនិញដែលកម្ពុជានាំចូលពីជប៉ុនមកវិញរួមមាន យានយន្ត គ្រឿងម៉ាស៊ីន គ្រឿងអេឡិចត្រូនិច ជាដើម ។

គួរបញ្ជាក់ថារយៈពេល៩ខែនៃឆ្នាំ ២០១២ កន្លងទៅ កម្ពុជានាំចេញទំនិញទៅជប៉ុនមានតម្លៃត្រឹមតែ ២៩៩,៥ លានដុល្លារ និង នាំចូលពីជប៉ុនមកវិញប្រមាណ ១៧៣ លានដុល្លារ ។

**ពាណិជ្ជកម្ម កម្ពុជា_អាមេរិក រយៈពេល ៩ ខែ :**

ការិយាល័យស្ថិតិពាណិជ្ជកម្មរបស់អាមេរិកបានបញ្ជាក់ថា នៅក្នុងរង្វង់ ៩ ខែឆ្នាំ ២០១៣(មករា-កញ្ញា) នេះ ប្រទេសកម្ពុជា និងអាមេរិកបានធ្វើពាណិជ្ជកម្មជាមួយគ្នានៅក្នុងទំហំទឹកប្រាក់សរុបចំនួន ២.២៦៥,៦ លានដុល្លារអាមេរិក ។

នៅក្នុងទំហំទឹកប្រាក់ពាណិជ្ជកម្មនេះ កម្ពុជានាំចេញទៅកាន់អាមេរិកមានទំហំប្រមាណ ២.០៩២,១ លានដុល្លារ ។ រីឯការទំនិញដែលកម្ពុជានាំចូលពីអាមេរិកមកវិញមានតម្លៃ ១៧៣,៥ លានដុល្លារ ។

ទំហំទឹកប្រាក់ដែលកម្ពុជានាំចេញទៅកាន់ទីផ្សារអាមេរិកបានកើនឡើង ៧៥,២លានដុល្លារ បើប្រៀបធៀបទឹងរយៈពេលដូចគ្នានាឆ្នាំ ២០១២ ។ រីឯទំនិញដែលកម្ពុជានាំចូលពីអាមេរិកមកវិញមានការថយចុះចំនួន ៦,៨ លានដុល្លារ ។

គួររំលឹកថា ក្នុងរយៈពេល ៩ ខែនៃឆ្នាំ ២០១២ ទំហំទឹកប្រាក់ដែលកម្ពុជានាំចេញទៅអាមេរិកមានតម្លៃ ២.០១៦,៩ លានដុល្លារ និង នាំចូលមកកម្ពុជាវិញមានតម្លៃប្រមាណ១៨០,៣ លានដុល្លារ ។

នៅក្នុងឆ្នាំ ២០១៣ នេះដែរ ធនាគារពិភពលោកបានព្យាករណ៍ថា កម្ពុជាអាចនឹងមានសមត្ថភាពនាំចេញមានតម្លៃរហូតដល់ទៅជិត ៧ ពាន់លានដុល្លារ ។ ដោយឡែកនៅឆ្នាំ២០១៤ នឹងកើនឡើងរហូតដល់ប្រមាណ ៧,៧ ពាន់លានដុល្លារ ។

**វិស័យមីក្រូហិរញ្ញវត្ថុនិងបំណុលរយៈពេល ៩ ខែ :**

សមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាបានបញ្ជាក់ថា គិតត្រឹមត្រីមាសទី ៣ ឆ្នាំ ២០១៣នេះ អ្នកដែលជាប់បំណុលស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់មានចំនួន ១,៤៩ លាននាក់ ។ ប៉ុន្តែអ្នកដែលដាក់ប្រាក់បញ្ញើវិញមានចំនួន ៨៨០.០០០ នាក់ ។

អ្នកដែលជំពាក់បំណុលស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងនេះ គឺបានទទួលឥណទានពីស្ថាប័នទាំងនេះសរុបជាទឹកប្រាក់ប្រមាណ ១,១៨ ពាន់លានដុល្លារអាមេរិក ពោលគឺមានការកើនឡើងប្រមាណ៣៣ភាគរយ បើធៀបនឹងពេញមួយឆ្នាំ ២០១២ កន្លងទៅដែលមានតម្លៃត្រឹម ៨៩០ លានដុល្លារនោះ ។

សម្រាប់អ្នកដែលដាក់ប្រាក់បញ្ញើទាំង ៨៨០.០០០ នាក់វិញ បានយកប្រាក់ទៅផ្ញើនៅបណ្តាស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងនេះសរុបប្រមាណ ៣៦៥ លានដុល្លារ គឺកើនឡើងប្រមាណ ៣០% ធៀបនឹងរយៈពេលពេញមួយឆ្នាំនៃឆ្នាំ ២០១២ ដែលប្រាក់បញ្ញើមានតម្លៃត្រឹម ២៨០ លានដុល្លារ ។

អត្រាការប្រាក់នៃអ្នកដែលយកប្រាក់ទៅដាក់បញ្ញើនៅស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងនេះមានតម្លៃប្រមាណជិត ១០% នៅក្នុងមួយឆ្នាំ ខណៈដែលអត្រាការប្រាក់នៃប្រាក់កម្ចីគឺមានប្រមាណ ១,៥% នៅក្នុងមួយខែ ឬ ១៨% នៅក្នុងមួយឆ្នាំ ។

ស្ថាប័នមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានចំនួនប្រមាណ ៣៧ តែជាសមាជិករបស់សមាគមមានចំនួន ៣៥ ហើយក្រៅពីនេះក៏មានអង្គការសមាគមមួយចំនួនក៏កំពុងតែដំណើការកម្មវិធីឥណទាននេះផងដែរ ។

ក្រៅពីស្ថាប័នមីក្រូហិរញ្ញវត្ថុ គិតមកដល់ពេលនេះ កម្ពុជាមានធនាគារពាណិជ្ជចំនួន ៣៤ និងធនាគារឯកទេសមួយចំនួនទៀតដែលកំពុងតែប្រតិបត្តិការអាជីវកម្មហិរញ្ញវត្ថុ ។

**វិស័យធានារ៉ាប់រងរយៈពេល ៩ ខែ :**

យោងតាមរបាយការណ៍របស់សមាគមធានារ៉ាប់រងទូទៅនៃកម្ពុជាបានបញ្ជាក់ថា រយៈពេល ៩ ខែ ឆ្នាំ ២០១៣ (មករា-កញ្ញា) ក្រុមហ៊ុនធានារ៉ាប់រងទាំង ៦ ដែលកំពុងដំណើរការនៅកម្ពុជាប្រមូលបានប្រាក់ធានារ៉ាប់រងទូទៅសរុបចំនួន ១០,២៨ លានដុល្លារអាមេរិក ។ បន្ទាប់មកគឺធានារ៉ាប់រងយានយន្តចំនួន ៥,៤៥ លានដុល្លារ ធានារ៉ាប់រងផ្សេងៗចំនួន ៤,៧៣ លានដុល្លារ ធានារ៉ាប់រងសុខភាពចំនួន ៤,៣១ លានដុល្លារ វិស្វកម្មចំនួន ៣,៦៧ លានដុល្លារ ធានារ៉ាប់រងគ្រោះថ្នាក់ផ្ទាល់ខ្លួនចំនួន ២,៣៤ លានដុល្លារ ។ ដោយឡែកសេវាកម្មធានារ៉ាប់រងដឹកជញ្ជូនតាមសមុទ្រគឺប្រមូលបានតែ៥៦៧.៤១៧ដុល្លារប៉ុណ្ណោះ ។

**អង្ករផ្កាម្លិះរបស់កម្ពុជាជាប់ចំណាត់លេខ១និងការនាំចេញអង្ករ :**

អង្ករផ្កាម្លិះរបស់កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ ១ នៅលើពិភពលោកប្រចាំឆ្នាំ២០១៣(Worlds Best Rice 2013) ក្នុងកម្មវិធីប្រកួតប្រជែងអង្កររសជាតិឆ្ងាញ់ប្រចាំឆ្នាំ ២០១៣ ( Annual The Rice Trader World Rice Conference 2013) នៅទីក្រុងហុងកុង ។ កម្មវិធីប្រកួតប្រជែងលើកទី ៥ នេះ បានចាប់ផ្តើមពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ។

គណៈប្រតិភូកម្ពុជាបាននាំយកគំរូអង្ករចំនួន ៦ ប្រភេទ ទៅចូលរួមប្រកួតប្រជែងរសជាតិអង្ករនៅទីក្រុងហុងកុង ។ កាលពីឆ្នាំ ២០១២ អង្ករផ្កាម្លិះរបស់កម្ពុជាក៏បានទទួលពានរង្វាន់អង្ករឆ្ងាញ់ម្តងហើយ នៅក្នុងការប្រកួតនៅកោះបាលីប្រទេសឥណ្ឌូណេស៊ី ។

សហព័ន្ធអ្នកនាំចេញអង្ករកម្ពុជាបានអះអាងថា អង្ករក្រអូបរបស់កម្ពុជាមាន ៣ ប្រភេទ ។ គឺទី ១.ផ្ការំដួល ឬ ផ្កាម្លិះ ទី ២.ផ្ការមៀត និងទី ៣.អង្ករក្រអូបប្រាំង( សែនក្រអូប ឬសែនប្រហើរជាដើម ) ។ ប៉ុន្តែអង្ករផ្កាម្លិះ ឬក៏ផ្ការំដួលជាប់លេខ ១ និងនាំមុខគេសម្រាប់អង្ករកម្ពុជាដែលត្រូវនាំចេញទៅក្រៅប្រទេស ។

យោងតាមរបាយការណ៍របស់សហព័ន្ធអ្នកនាំចេញអង្ករកម្ពុជា បានបង្ហាញពីបរិមាណអង្ករកម្ពុជាដែលបាននាំចេញទៅក្រៅប្រទេសរួមមាន : ឆ្នាំ ២០០៩ មានចំនួន ១២.៦១៣ តោន ឆ្នាំ ២០១០ ចំនួន ១០៥.២៥៩ តោន ឆ្នាំ ២០១១ ចំនួន ២០១.៨៩៩ តោន និងឆ្នាំ២០១២ មានចំនួន ២០៥.៧១៧ តោន ។

របាយការណ៍ដដែលបញ្ជាក់ថា គិតត្រឹមរយៈពេល ១០ ខែ ក្នុងឆ្នាំ ២០១៣ នេះ កម្ពុជាបាននាំចេញអង្ករទៅក្រៅប្រទេសចំនួនប្រមាណ ៣០ ម៉ឺនតោន ដែលកើនឡើង ១០០% បើធៀបនឹងរយៈពេល ១០ ខែ កាលពី ឆ្នាំ ២០១២ ។

សម្រាប់នៅឆ្នាំ ២០១៣នេះ សហព័ន្ធអ្នកនាំចេញអង្ករកម្ពុជាបានប៉ាន់ស្មានថា អង្ករកម្ពុជាអាចនាំចេញទៅក្រៅប្រទេសបានចំនួន ៤៥ ម៉ឺនតោន ។ អង្ករប្រភេទលេខ ១ ពិសេសអង្ករផ្កាម្លិះរបស់កម្ពុជាលក់ក្នុងទីផ្សារអន្តរជាតិ តម្លៃចន្លោះពី ៩១០ ទៅ ៩២០ ដុល្លារអាមេរិក ក្នុងមួយតោន ។/

# ថវិកាជាតិ ឆ្នាំ ២០១៤ ជាឧបករណ៍គោលនយោបាយ សំខាន់បំផុត ដែលឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន

នៅថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានបើកសម័យប្រជុំរបស់ខ្លួន ដើម្បីពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ និងពិភាក្សាអនុម័តលើការបង្កើតក្រសួងចំនួន ៣ គឺក្រសួងមុខងារសាធារណៈ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងថាមពល និងរ៉ែ។ សម័យប្រជុំបានប្រព្រឹត្តទៅក្រោមអធិបតីភាពសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា។ ក្រោយពីការពិភាក្សាយ៉ាងម៉ត់ចត់រួចមក អង្គប្រជុំបានអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ និងអនុម័តលើការបង្កើតក្រសួងទាំង ៣ ដោយមានសំឡេងគាំទ្រ ៦៦ លើ ៦៦ សំឡេង។



រដ្ឋសភាប្រជុំ ពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ និងពិភាក្សាអនុម័តលើការបង្កើតក្រសួងចំនួន ៣ គឺក្រសួងមុខងារសាធារណៈ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងថាមពល និងរ៉ែ

ថវិកាជាតិឆ្នាំ ២០១៤ គឺជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់បំផុតសម្រាប់ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជនដែលបានស្តែងឡើងតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ ពិសេស តាមរយៈការជំរុញអនុវត្តនូវ "គោលដៅជាយុទ្ធសាស្ត្រ ៤ " និង "វិស័យអាទិភាព ៤ " នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣។ ថវិកាឆ្នាំ ២០១៤ ក៏បានឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និងមុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សានូវស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម បន្តពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ បន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងធានានូវភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅជាសារវ័ន្តនៃការទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ៧% និងការកាត់បន្ថយភាពក្រីក្រក្នុងអត្រា ១% ក្នុង ១ ឆ្នាំ ក៏ដូចជាក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ និងកំណែទម្រង់លើគ្រប់វិស័យឱ្យកាន់តែស៊ីជម្រៅ និងឱ្យមានលទ្ធភាពជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការផ្លាស់ប្តូរជារចនាសម្ព័ន្ធនៃសេដ្ឋកិច្ចកម្ពុជាផង និងឆន្ទៈរបស់ប្រជាជនផង ព្រមទាំងដើម្បីពង្រីក និងពង្រឹងមូលដ្ឋានសម្រាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសម្រាប់រយៈពេលវែងផងដែរ។

តាមច្បាប់ដែលត្រូវបានអនុម័ត ហើយនេះបានបង្ហាញឱ្យឃើញថារាជរដ្ឋាភិបាលនឹងត្រូវការថវិកាចំណាយសរុបចំនួន ១៤ ១៦៧ ៤៤៤,៣ លានរៀល ស្មើនឹង ២០,៦៥ នៃផ.ស.ស គឺកើនឡើង ១៣,១% ត្រូវជា ០,២៨% នៃ ផ.ស.ស ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ។ ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានបែងចែកទៅតាមវិស័យធំៗ គឺចំណាយវិស័យសង្គមកិច្ចមានទំហំ ៤,៦១% នៃផ.ស.ស កើនឡើង ១៥,៣% ដែលក្នុងនោះក្រសួងសុខាភិបាលត្រូវបានគ្រោងចំនួន ៩៧៧ ៦៥១,៣ លានរៀល មានសមាមាត្រស្មើនឹង ១១,៨% នៃចំណាយចរន្តថវិកាថ្នាក់ជាតិកើនឡើងឆ្នាំមុន ៨,៤%។ ក្រសួងអប់រំយុវជន និង-កីឡាត្រូវបានគ្រោងចំនួន ១ ៣៤២ ០៤៩ លានរៀល មានសមាមាត្រ ស្មើនឹង ១៦,២%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ មានកំណើន ១៩,៩%។ ក្រសួងសង្គមកិច្ចអតីតយុវជន និងយុវនិតីសម្បទាត្រូវបានគ្រោងចំនួន ៥ ៦៥២ ៥៨៤ លានរៀលមានសមាមាត្រស្មើ នឹង ៦,៨%នៃចំណាយចរន្តថវិកាថ្នាក់ជាតិមានកំណើន ៣៧,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣។

ចំណាយវិស័យសេដ្ឋកិច្ចមានទំហំ១,០២%នៃផ.ស.សកើនឡើង ១៨,១% ធៀបនឹងច្បាប់ហិញ្ញវត្ថុឆ្នាំ ២០១៣ ក្នុងនោះក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទត្រូវបានគ្រោងចំនួន ១៣៤ ២១៩ លានរៀលមានសមាមាត្រ ១,៦% នៃចំណាយចរន្តថវិការថ្នាក់ជាតិ និងមានកំណើន ១០,៧% ក្រសួងធនធានទឹក និងឧតុនិយម ត្រូវបានគ្រោងចំនួន ៦១ ៤១២,៤លានរៀលមានសមាមាត្រ០,៧%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ និងមានកំណើន ៦% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០១៣។

ចំណាយវិស័យរដ្ឋបាលទូទៅមានទំហំ ១,៦៣% នៃផ.ស.ស កើនឡើង ១,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣។ ដោយឡែក ចំណាយវិស័យការពារជាតិ និងសន្តិសុខមានទំហំ ២,៧៣% នៃផ.ស.ស កើនឡើង ១៧% ធៀបនឹងឆ្នាំ ២០១៣ ក្នុងនោះចំណាយបន្ទុកបុគ្គលិកមានចំនួន ១ ៣៥៩ ៦៩០ លានរៀល ស្មើនឹង ៧២,៦% នៃចំណាយសរុបរបស់ក្រសួង និងមានកំណើនប្រមាណ ១៧,៩% ធៀបនឹងឆ្នាំមុន។ រាជរដ្ឋាភិបាលកម្ពុជាក៏បានធ្វើការគូសបញ្ជាក់ថាកំណើនក្នុងវិស័យការពារជាតិ និងសន្តិសុខមានលក្ខណៈជាចំណាយសង្គមកិច្ចច្រើនជាង គឺមិនមែនជាការបង្កើនចំណាយយោធូបករណ៍នោះទេ ។ យោងតាមច្បាប់ដដែលនេះបានឱ្យដឹងថា តម្រូវការចំណាយខាងលើ គឺធ្វើឡើងដើម្បីផលប្រយោជន៍សង្គមជាតិ

និងលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដោយបានដំឡើងប្រាក់បៀវត្សមូលដ្ឋានប្រចាំខែជូនមន្ត្រីរាជការស៊ីវិលចំនួន ៤០ ០០០ រៀល សម្រាប់ក្របខណ្ឌប្រភេទ"ក" និងចំនួន ៨០ ០០០ រៀល សម្រាប់ក្របខណ្ឌប្រភេទ"ខ""គ"និង"ឃ" ដំឡើងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃរបស់កងកម្លាំងប្រដាប់អាវុធពីចំនួន ៤០ ០០០ រៀល ជូនគ្រូចូលនិវត្តន៍ដែលបន្តបម្រើការងារជាគ្រូជាប់កិច្ចសន្យា និងដំឡើងប្រាក់ហូបប្រចាំថ្ងៃរបស់កងកម្លាំងប្រដាប់អាវុធពីចំនួន ១៥០០ រៀល ក្នុង ១ ថ្ងៃ ទៅចំនួន ៤០០០ រៀលក្នុង ១ ថ្ងៃ ព្រមទាំងបានផ្តល់ប្រាក់ហូបដល់អង្គការសម្រាប់ការហ្វឹកហាត់របស់យោធាចំនួន ៣០០០ រៀលក្នុង ១ ថ្ងៃ។ គោលនយោបាយថ្មីនេះនឹងធ្វើឱ្យប្រាក់បៀវត្សប្រចាំខែទាបបំផុតកើនពី ៣២០ ០០០ រៀល ដល់ ៤២០ ០០០ រៀល។ ចំណាយបន្ទុកបុគ្គលិក កើនពី ៤២% ដល់ ៤៥,៧៥%នៃចំណាយចរន្តសរុប ស្មើនឹង ៥,៥១% នៃផ.ស.ស។

ដើម្បីបំពេញតាមគោលនយោបាយខាងលើរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភានេះ ប្តេជ្ញាបន្តពង្រឹង និងពង្រីកការប្រមូលចំណូលបន្ថែម នៅក្នុងផ្នែកគយ ពន្ធដារ និងចំណូលមិនមែនសារពើពន្ធដោយម៉ឺងម៉ាត់ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ចំណូលក្នុងប្រទេសនៃថវិការដ្ឋសរុបសម្រាប់ឆ្នាំ ២០១៤ ត្រូវសម្រេចឱ្យបានចំនួន ១០ ៥១៧ ៤៤៩,៣ លានរៀល កើនឡើង ១៧% ធៀបនឹងឆ្នាំមុន។

យោងតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ នេះក៏បានឱ្យដឹងដែរថា ថវិកានេះត្រូវបានរៀបចំឡើងក្នុងគោលដៅលើវិស័យអាទិភាព ៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ គឺការអភិវឌ្ឍធនធានមនុស្ស បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដោយផ្តោតជាពិសេសលើយុវជន ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការកែសម្រួលពាណិជ្ជកម្មបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា បន្តអភិវឌ្ឍវិស័យកសិកម្ម សំដៅជំរុញកំណើតសេដ្ឋកិច្ចកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ តាមរយៈការបង្កើនផលិតភាពទំនើបកម្មកសិកម្ម ឧស្សាហូបនីយកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម និងការពង្រឹងអភិបាលកិច្ចសមត្ថភាពនៃស្ថាប័នរដ្ឋសំដៅបង្កើនប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈ បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការវិនិយោគ និងធុរកិច្ច ពិសេសការកែលម្អបរិស្ថានវិនិយោគ តាមរយៈការកាត់បន្ថយថ្លៃដើម និងរបាំងធុរកិច្ច។

គួរបញ្ជាក់ថា រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយអនុវត្តយ៉ាងខ្ជាប់ខ្ជួនការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្រប បានធ្វើឱ្យកម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់រយៈពេលវែង ទោះបីជាមានផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក ក៏ដូចជាគ្រោះធម្មជាតិជាបន្តបន្ទាប់ក៏ដោយ។ ជាក់ស្តែង ក្នុងឆ្នាំ ២០០៩ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនវិជ្ជមាន គឺ ០,១% ក្នុងឆ្នាំ ២០១០ មានកំណើន ៦% ក្នុងឆ្នាំ



២០១១ មានកំណើន ៧,១% ក្នុងឆ្នាំ ២០១២ សម្រេចបាន ៧,៣% ក្នុងឆ្នាំ ២០១៣ កំណើនសេដ្ឋកិច្ចកម្ពុជាអាចនឹងសម្រេចបាន ៧,៦%។ តាមការប៉ាន់ស្មានកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១៤ អាចនឹងបន្តសម្រេចបានក្នុងរង្វង់ ៧%។

ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១៤ ត្រូវបានកំណត់ជាសូចនាករសំខាន់ៗដូចតទៅគឺ :-កំណើនសេដ្ឋកិច្ចតាមថ្លៃថេរ នឹងសម្រេចបានក្នុងរង្វង់ ៧% ធ្វើឱ្យផលិតផលក្នុងស្រុកសរុបគិតជាប្រាក់តាមថ្លៃបច្ចុប្បន្នមានចំនួន ៦៨ ៦១៩ ០០០ លានរៀល ដែលត្រូវជាប្រមាណ ១៦ ៩៤៣ លានដុល្លារអាមេរិក។ ដូច្នេះនៅឆ្នាំ ២០១៤ ផ.ស.ស សម្រាប់មនុស្សម្នាក់អាចនឹងឡើងដល់ ១ ១៣៩ ដុល្លារអាមេរិក ហើយធ្វើឱ្យកម្ពុជាអាចនឹងចេញផុតពីចំណាត់ថ្នាក់ជាប្រទេសមានចំណូលទាប ក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលឆាប់ៗខាងមុខ។-អតិផរណានឹងត្រូវបានរក្សាឱ្យស្ថិតក្នុងរង្វង់ ៣,៥% ដោយរាជរដ្ឋាភិបាល និងបន្តអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុសមស្រប និងប្រុងប្រយ័ត្ន ។-អត្រាប្តូរ ប្រាក់រៀល-ដុល្លារអាមេរិក នឹងត្រូវបានរក្សាឱ្យស្ថិតក្នុងរង្វង់ ៤០៥០ រៀល ១ ដុល្លារអាមេរិក។-ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ក្រៅប្រទេសនឹងត្រូវបានកាត់បន្ថយពី -៩,៥% នៃផ.ស.ស ក្នុងឆ្នាំ ២០១៣ មកត្រឹម -៩,៣% ក្នុងឆ្នាំ ២០១៤ ដោយសារការកើនឡើងនៃការនាំចេញ ជាពិសេសកំណើននៃការនាំចេញទំនិញពីវិស័យកសិកម្ម និងវិស័យអេឡិចត្រូនិក។

រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភាក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយភាពម៉ឺងម៉ាត់ និងការប្តេជ្ញាចិត្តខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** ពិតជាបន្តទទួលបានជោគជ័យថ្មីៗធំធេងថែមទៀត នៅក្នុងឆ្នាំ ២០១៤ និងបណ្តាឆ្នាំក្រោយៗទៀត ដោយរក្សាបាននូវស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាពសង្គម រក្សាបាននូវអធិបតេយ្យបូរណភាពទឹកដី រក្សាបានស្ថិរភាពហិរញ្ញវត្ថុ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជំនះបាននូវផលវិបាកនៃវិបត្តិកលយុគសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកល វិបត្តិគ្រោះទឹកជំនន់ ធ្វើឱ្យប្រទេស ជាតិមានការអភិវឌ្ឍ ធ្វើឱ្យប្រជាជនរស់នៅប្រកបដោយសុភមង្គល និងភាពសុខដុមរមនាតរៀងទៅ។ ហើយពិតប្រាកដណាស់ថា អ្វីៗគ្រប់យ៉ាង យើងនឹងសម្រេចបាន ដោយត្រូវបន្តអនុ-វត្តនូវកំណែទម្រង់គ្រប់ជ្រុងជ្រោយនិងស៊ីជម្រៅប្រកបដោយប្រសិទ្ធភាព។/

# សេវាដឹកជញ្ជូនតាមកំពង់ផែកាន់តែមានភាពមមាញឹក បើប្រៀបធៀបនឹងឆ្នាំមុន





*សកម្មភាពផ្ទេរ និងលើកដាក់ទំនិញនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ*

នៅពេលដែលវិបត្តិសេដ្ឋកិច្ចពិភពលោកបានធូរស្រាលហើយ សេដ្ឋកិច្ចនៅប្រទេសកម្ពុជាមានកំណើនជាង ៧% ក្នុងឆ្នាំ ២០១៣ នេះ បានធ្វើឱ្យទំនិញឆ្លងកាត់តាមកំពង់ផែស្វយ័តក្រុងភ្នំពេញ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុមានការកើនយ៉ាងខ្លាំង បើធៀបរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ ។

តាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មបានបង្ហាញថា ទំហំពាណិជ្ជកម្មរបស់កម្ពុជានៅក្នុងរយៈពេល ៩ ខែដំបូងនៃឆ្នាំ ២០១៣ នេះ មានទឹកប្រាក់ប្រមាណ ១១,៨៤ ពាន់លានដុល្លារអាមេរិក បានកើនឡើង ២០% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនដែលមានប្រមាណ ៩,៨៨ ពាន់ លានដុល្លារអាមេរិក ក្នុងនោះការនាំចេញរបស់កម្ពុជាពីខែមករា ដល់ខែកញ្ញា ឆ្នាំ ២០១៣ មានទំហំទឹកប្រាក់ប្រមាណ ៥,១៧ ពាន់លាន ដុល្លារអាមេរិក កើនឡើង ២៨% រីឯការនាំចូលវិញមានប្រមាណ ៦,៦៥ ពាន់លានដុល្លារអាមេរិក កើនឡើង ១៥,៨៣% ។

ដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជារួមមាន សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ចិន ជប៉ុន កូរ៉េខាងត្បូង និងប្រទេសជិតខាងដូចជា វៀតណាម និងថៃជាដើម ។ ដោយឡែកការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើងមានតម្លៃជាទឹកប្រាក់ ៤,១៩ ពាន់លានដុល្លារ កើនឡើងប្រមាណ ២២% ។

ឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌគឺជាក្បាលម៉ាស៊ីនសម្រាប់រុញច្រានកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាអស់ជាច្រើនឆ្នាំមកហើយ ។ កាលពីឆ្នាំ ២០១២ កម្ពុជាបាននាំចេញផលិតផលវាយនភ័ណ្ឌសម្លៀកបំពាក់ និងស្បែកជើងប្រមាណ ៤,៦១ ពាន់លានដុល្លារ ។ បច្ចុប្បន្នកម្ពុជាមានរោងចក្រកាត់ដេរប្រមាណ ៤៥០ រោងចក្រ រោងចក្រម៉ៅការបន្តប្រមាណ ១២០ និងរោងចក្រស្បែកជើង ៤៥ ដែលស្រូបយកកម្លាំងពលកម្មប្រមាណជា ៦០ ម៉ឺននាក់ ក្នុងនោះភាគច្រើនជាស្ត្រី ។

អ្នកស្រាវជ្រាវជាន់ខ្ពស់ប្រចាំវិទ្យាស្ថានកម្ពុជាដើម្បីកិច្ចសហការ និងការអភិវឌ្ឍបានឱ្យដឹងថា កំណើននៃការនាំចេញផលិតផលកាត់ដេរ ដែលជាក្បាលម៉ាស៊ីនសម្រាប់សេដ្ឋកិច្ចកម្ពុជា បានឆ្លុះបញ្ចាំងពីស្ថានភាពរឹងមាំនៃសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍មួយនេះ ។ប៉ុន្តែទទ្ទឹមនេះ ក្រុមហ៊ុនកាត់ដេរគួរបន្ថែមការវិនិយោគក្នុងការបង្កើតផលិតផលដែលមានគុណភាពខ្ពស់ ដើម្បីទទួលបានតម្លៃបន្ថែមទៅលើផលិតផល សំដៅដោះស្រាយបញ្ហាប្រឈមដែលទាក់ទងនឹងការកើនឡើងនៃប្រាក់ឈ្នួលកម្មករ ហើយគួរតែផ្លាស់ប្ដូរពីការផលិតសម្លៀកបំពាក់ធម្មតាទៅបង្កើតផលិតផល ដែលមានដំណើរការផលិតស្មុគស្មាញជាងនេះ ដូចជាផលិតអាវធំ ឬអាវដែលមានប៉ាក់ឱ្យជាដើម ដែលអាចទទួលបានតម្លៃខ្ពស់ជាង ។

បច្ចុប្បន្នការដឹកជញ្ជូនទំនិញចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសដទៃទៀត គឺមានការពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើកំពង់ផែដើម្បីលើកដាក់ទំនិញ និងផ្ទេរទំនិញដាក់កប៉ាល់ដឹកទៅកាន់ប្រទេសផ្សេងទៀត ពីព្រោះការដឹកជញ្ជូនទំនិញតាមកប៉ាល់ ឬតាមផ្លូវសមុទ្រត្រូវបានអ្នកជំនាញ និយាយថាមានតម្លៃថោកជាងការដឹកជញ្ជូនទំនិញតាមផ្លូវគោក ។

តាមទិន្នន័យចុងក្រោយដែលទទួលបានពីកំពង់ផែស្វយ័តភ្នំពេញ (PPAP) បានបង្ហាញថា ការដឹកជញ្ជូនទំនិញឆ្លងកាត់តាមកំពង់ផែនេះ ដែលជាកំពង់ផែរដ្ឋធំទីពីរ បន្ទាប់ពីកំពង់ផែសមុទ្រទឹកជ្រៅក្រុងព្រះសីហនុនោះ បានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេល ៩ ខែដំបូង ក្នុងឆ្នាំនេះ ពោលគឺកើនប្រមាណ ២២% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ ការទទួលបានអត្រាកំណើននេះ ដោយសារការកើនឡើងសកម្មភាពនាំចេញ និងនាំចូលសម្លៀកបំពាក់ សម្ភារៈកសិកម្ម និងសម្ភារៈសំណង់ ។ ទិន្នន័យដដែលបានបង្ហាញទៀតថា នៅក្នុងរយៈពេល ៩ ខែ ដំបូងនៅឆ្នាំ ២០១៣ នេះ ចំនួនកុងតឺន័រប្រហែល ៨៥ ១៨៨ ទូ (TEU) ត្រូវបាននាំចេញ និងនាំចូលតាមរយៈកំពង់ផែនេះ បើធៀប

នឹងកុងតឺន័រចំនួន ៧០ ០៧៩ ទូ នៅក្នុង រយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

ការកើនឡើងនេះគឺជាការឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចក្នុងរយៈពេលនេះ ដោយសារតែកំណើនក្នុងការនាំចេញសម្លៀកបំពាក់ និងផលិតផលកសិកម្ម ហើយចំណតផែថ្មីដែលទើបនឹងបើកដំណើរការក៏កំពុងដើរតួនាទីដ៏សំខាន់ក្នុងការឆ្លើយតបទៅនឹងកំណើនចរាចរណ៍ទំនិញ ដែលភាគច្រើននៃផលិតផលនាំចូលតាមរយៈកំពង់ផែ PPAP គឺជាសម្ភារៈសំណង់ ទំនិញប្រើប្រាស់វត្ថុធាតុដើមក្នុងវិស័យកាត់ដេរ ផលិតផលអេឡិចត្រូនិក រថយន្តដែលនាំចូលមកពីប្រទេសចិន និងប្រទេសក្នុងតំបន់អាស៊ានមួយចំនួន ចំណែកឯផលិតផលនាំចេញភាគច្រើនជាផលិតផលកសិកម្ម ដូចជា អង្ករ និងផលិតផលកាត់ដេរសម្រេច ដែលនាំចេញទៅសហភាពអឺរ៉ុប អាមេរិក ចិនហ្វីលីពីន ។ល។

គួរបញ្ជាក់ថា កំពង់ផែស្វយ័តក្រុងភ្នំពេញបានចំណាយថវិកាជាង ២៨ លានដុល្លារអាមេរិក សម្រាប់ការសាងសង់ចំណតផែថ្មី ដោយទទួលបានហិរញ្ញប្បទានពីរដ្ឋាភិបាលចិន ។ ចំណតផែថ្មីដែលមានទីតាំងនៅស្រុកគៀនស្វាយ ខេត្តកណ្តាល ចម្ងាយ ៣០ គីឡូម៉ែត្រពីកំពង់ផែដែលមានស្រាប់មួយនៅទីក្រុងភ្នំពេញ ត្រូវបានបើកសម្ពោធដាក់ឱ្យដំណើរការកាលពីខែមករាឆ្នាំ ២០១៣ នេះ ហើយអាចមានលទ្ធភាពផ្ទុកកុងតឺន័របានចំនួន ១២ ពាន់ទូក្នុងមួយឆ្នាំនៅជំហានដំបូងនៃការអភិវឌ្ឍ ឯកំពង់ផែចាស់អាចផ្ទុកកុងតឺន័របានជាង ៧ ពាន់ទូ ។

បច្ចុប្បន្នកំពង់ផែស្វយ័តក្រុងភ្នំពេញកំពុងសិក្សា និងស្វែងរកដៃគូឯកជន ដើម្បីដំឡើងឧបករណ៍ដែលមានបច្ចេកវិទ្យាខ្ពស់ ឧបករណ៍ស្ទូច ឃ្លាំង និងចំណតផែថ្មីសម្រាប់ដំណាក់កាលទីពីរនៃការអភិវឌ្ឍ ដែលអាចឱ្យកំពង់ផែនេះអាចផ្ទុកកុងតឺន័របាន ៣សែនទូនៅពេលអនាគត ។

ដោយឡែកចរាចរណ៍ទំនិញឆ្លងកាត់តាមកំពង់ផែស្វយ័តក្រុងព្រះសីហនុដែលជាកំពង់ផែសមុទ្រទឹកជ្រៅនៅកម្ពុជា បានកើនឡើងជាង ១៦% ក្នុងរយៈពេល៩ខែឆ្នាំនេះបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំទៅ ។ ទិន្នន័យនេះបានបង្ហាញថា ទំនិញប្រហែល ២ ២៧១ ១៧៧ តោន ត្រូវបានដឹកជញ្ជូនបើប្រៀបធៀបនឹងទំនិញ ១ ៩៥៣ ០០១ តោន ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុនគឺកើន ១៦,២៩% ។ ក្នុងនោះចំនួននៃការនាំចេញសរុបបានកើនឡើងជិត ១៥០% រហូតដល់ ៥៩៤ ៤២៤ តោន ធៀបនឹង ៤០៧ ៥៧៨ តោន ខណៈចំនួននៃការនាំចូលសរុបបានកើនឡើង ១០៨,៥% ដល់ ១ ៦៧៦ ៧៥៣ តោន ធៀបនឹង ១ ៥៤៥ ៤២៣ តោន នៅក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

មន្ត្រីជំនាញរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុបានឱ្យដឹងថា កំណើននៃការនាំចេញទំនិញកំពុងបញ្ជាក់ពីស្ថិរភាពកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ទោះបីជាមានបញ្ហាស្មុគស្មាញខាងនយោបាយក៏ដោយ ។ ជាធម្មតា ការកើនឡើងចរាចរណ៍ទំនិញនៅកំពង់ផែនេះ គឺជាផ្នែកមួយបង្ហាញថា សេដ្ឋកិច្ចរបស់យើង ព្រមទាំងសេដ្ឋកិច្ចក្នុងតំបន់



*សកម្មភាពផ្ទេរ លើកដាក់ទំនិញនៅកំពង់ផែស្វយ័តរាជធានីភ្នំពេញ*

និងសេដ្ឋកិច្ចពិភពលោកកំពុងល្អប្រសើរឡើង ។ លើសពីនេះ កំណើននៃការនាំចូល និងនាំចេញទំនិញ កំពុងឆ្លុះបញ្ចាំងពីកំណើនសេដ្ឋកិច្ចរបស់យើង ទោះបីជាមានបាតុកម្មមួយចំនួនធ្វើឡើងដោយគណបក្សប្រឆាំងក៏ដោយ យើងនៅតែមើលឃើញទំនិញនាំចូលនាំចេញនៅកំពង់ផែនេះកំពុងកើនឡើង ។

កាលពីដើមខែនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្កើនការព្យាករកំណើនសេដ្ឋកិច្ចឆ្នាំ ២០១៣ នៅកម្រិត ៧% កើនឡើងពីការព្យាករកាលពីខែមេសា ៦,៧% ។ នៅក្នុងការធ្វើបច្ចុប្បន្នភាពក្នុងពេលថ្មីៗ ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)បានរក្សាការព្យាករកំណើន ៧,២% ។ ទិន្នន័យ នេះបានបង្ហាញថា ផលិតផលនាំចេញភាគច្រើនគឺសម្លៀកបំពាក់និងផលិតផលកសិកម្មមួយចំនួនដូចជាអាកាស្យាកែច្នៃ ដំឡូង ពិសេស អង្ករ និងផលិតផលនាំចូលជាវត្ថុធាតុដើមផ្នែកឧស្សាហកម្ម និងគ្រឿងសំណង់ រថយន្ត និងប្រេង ។ល។

មន្ត្រីជំនាញរបស់កំពង់ផែបានឱ្យដឹងថា កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាកំពង់ផែសម្រាប់ការដឹកជញ្ជូនផ្លូវឆ្ងាយដ៏សំខាន់នៅកម្ពុជា ដូចជាទៅប្រទេសនៅអឺរ៉ុប អាមេរិក កាណាដា ចំណែកឯកំពង់ផែស្វយ័តភ្នំពេញ ត្រូវបានប្រើប្រាស់សម្រាប់នាំចេញនៅក្នុងតំបន់ ដូចជា សិង្ហបុរី ម៉ាឡេស៊ី និងចិនជាដើម ។/



# ឥទ្ធិពល របស់សត្វមកលើ ជីវភាពមនុស្សខ្មែរ

**តពីលេខមុន**

មិនអនុញ្ញាតឱ្យមនុស្សមានគភ៌(ផើម)ជិះលើខ្នងដំរីឡើយ។ បើគេនៅតែបំពារបំពានទៅលើត្រណមនេះ ដំរីនឹងរលាស់ជម្រុះមនុស្សផើមនោះឱ្យធ្លាក់ពីលើខ្នងវា ។

## ២១_ហាមសាសងស្នេហានៅលើខ្នងដំរី :

ដោយឡែកពីត្រណមមិនឱ្យមនុស្សផើមជិះលើខ្នង ការសាសងតាមផ្លូវស្នេហាប្រឡូកប្រឡែងគ្នានៅលើខ្នងដំរីក៏ជាប្រការមួយពុំអាចអនុញ្ញាតបានដែរ។ យើងរាល់គ្នាដែលធ្លាប់ដឹងអំពីប្រពៃណីនេះរួមទាំងហ្មដំរីផងនៅពុំទាន់បានស្រាវជ្រាវរកឃើញអំពីមូលហេតុច្បាស់លាស់នៅឡើយ ។ រហូតមកទល់ពេលនេះ យើងគ្រាន់តែដឹងតាមរយៈចាស់ៗនិយាយថា បើកាលណាគេនៅតែបំពារបំពានទៅលើត្រណមនេះដំរីនឹងស្រុត(ស្លាប់)ដោយពុំអាចព្យាបាលឱ្យជាបានឡើយ។

## ២២_ដំរីចូលរួមចំណែកក្នុងការនាំមកនូវភាពត្រជាក់ត្រជុំ និងព្យាបាលក្មេងអារឹះ :

ក្មេងអារឹះជាប្រភេទក្មេងដែលពិបាកចិញ្ចឹមព្រោះវាមានជំងឺរ៉ាំរ៉ៃជាប្រចាំ គឺជំងឺចម្រុះច្រើនមុខ ឈឺនេះផង ឈឺនោះផង ពិបាកព្យាបាលជាទីបំផុត ។ហេតុគួរឱ្យចម្លែកនៅត្រង់វាស្គមរីងរៃ ឈឺឥតមានថ្ងៃស្រាកស្រាន្តតែវាមិនស្លាប់ ។ ចាស់បុរាណធ្លាប់ព្យាបាលក្មេងអារឹះនេះតាមវិធីប្លែកជាច្រើន មានដាក់វាឱ្យអង្គុយក្នុងឈ្នាងហើយយកទៅធ្វើពិធី ឧបកិច្ចនៅត្រង់ផ្លូវបំបែកជាបួន ដាក់វានៅចំផ្លូវព្រះសង្ឃនិមន្តបិណ្ឌបាតដើម្បីឱ្យព្រះសង្ឃទស់ ឬក៏យកទៅប្រគេនលោកធុតុង្គ ឱ្យលោកព្យាបាល ឬក៏ឧបកិច្ចធ្វើជាឱ្យទៅលោកអាចារ្យ ចិញ្ចឹមជានិមិត្តរូប រួចទៅលោះយកមកវិញ ។ល។ និង ។ល។ តែនៅពេលនោះយើងសូម លើកយកវិធីមួយមកពណ៌នានោះ គឺការព្យាបាលដោយមានអន្តរាគមន៍ពីដំរី ។



ដំរីជាប្រភេទសត្វដែលប្រជាជនកម្ពុជាចាត់ទុកជាសត្វផ្ដល់នូវភាពត្រជាក់ត្រជុំដល់មនុស្ស

តាំងពីបុរម បុរាណរៀងដរាបមក ខ្មែរយើងតែងតែចាត់ទុកដំរីថាជាសត្វត្រជាក់ត្រជុំ ជាសត្វនាំមកនូវសុភមង្គល ជាសត្វតំណាងឱ្យទឹក និងភាពសម្បូររុងរឿង។ ជំនឿនេះបានចាក់ឫសយ៉ាងជ្រៅទៅក្នុងអារម្មណ៍ខ្មែរ រហូតដល់នាំគ្នាជឿតៗមកថា បើកាលណាយល់សប្ដិឃើញដំរី នោះច្បាស់ជាមានភ្លៀងជាពុំខាន។ ខ្មែរខ្លះជឿថា ដំរីនាំមកនូវជោគវាសនាល្អធ្វើ អ្វីៗតែងតែកើតចម្រើនផលកាក់កបជានិច្ច។ ដូច្នេះហើយបានជាស្រីៗនៅស្រុកស្រែខ្លះដែលចង់ចិញ្ចឹមដង្កូវនាងឱ្យបានផលចម្រើន គេតែងទៅនិយាយអង្វរហ្មដំរីឱ្យជួយគេឱ្យបានស្ទាបបបូរមាត់ក្រោមរបស់ដំរី។ ជួនកាលគេយកស្បែកដំរី(ដែលងាប់)មកធ្វើជាជ្រុញហាន់ស្លឹកមនឱ្យដង្កូវនាងស៊ីដើម្បីឱ្យបានលទ្ធផលល្អក្នុងការចិញ្ចឹម ។ ខ្មែរភាគច្រើនពិសេសគ្រួសារអ្នកមានច្រើនតែយកភ្លុកដំរីទាំងគូមកដាក់តាំងលើតុកិត្តិយស ឬលើខ្នងទូទុកជាគ្រឿងលម្អផ្ទះផង និងទុកជាទ្រព្យត្រជាក់ត្រជុំនៅក្នុងផ្ទះផង។

ចំពោះក្មេងអារឹះគេយកវាទៅដាក់ពីក្រោមពោះដំរី ឬដាក់ពីក្រោមមាត់ដំរីយកប្រមោយវាឱ្យស្ទាបក្បាលក្មេងនោះ ឬក៏ឱ្យវាព្រួសទឹកដាក់ខ្លួនប្រាណក្មេងនោះក្នុងក្ដីសង្ឃឹមថាធ្វើយ៉ាងនេះ ក្មេងនឹងបានជាសះស្បើយពីជំងឺរ៉ាំរ៉ៃរបស់វា ហើយវានឹងមានសុខភាពល្អ មានកម្លាំងពលំមានប្រាជ្ញាស្មារតីល្អឡើងវិញ ។/



**លេខយោង :**

(១) មនុស្ស ឬសត្វទាំងបួនជំពូកនេះចាស់ៗលោកថា ចង្រៃណាស់មិនគួរឱ្យសេពគប់ឡើយ ។

-គោជ្រលែង : គោគេចវេះ ដើរចោល ហ្វូង ឬមិនចង់ចូលផ្ទះដូចសត្វដទៃទៀត។

-ពុតសិស្សគ្រូបី : រៀនហើយរត់រកគ្រូថ្មីទៀតញយៗ មានន័យថា ចិត្តសាវ៉ា ។

-ពុតឆ្កែបង់ម្ចាស់ : គឺឆ្កែរត់ចោលម្ចាស់ឥតហេតុផល ។

(២) គឺដោះដែលមានស្នាមផ្ដិតកន្ទួលៗ(ដូចសណ្ឋានផ្លែញ)នៅត្រង់រង្វង់ខ្មៅជុំវិញចុងដោះនោះឯង

(៣) ត្រដេវរ៉ិចយំរន្ទាន់ខ្លាំង ។/

# ទឹកជំនន់នៅអឺរ៉ុបគឺជាគ្រោះមហន្តរាយកំពូលប្រចាំឆ្នាំ



គ្រោះមហន្តរាយទឹកជំនន់ដ៏ធំនៅអឺរ៉ុបក្នុងឆ្នាំ ២០១៣

ទឹកជំនន់ក្នុងឆ្នាំ ២០១៣ នេះ គឺជាគ្រោះមហន្តរាយធម្មជាតិដ៏ធំនៅក្នុងពិភពលោក ដែលបានបង្កឱ្យមានការបាត់បង់ទឹកប្រាក់រាប់សិបពាន់លានដុល្លារ ដែលនោះគឺជាគ្រោះមហន្តរាយធម្មជាតិដ៏ធំបំផុតក្នុងឆ្នាំនេះ ជាពិសេសបណ្ដាប្រទេសនៅអឺរ៉ុបកណ្ដាលទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ។

សរុបមកគ្រោះមហន្តរាយធម្មជាតិរួមមានការរញ្ជួយដី ខ្យល់ព្យុះ និងរលកកម្ដៅ ដែលបានធ្វើឱ្យមានការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិខាតបង់ជាទឹកប្រាក់សរុប ៤៥ ពាន់លានដុល្លារ គិតរយៈពេល ៦ ខែដើមឆ្នាំ ២០១៣ បើប្រៀបធៀបមធ្យមភាគសម្រាប់រយៈពេល ១០ ឆ្នាំចុងក្រោយនេះ គឺមាន ៨៥ ពាន់លានដុល្លារនៃការបាត់បង់ដោយគ្រោះមហន្តរាយធម្មជាតិ ។ ការបាត់បង់ដោយមានការធានារ៉ាប់រងនៅក្នុងពិភពលោករយៈពេល ៦ ខែដើមឆ្នាំមានចំនួន ១៣ ពាន់លានដុល្លារ នេះបើយោងតាមក្រុមហ៊ុនធានារ៉ាប់រងអាល្លឺម៉ង់ Munich Re បានបញ្ជាក់ក្នុងរបាយការណ៍ ។

ទឹកជំនន់នៅតំបន់ឆ្ងាយពីសមុទ្របានវាយប្រហារនៅតាមផ្នែកមួយចំនួនក្នុងទ្វីបអឺរ៉ុប អាស៊ី កាណាដា និងអូស្ដ្រាលី បង្កឱ្យមានការបាត់បង់ទ្រព្យសម្បត្តិប្រមាណ ៤៧% នៃការបាត់របស់ពិភពលោកដោយគ្រោះមហន្តរាយធម្មជាតិ។ គ្រោះមហន្តរាយដែលមរណៈបំផុតមួយក្នុងចំណោមគ្រោះមហន្តរាយ ៤៦០ ដែលបានចុះក្នុងកំណត់ត្រាពិភពលោកថាជា "ព្រឹត្តិការណ៍ធម្មជាតិដ៏គ្រោះថ្នាក់បំផុតនោះ" គឺទឹកជំនន់ភ្លាមៗមានជាបន្តបន្ទាប់ កើតឡើងនៅភាគខាងជើងប្រទេសឥណ្ឌា និងនៅប្រទេសនេប៉ាល់ ដែលបានសម្លាប់ជីវិតមនុស្សអស់ជាង ១០០០ នាក់ កាលពីខែមិថុនា បន្ទាប់ពីមានភ្លៀងធ្លាក់យ៉ាងខ្លាំងខុសប្លែកពីធម្មតា។

រហូតមកទល់ពេលនេះ គ្រោះមហន្តរាយធម្មជាតិដែលបានបំផ្លាញធ្ងន់ធ្ងរជាងគេបំផុតនៅក្នុងឆ្នាំនេះ គឺទឹកជំនន់ទន្លេដែលបានវាយប្រហារភាគខាងជើង និងភាគខាងកើតប្រទេសអាល្លឺម៉ង់ ព្រមទាំងប្រទេសជិតខាងអាល្លឺម៉ង់មួយចំនួនទៀតនៅភាគកណ្ដាលទ្វីបអឺរ៉ុប កាលពីខែឧសភា និងមិថុនា បង្កឱ្យមានការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិគិតជាទឹកប្រាក់ជាង ១៦ ពាន់លានដុល្លារ ដែលភាគច្រើននៅក្នុងប្រទេសអាល្លឺម៉ង់ ។

លោក Torsten Jeworrek សមាជិកក្រុមប្រឹក្សានាយករបស់ក្រុមហ៊ុនធានារ៉ាប់រង Munich Re បាននិយាយថា "មានទឹកជំនន់កើតឡើងជាញឹកញាប់នៅអាល្លឺម៉ង់ និងអឺរ៉ុបកណ្ដាលចាប់តាំងពីទសវត្ស ១៩៨០ មក"។ ទឹកជំនន់នេះគឺជាជំនន់ទឹកភ្លៀង ដោយកន្លែងខ្លះភ្លៀងធ្លាក់មានចំណុះ ៤០០ លីត្រក្នុងមួយម៉ែត្រការ៉េ គឺភ្លៀងធ្លាក់ជាប់ៗគ្នារយៈពេល ២-៣ថ្ងៃ ។ រីឯផ្ទៃដីវិញគឺមានសភាពជោកជាំដោយទឹកអស់រយៈពេលកន្លះសតវត្សមកហើយ ដូច្នេះហើយវាបាននាំទៅដល់ការជោរជន់យ៉ាងរហ័សនៅក្នុងប្រព័ន្ធទន្លេ Danube និងទន្លេ Elbe ដែលឆ្លងកាត់ប្រទេសអាល្លឺម៉ង់ ។

លោកPeter Hoeppe ប្រធានផ្នែកស្រាវជ្រាវអំពីគ្រោះថ្នាក់នៃគ្រោះមហន្តរាយធម្មជាតិរបស់ក្រុមហ៊ុនធានារ៉ាប់រង Munich Re បាននិយាយនៅក្នុងសេចក្ដីថ្លែងការណ៍ថា "នេះគឺជាភ័ស្តុតាងបង្ហាញថា ស្ថានភាពអាកាសធាតុអាក្រក់នេះ ហើយដែលនាំឱ្យ មានទឹកជំនន់ខ្លាំងបែបនេះ ហើយតែងតែកើតមានជាញឹកញាប់" ។

ប្រព័ន្ធអាកាសធាតុអាក្រក់នៅតែគ្មានការប្រែប្រួលឡើយតាំងពីយូរមកហើយដោយលោក Peter Hoeppe បាននិយាយថា មានឱកាសខ្ពស់ណាស់ សម្រាប់ការធ្លាក់ភ្លៀងធំយូរអង្វែងតទៅទៀត ព្រមទាំងនៅរដូវក្ដៅកើតមានគ្រោះរាំងស្ងួត និងរលកកម្ដៅខ្លាំង។ លោកបានបន្តថា "នៅក្នុងកិច្ចពិភាក្សាគ្នាអំពីការប្រែប្រួលអាកាសធាតុថ្មីៗនេះគេបានសង្កត់ធ្ងន់ទៅលើបុព្វហេតុដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុ និងតួនាទីនៃការប្រែប្រួលអាកាសធាតុ" ។

គ្រោះមហន្តរាយដែលធ្វើឱ្យបាត់បង់ធ្ងន់ធ្ងរលំដាប់ទីពីរ បន្ទាប់ពីទឹកជំនន់នោះគឺខ្យល់ព្យុះដែលបានវាយប្រហារសហរដ្ឋអាមេរិកកាលពីខែឧសភា ជាខ្យល់ព្យុះមានកម្លាំងខ្លាំង ដោយបានបំផ្លិចបំផ្លាញស្រុកមួយចំនួននៅជាយក្រុង Oklahoma ក្នុងនោះមានស្រុក Moore ។ ខ្យល់ព្យុះនោះបានសម្លាប់ជីវិតមនុស្ស ២៦ នាក់ និងរបួសជាង ២៧០ នាក់ ហើយនៅក្នុងស្រុក Moore តែមួយគត់ខ្យល់ព្យុះនោះបានបំផ្លាញអគារជាង ១០០០ អគារ ធ្វើឱ្យបាត់បង់ផ្នែកសេដ្ឋកិច្ចសរុបជាងបីពាន់លានដុល្លារ ដែលក្នុងនោះពាក់កណ្ដាលស្ថិតក្នុងការធានារ៉ាប់រង ។

លោក Peter Hoeppe បាននិយាយថា "រដ្ឋមួយចំនួននៅភាគកណ្ដាលសហរដ្ឋអាមេរិកទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរជាងគេដោយសារខ្យល់ព្យុះ។ ប៉ុន្តែសរុបមករដូវខ្យល់ព្យុះនៅអាមេរិកមានកម្រិតទាបជាងកម្រិតមធ្យមភាគ ពោលគឺខ្យល់ព្យុះកាលពីខែមិថុនាជាខ្យល់ព្យុះមួយក្នុងចំណោម ៦២៥ ខ្យល់ព្យុះដែលបានកើតឡើង ហើយបើប្រៀបធៀបកម្រិតមធ្យមភាគរយៈពេលវែងគឺ ១០៧៥ ខ្យល់ព្យុះ" ។/

# មើមរមៀតជួយការពារជំងឺមហារីក



មើមរមៀត



ដើម និងមើមរមៀត

មើមរមៀតមិនត្រឹមតែត្រូវបានយកមកប្រើប្រាស់សម្រាប់ផ្សំធ្វើជាគ្រឿងសម្លប្រហើរការី ឬដើម្បីយកពណ៌ម្ហូបប៉ុណ្ណោះទេ តែក៏ជាគ្រឿងផ្សំមួយប្រើក្នុងឱសថបូរាណសម្រាប់ព្យាបាលជំងឺផ្សេងៗផងដែរ។ ឥឡូវនេះ គេកាន់តែស្គាល់ និងយល់ច្បាស់នូវគុណប្រយោជន៍ដ៏ច្រើនរបស់រមៀត ។ អ្នកវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ បានរកឃើញ និង ទទួលស្គាល់ថា រមៀតមានគុណប្រយោជន៍ យ៉ាងច្រើនសម្រាប់ការពារសុខភាព និងប្រយុទ្ធប្រឆាំងនឹងជំងឺជាច្រើនរាប់ទាំងជំងឺមហារីកដ៏កាចសាហាវផង។ ដើមរមៀតមានដុះច្រើននៅប្រទេសក្ដៅ ដូចជាប្រទេស វៀតណាម ឡាវ ចិន ឥណ្ឌូណេស៊ី ។

ក្នុងមើមរមៀត គេវិភាគរកឃើញមានជាតិពណ៌ curcumine 0,៣% ពណ៌សូកូឡាមិនរលាយក្នុងទឹក តែរលាយក្នុងស្រា ether ឬchloroforme ។ជាតិពណ៌នេះរលាយក្នុងអាស៊ីដឱ្យពណ៌ក្រហមស្រស់ ហើយបើ ដាក់ក្នុង soude ឱ្យពណ៌ក្រហមដូចឈាម គេនិយមយកជាតិពណ៌នេះប្រើក្នុងផ្នែកវិទ្យាសាស្ត្រ។ មើមរមៀត មានជាតិប្រេងម្យ៉ាងអាចសម្លាប់មេរោគផ្សិត staphylocoque ហើយនិងមេរោគផ្សេងៗទៀត។ តាមឯកសារបូរាណ មើមរមៀត គេនិយមយកមើមរមៀតប្រើព្យាបាលជំងឺឈឺក្រពះ ជំងឺកើតលឿង សម្រាប់ព្យាបាលនារី ក្រោយសម្រាលកូនរួច ប្រើជាថ្នាំលាបមុខដែលមានរោគមុនដើម្បីកុំឱ្យមានស្លាកស្នាម។ ចំណែកស្លឹករមៀត ប្រើក្នុងការផ្សំធ្វើម្ហូប ដើម្បីបំបាត់ក្លិន ដើម្បីបានពណ៌ក្នុងអាហារ មើមរមៀត ត្រូវបានក្រុមគ្រូពេទ្យថ្នាំបូរាណ ឥណ្ឌា ចិន ខ្មែរ ស្គាល់ និងយកមកប្រើធ្វើជាឱសថតាំងពីរាប់ពាន់ឆ្នាំមុនមកម្ល៉េះ។ បើនៅប្រទេសឥណ្ឌាវិញ មើមរមៀត ម្សៅរមៀតត្រូវបានយកមកប្រើប្រាស់ស្ទើរក្នុងគ្រប់មុខម្ហូប បើជាសម្លការីផងគ្មានរមៀត គឺមិនហៅថាការីឡើយ ។

មើមរមៀតមានគុណប្រយោជន៍ខ្លាំងចំពោះសុខភាព ក៏ព្រោះតែរមៀតមានផ្ទុកសារធាតុសកម្ម Curcumine ។ សារធាតុ Curcumine មានតួនាទី និងសកម្មភាពប្រកបដោយអត្ថប្រយោជន៍ដូចខាងក្រោមនេះ ៖

មើមរមៀតមានសកម្មភាពជួយធ្វើមក្នុងការបញ្ចេញជាតិពុល សារធាតុ Curcumine ជួយសម្រួលដល់ការបញ្ចេញវត្ថុរាវសម្រាប់ចិញ្ចឹមសរីរាង្គកាយផង ការបញ្ចេញទឹកប្រម៉ាត់ផង ក្រពះឡើយហត់ពិបាករំលាយចំណី អាហារ ជាពិសេសជាតិខ្លាញ់ ចូរគិតដល់រមៀត ព្រោះថា សារធាតុ Curcumine ត្រូវបានគេចាត់ទុកជាភ្នាក់ងារការពារប្រព័ន្ធរំលាយអាហារយ៉ាងពេញលេញ។ គ្រូពេទ្យឯកទេសចំណីអាហារបានណែនាំឱ្យប្រើមើមរមៀតជាគ្រឿងផ្សំនៅក្នុងម្ហូបអាហារណាដែលមានខ្លាញ់ច្រើន ដូចជាការធ្វើដូច្នេះលោកអ្នក និងអាចបញ្ចៀសគ្រោះមានជំងឺក្រលាយអាហារបាន។ វត្តមានរបស់មើមរមៀតជាគ្រឿងផ្សំរបស់សម្លការី ទំនងមិនមែនជាការចៃដន្យទេ ការប្រើរមៀត ២៥% នៅក្នុងគ្រឿងការី គឺពិតជាដើម្បីទប់ឥទ្ធិពលរបស់ខ្លាញ់ ខ្ទិះ និងម្ទេស ដែលបើមុខនេះ អាចនឹងធ្វើឱ្យក្រពះទ្រាំមិនបាន។ ហេតុដូច្នេះហើយ បានជាចាស់បូរាណខ្មែរឱ្យលាបរមៀតដើម្បីរក្សាស្បែកឱ្យនៅក្មេងល្អ។ បើនិយាយដល់សមត្ថភាពអង់ទីអុកស៊ីតដង់នេះ គេត្រូវនឹកឃើញភ្លាមដល់ការប្រយុទ្ធប្រឆាំងនឹងជំងឺមហារីក ។

ពេលនេះគ្រប់គ្នាបានទទួលស្គាល់អំពីប្រសិទ្ធភាពរបស់រមៀតប្រឆាំងទប់ទល់នឹងជំងឺមហារីក ។ សមត្ថភាពនេះនឹងឡើងដល់កម្រិតកាន់តែខ្ពស់ប្រសិនបើគេប្រើប្រាស់មើមរមៀត បូកផ្សំជាមួយនឹងប្រេង Olive ម្រេចខ្មៅ ឬជាមួយនឹងខ្ញី-ផ្លែម្នាស់។ ការសិក្សាជាច្រើនកំពុងតែផ្ដោតលើសមត្ថភាពរមៀតជាថ្នាំការពារប្រឆាំងជំងឺមហារីក។ មើមរមៀតទំនងជាអាចមានឥទ្ធិពលបីដំណាក់កាល ៖ ទីមួយ គឺកាត់បន្ថយសកម្ម-



ដើម និងមើមរមៀត ដែលត្រូវបានកិនធ្វើជាម្សៅ

ភាពបំប្លែងខ្លួនរបស់សារធាតុខ្លះ កាត់បន្ថយការឆាប់ស្លាប់របស់កោសិកាដែលចាស់មុនអាយុ ដោយឥទ្ធិពលខាងក្រៅ និងចុងក្រោយរមៀតទំនងជាមានសកម្មភាពទៅទប់ស្កាត់សរសៃឈាមតូចៗមិនឱ្យមានកំណកដុំពកបាន។ នៅប្រទេសចិន អាជ្ញាធរសុខាភិបាលបានចេញអនុសាសន៍ជាផ្លូវការឱ្យបុគ្គលមានហានិភ័យកើតជំងឺមហារីកបំពង់អាហារប្រើមើមរមៀតជាប្រចាំ ។ សមត្ថភាពការពារជំងឺមហារីករបស់រមៀត គឺមានទាំងមហារីកមាត់ ធ្មេញ បំពង់ក និងពោះវៀន។ នៅប្រទេសឥណ្ឌា គុណប្រយោជន៍របស់មើមរមៀតប្រឆាំងនឹងជំងឺមហារីកត្រូវបានទទួលស្គាល់ជាទូទៅ ហើយបើយោងតាមទិន្នន័យនៃការសិក្សាអំពីរោគរាតត្បាត គេសង្កេតឃើញថាប្រេវ៉ាឡង់នៃជំងឺ មហារីកជាច្រើន ដូចជាមហារីកពោះវៀន សុដន ពងស្វាស និងសួតនៅតាមបណ្ដាប្រទេសអាស៊ី ដែលបរិភោគរមៀតច្រើនគឺមានកម្រិតទាបជាងបស្ចឹមប្រទេសដែលមិនស្គាល់រមៀតនេះ។ ដូច្នេះដំបូន្មានរបស់ចាស់បូរាណខ្មែរឱ្យប្រើរមៀតដើម្បីរក្សាស្បែក សាច់ស្អាត ពិតជាមិនខុស ឬមិនមែនជាគំនិតស្រមើស្រមៃជឿតៗគ្មានគតប្រយោជន៍នោះឡើយ ព្រោះបើវិភាគតាមបែបវេជ្ជសាស្ត្រ វិទ្យាសាស្ត្រ រមៀតមានផ្ទុកសារធាតុអង់ទីអុកស៊ីដង់ ជួយកោសិកាមិនឱ្យឆាប់ចាស់ គឺពិតណាស់ដែលថាលាបរមៀតដើម្បីជួយស្បែកឱ្យបាត់ស្នាមសម្លាកឱ្យនៅក្មេង។ លទ្ធផលបានបង្ហាញដោយជាក់ស្ដែងចំពោះអ្នកដែលមានជំនឿលើឱសថបូរាណ និងអ្នកចូលចិត្តប្រើប្រាស់ថ្នាំធម្មជាតិ។

ជាមួយនឹងតម្លៃថោក ស្រួលដាំដុះរមៀតមានគុណប្រយោជន៍រាប់មិនអស់ អ្នកវិទ្យាសាស្ត្របានរកឃើញបន្ថែមទៀតថារមៀតនេះមានសកម្មភាពប្រឆាំងនឹងការរលាក។ ការរលាកដែលកើតមានឡើង ជាពិសេសនៅតាមសន្លាក់ដៃ សន្លាក់ជើង និងឆ្អឹងឆ្អែង។ លើសពីនេះទៅទៀត ការបរិភោគជាប្រចាំម្សៅរមៀត អាចជួយសម្រួលចរន្តឈាម និងបេះដូង ការពារប្រឆាំងនឹងជំងឺស្ទះសរសៃឈាមបេះដូង ព្រោះមើមរមៀតមានសមត្ថភាពទៅទប់ទៅឃាត់មិនឱ្យខ្លាញ់អាចកកនៅលើផ្ទៃនៃសរសៃឈាមក្រហមបាន។ នៅប្រទេសឥណ្ឌា គេបរិភោគឫស ឬមើមរមៀតក្រៀម ពី ២ ទៅ ៤ ក្រាម ក្នុងមួយថ្ងៃ។ ឫស-មើមនេះ បើយកទៅចម្រាញ់នោះ គេនឹងទាញបានសារធាតុ Curcumine ដ៏មានប្រយោជន៍ប្រមាណពី ១ ទៅ ៥ % ។ ដើម្បីបានប្រយោជន៍ពីដើមរមៀតសម្រាប់ការពារសុខភាព គេត្រូវទទួលទានសារធាតុ Curcumine ពី ២០០ ទៅ ៤០០ មីលីក្រាមក្នុងមួយថ្ងៃ។ គុណភាពមើមរមៀតមិនដូចគ្នាទេ ជាទូទៅក្នុងមើមរមៀតពី ២០ ទៅ ១០០ មីលីក្រាម អាចផ្ដល់សារធាតុ Curcumine បានមួយមីលីក្រាម។/

តមកពីទំព័រទី ៦

## សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម .............

ជានិមិត្តរូបនៃការខិតខំប្រឹងប្រែងរួមគ្នា ប្រកបដោយឆន្ទៈនយោបាយខ្ពស់បំផុត ដើម្បីការបង្រួបបង្រួមជាតិ ផ្សះផ្សារជាតិ ឯកភាពជាតិ សន្តិភាព ស្ថិរភាពនយោបាយ ជូនប្រជាជន និងប្រទេសកម្ពុជា។ ជាងនេះទៀត ការផ្ដល់គ្រឿងឥស្សរិយយសនេះពិតជាមានអត្ថន័យដ៏ធំធេង ព្រោះស្របពេលដែលប្រទេសយើងទាំងពីរបាននឹងកំពុងប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦០នៃថ្ងៃបង្កើតទំនាក់ទំនងការទូត ។

សម្ដេចបានបន្តថា រាជរដ្ឋាភិបាលជប៉ុន និងប្រជាជនជប៉ុនជានិច្ចកាល បានជួយគាំទ្រប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈ ពិសេសបានដើរតួនាទីដ៏សំខាន់ សកម្ម និងគន្លឹះ នៅក្នុងដំណើរការស្វែងរកសន្តិភាពនៅកម្ពុជា ហើយបានបន្តជួយឧបត្ថម្ភគាំទ្រទាំងធនធាន មធ្យោបាយ ស្មារតី ក្នុងការអភិវឌ្ឍប្រទេសកម្ពុជាឡើងវិញ ឱ្យមានការរីកចម្រើន ប្រជាជនកម្ពុជារស់នៅក្នុងជីវភាពថ្លៃថ្នូរសុភមង្គលឧត្តុង្គឧត្តម។

សម្ដេចបានបញ្ជាក់ទៀតថា ក្នុងរយៈពេល ៦០ ឆ្នាំ កន្លងមកនេះ ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ កម្ពុជា-ជប៉ុន កាន់តែមានការរីកចម្រើនឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃលើវិស័យសេដ្ឋកិច្ច នយោបាយ វប្បធម៌ សង្គមកិច្ច សុខាភិបាល អប់រំ។ ជាពិសេស ប្រជាជនទាំងពីរបានស្រឡាញ់រាប់អានគ្នាទៅវិញទៅមក ផ្លាស់ប្ដូរគ្នាទៅវិញទៅមកនូវប្រពៃណី និងវប្បធម៌ ដ៏រុងរឿង។ ទំនាក់ទំនងដ៏ល្អនេះ នឹងត្រូវបានបន្តថែរក្សាពូនជ្រំឱ្យរឹងមាំ ស្ថិតស្ថេរយូរអង្វែងសម្រាប់កូនចៅជំនាន់ក្រោយ និងដើម្បីផលប្រយោជន៍ទៅវិញទៅមកនៃប្រជាជន និងប្រទេសទាំងពីរ ។/



ឃុំកំពង់ភ្លុកដែលជាមូលដ្ឋានរបស់ប្រជានេសាទនៃស្រុកប្រាសាទបាគង ខេត្តសៀមរាប បានបង្កប់ខ្លួនយ៉ាងជ្រៅនៅក្នុងដែនព្រៃលិចទឹក និងបណ្តែតខ្លួនលើផ្ទៃទឹកដ៏ល្វឹងល្វាចធំស្កឹមស្កៃនៃតំបន់បឹងទន្លេសាប ។ ប្រជាជនរស់នៅឃុំកំពង់ភ្លុកមានជីវភាពពីរបែបអាស្រ័យទៅតាមរដូវកាល គឺក្នុងរដូវប្រាំងរស់តាមរបៀបម្យ៉ាង និងក្នុងរដូវវស្សារស់តាមរបៀបម្យ៉ាងផ្សេងទៀត ។ អាស្រ័យដោយមានទិដ្ឋភាពពីររដូវកាលបែបនេះ ទើបធ្វើឱ្យឃុំកំពង់ភ្លុកក្លាយទៅជាទីចាប់អារម្មណ៍របស់មនុស្សផងទាំងពួង ។ វាមិនមែនហាក់ដូចជាបង្កប់នូវអាថ៌កំបាំងណាមួយដែលធ្វើឱ្យគេពិបាកយល់នោះទេ ប៉ុន្តែកំពង់ភ្លុកបានផ្តិតជាប់នូវទេសភាពដ៏ស្រស់ត្រកាលប្លែកពីគ្នាទាំងស្រុងរវាងរដូវប្រាំង និងរដូវវស្សា ។




# ឃុំកំពង់ភ្លុក ទឹកដីដែននេសាទ ដ៏ស្រស់ត្រកាលដែលកំពុងតែពង្រីកខ្លួន




ក្រុមការងារគណបក្សប្រជាជនកម្ពុជា ដង្ហែអង្គកឋិនទានដោយទូកតូចៗទៅកាន់វត្តកំពង់ភ្លុក

កំពង់ភ្លុកជាឃុំមួយស្ថិតនៅជាប់តំបន់បឹងទន្លេសាបប៉ែកខាងកើតនៃខេត្តសៀមរាប មានចម្ងាយប្រមាណជាង ៣២ គីឡូម៉ែត្រពីទីរួមខេត្ត មានប្រជាជនរស់នៅចំនួន ៣៤៧៥ នាក់ក្នុងនោះស្រី ១៧៦៤ នាក់ ។ ប្រជាជនដែលប្រកបរបរជាអ្នកនេសាទមាន ៩៧% ឯណោះ ។ អ្វីដែលគួរឱ្យកត់សម្គាល់ គឺប្រជាជនធ្វើចំណាកស្រុកពីឃុំកំពង់ភ្លុកមានតែចំនួន ៧ នាក់ទេ ។ ដោយសារតែឃុំកំពង់ភ្លុកស្ថិតនៅជាប់មាត់បឹងទន្លេសាបហ៊ុមព័ទ្ធទៅដោយព្រៃគុម្ពោត ព្រៃលិចទឹក ហើយច្បាប់បានហាមឃាត់យ៉ាងតឹងរ៉ឹងមិនឱ្យប្រជាជនកាប់បំផ្លាញព្រៃឈើធ្វើស្រែចម្ការនោះ ទើបបងប្អូនប្រជាជននៅទីនោះចាប់យកមុខរបរនេសាទសឹងតែទាំងអស់គ្នា ហើយវាក៏បានក្លាយទៅជាប្រពៃណីតកូន តចៅតរៀងមក ។ ប្រជាជននៅទីនេះត្រូវធ្វើការនេសាទគ្រប់ពេលគ្រប់រដូវកាល ហេតុនេះពួកគាត់តែងតែត្រូវប្រឈមនឹងបញ្ហាលំបាកខ្លះៗក្នុងរដូវបិទនេសាទម្តងៗ ។

ប៉ុន្តែទោះលំបាកបន្តិចក្តី ប៉ុន្តែប្រជាជនមានសេចក្តីរីករាយណាស់ក្រោយពេលដែលសម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើកំណែទម្រង់នេសាទដោយបានដកឡូត៍នេសាទមួយចំនួនមកប្រគល់ជូនប្រជានេសាទប្រកបរបររកស៊ីទទួលទានដោយសេរី ដែលធ្វើឱ្យជីវភាពរបស់បងប្អូនកាន់តែមានភាពធូរធារមួយកម្រិតថែមទៀត ។

ក្រៅពីប្រកបរបរនេសាទ ប្រជាជនឃុំកំពង់ភ្លុកក៏អាចបង្កើនជីវភាពរស់នៅឱ្យកាន់តែកើនឡើងថែមទៀតតាមរយៈការបង្កើតសហគមន៍ដឹកជញ្ជូនភ្ញៀវទេសចរ ។ លោក នឹង នី ប្រធានក្រុមប្រឹក្សាឃុំបានថ្លែងថា ចាប់តាំងពីបានរៀបចំចងក្រងជាសហគមន៍កាលក្នុងអំឡុងឆ្នាំ ២០១០ រហូតមកទល់ឆ្នាំ ២០១៣ នេះ ប្រជានេសាទឃុំកំពង់ភ្លុកបានទទួលកម្រៃប្រចាំថ្ងៃបន្ថែមពីវិស័យទេសចរណ៍ លើកម្រៃដែលពួកគាត់ទទួលបានជាប្រពៃណីក្នុងជីវិតជាអ្នកនេសាទត្រី ។ លោក នឹង នី បានមានប្រសាសន៍ដោយមានមោទនភាពថា ប្រជាសហគមន៍នេសាទឃុំកំពង់ភ្លុកប្រមាណ ៧០០ គ្រួសារលើចំនួនគ្រួសារសរុប




លោក **ឌឹម សីលា** និងក្រុមការងារ និងលោក **នឹង នី** ជួបសំណេះសំណាល និងផ្តល់អំណោយដល់ប្រជាពលរដ្ឋឃុំកំពង់ភ្លុកដែលរងគ្រោះដោយទឹកជំនន់



*លំនៅឋានរបស់ប្រជាពលរដ្ឋ និងទូកសម្រាប់ដឹកភ្ញៀវទេសចរណ៍ធ្វើដំណើរកម្សាន្តក្នុងតំបន់ព្រៃលិចទឹកឃុំកំពង់ភ្លុក*

១០២៧ គ្រួសារ បានក្លាយជាសមាជិកសហគមន៍ទូកដឹកជញ្ជូនភ្ញៀវទេសចរកំសាន្តតំបន់ព្រៃធម្មជាតិលិចទឹកក្នុងមូលដ្ឋានរបស់ខ្លួន ។ ដោយឡែកលោក សាន គង់ ប្រធានសហគមន៍ទេសចរណ៍វប្បធម៌ និងធម្មជាតិឃុំកំពង់ភ្លុកក៏បានឱ្យដឹងដែរថា នៅក្នុងចំណោមសមាជិកសហគមន៍ទេសចរណ៍កំពង់ភ្លុកទាំង ៧០០ គ្រួសារនេះ គឺមានទូកអុំចំនួន ៧០០ គ្រឿង ដែលកំពុងមានដំណើរការដឹកជញ្ជូនភ្ញៀវទេសចរទស្សនាកំសាន្តនៅតំបន់ព្រៃលិចទឹកទាំងនោះ ។ អ្នកអុំទូកជូនភ្ញៀវទាំងអស់គឺសុទ្ធតែជាក្រុមស្ត្រី ។ ក្រុមស្ត្រីអុំទូកជូនដំណើរភ្ញៀវបាននិយាយថា ក្នុងការជូនដំណើរភ្ញៀវម្តងមានរយៈពេលពី ២០-៣០ នាទី ហើយពួកគាត់ទទួលបានកម្រៃ ២ ដុល្លារ ជួនកាលក៏មានភ្ញៀវជួយឧបត្ថម្ភកម្រៃបន្ថែមក្រៅទៀត ។ បងប្អូនប្រជាជននៅទីនោះបង្ហាញនូវក្តីសោមនស្សរីករាយយ៉ាងក្រៃលែងចំពោះការបន្ថែមមុខរបរនេះ ហើយធ្វើឱ្យបងប្អូនកាន់តែយល់ដឹងច្រើនអំពីអត្ថប្រយោជន៍ដែលទាញយកបានពីសម្បត្តិធម្មជាតិព្រៃលិចទឹក តាមរយៈវិស័យទេសចរណ៍ ។ ដោយមើលឃើញពីផលប្រយោជន៍នេះ បងប្អូនប្រជាជននៅទីនេះកាន់តែសកម្មថែមទៀតក្នុងការរួបរួមគ្នាថែរក្សាការពារសម្បត្តិធម្មជាតិព្រៃលិចទឹក ក៏ដូចជារួមគ្នាការពារជម្រកត្រីនិងការធ្វើនេសាទត្រីដោយមិនបំពានច្បាប់ ។ លោកប្រធានសហគមន៍ទេសចរណ៍វប្បធម៌ឃុំកំពង់ភ្លុកបានឱ្យដឹងថា មុខរបរអុំទូកជូនភ្ញៀវកំសាន្តព្រៃលិចទឹកនេះមិនត្រឹមតែបានរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែមុខរបរបន្ថែមមួយនេះក៏ជាជំនួយមួយដែរក្នុងការកាត់បន្ថយបទល្មើសនេសាទ ។ ម្យ៉ាងវិញទៀត អាទិភាពសម្រាប់ចូលជាសមាជិកសហគមន៍ទេសចរណ៍នេះគឺយើងសំដៅលើគ្រួសារស្ត្រីមេម៉ាយ គ្រួសារគ្មានទីពឹង និងស្ត្រីដែលជួយបន្ទុកគ្រួសារ ដោយប្តីចេញទៅនេសាទដើម្បីរួមដៃគ្នាទាំងប្តី ទាំងប្រពន្ធ និងទាំងក្រុមគ្រួសារដើម្បីកសាងសេដ្ឋកិច្ចគ្រួសារមួយឱ្យកាន់តែប្រសើរឡើង ។ បើតាមលោកប្រធានសហគមន៍ទេសចរណ៍បានបញ្ជាក់ឱ្យដឹងទៀតថា ក្នុងមួយថ្ងៃមានភ្ញៀវទេសចរជាតិ និងអន្តរជាតិប្រមាណពី ៣០០ ទៅ ៥០០ នាក់ ដែលបានចូលទៅទស្សនាកំសាន្តក្នុងតំបន់ព្រៃលិចទឹកឃុំកំពង់ភ្លុក ។ ឯការលក់សំបុត្រជិះទូកកំសាន្តអាចដាច់ពី ៣០ ទៅ ៥០ សន្លឹក ។ សំបុត្រជិះទូកមួយសន្លឹកតម្លៃ៥ដុល្លារ ។សំបុត្រមួយសន្លឹកសម្រាប់ទូកមួយ ហើយទូកមួយនេះអាចជិះកំសាន្តពីម្នាក់ទៅ ៣ នាក់ ។ ការចែកផលលាភពីការលក់សំបុត្រនេះត្រូវបានដល់អ្នកអុំទូកចំនួន ២ ដុល្លារ ។ សម្រាប់អ្នកនាំភ្ញៀវចូលមកតំបន់នេះទទួលបាន ២ ដុល្លារ និង ១ ដុល្លារទៀតយើងរក្សាទុកសម្រាប់តម្កល់ប្រើប្រាស់ជាប្រយោជន៍សហគមន៍ទាំងមូល រួមទាំងជួយដល់ការងារអភិវឌ្ឍន៍តំបន់ត្រីមេពូជផងដែរ ។ អាស្រ័យដោយចំនួនទូករបស់សមាជិកសហគមន៍មានចំនួនរហូតដល់ ៧០០ គ្រឿង ដូច្នេះការទទួលសេវាបម្រើភ្ញៀវត្រូវវេនផ្លាស់វេនគ្នា ។

ឃុំកំពង់ភ្លុកក្នុងរដូវវស្សាពិតជាបង្ហាញនូវទស្សនីយភាពដ៏ល្អត្រកាលណាស់ ។ ទិដ្ឋភាពក្នុងរដូវវស្សាបានបង្ហាញឱ្យឃើញពីជីវិតរស់នៅរបស់ប្រជាជនប្រកបដោយភាពរស់រវើកបណ្តែតលើផ្ទៃបឹងទន្លេសាបដ៏ធំល្វឹងល្វើយ ។ គេឃើញផ្ទះបណ្តែតទឹកតម្រៀបគ្នាជាជួរគួរឱ្យគយគន់ ។ ពិសេសទៅទៀតព្រះវិហារវត្តមួយបានលេចត្រដែតឡើងនៅលើដែនកោះតូចមួយដែលស្ថិតនៅចំពាក់កណ្តាលនៃបណ្តាភូមិចំនួន ៥ លាតសន្ធឹងពីត្បូងទៅជើង ។ នោះគឺវត្តមុនីសាគរបវរសត្ថាស្រះកែវអណ្តែតហៅវត្តកំពង់ភ្លុក ។ ក្នុងរដូវវស្សាបែបនេះ ផ្ទះសម្បែងប្រជាជនទាំងអស់គឺត្រូវបណ្តែតទឹកពុំមានផ្ទះស្ថិតនៅលើដីគោកទេ ។ ចង់ទៅណាមកណាគឺត្រូវប្រើប្រាស់ទូកទាំងអស់ ។ បុណ្យកឋិនទានមួយត្រូវបានដង្ហែទៅកាន់វត្តកំពង់ភ្លុក ដែលផ្តួចផ្តើមឡើងដោយក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជាចុះជួយពង្រឹងមូលដ្ឋានកំពង់ភ្លុក រួមទាំងការមូលមតិគ្នាឯកច្ឆន្ទពីសំណាក់បងប្អូនប្រជានេសាទក្នុងសហគមន៍មួយនេះផងដែរ ។ ទូករាប់រយគ្រឿងបានដង្ហែអង្គកឋិននេះមើលទៅគួរឱ្យអស្ចារ្យសម្បើមណាស់ ដោយទូក និងកាណូតទាំងឡាយសុទ្ធតែមានតុបតែងដោយគ្រឿងលម្អចម្រុះពណ៌ ឯប្រជាជនក៏មានទឹកមុខសប្បាយរីករាយដោយមិនឡើយណាយថាត្រូវលំបាកដោយសារតែការធ្វើបុណ្យនៅលើផ្ទៃទឹកបែបនេះទេ ។ ប្រជានេសាទឃុំកំពង់ភ្លុក បាននិយាយថា រៀងរាល់បុណ្យប្រពៃណីព្រះពុទ្ធសាសនាដែលបានប្រារព្ធឡើងនៅក្នុងរដូវវស្សាគឺយើងតែងប្រារព្ធឡើងមិនដែលអាក់ខានទេ ព្រោះនេះជាប្រពៃណីទំនៀមទំលាប់របស់ប្រជាជនយើង ។

ប្រជានេសាទឃុំកំពង់ភ្លុកមិនត្រឹមតែមានជីវភាពរស់នៅសម្បូរធូរធារ មានការងារធ្វើ



*សមាជិកសហគមន៍ដឹកជញ្ជូនភ្ញៀវទេសចរកំសាន្តតំបន់ព្រៃធម្មជាតិលិចទឹកក្នុងមូលដ្ឋានឃុំកំពង់ភ្លុក*

គ្រប់ៗគ្នា និងមានចិត្តសប្បុរសរាក់ទាក់ប៉ុណ្ណោះទេ ប៉ុន្តែគឺជាប្រជាជនឈ្នះ ។ ប្រជាជនឃុំកំពង់ភ្លុកតែងបានបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាឱ្យទទួលបានជ័យជំនះគ្រប់នីតិកាលទាំងអស់ ទាំងការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ក្នុងការបោះឆ្នោតសកលកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅ ប្រជានេសាទឃុំកំពង់ភ្លុកបានបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជាដោយឈ្នះសំឡេងលើសលប់ ។ ក្នុងចំណោមអ្នកបោះឆ្នោត ១៨៩១ នាក់ គឺមានអ្នកបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាចំនួន ១៦៦៤ នាក់ទៅហើយ ។ ដោយឡែកការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កាលពីឆ្នាំ២០១២ ក្នុងចំណោមអាសនៈទាំង៥ គឺគណបក្សប្រជាជនកម្ពុជាឈ្នះទាំង ៥ អាសនៈនោះតែម្តង គ្មានគណបក្សណាមួយទទួលបានកៅអីនៅក្នុងជួរក្រុមប្រឹក្សាឃុំកំពង់ភ្លុកទេ។ លោក នឹង នី ប្រធានក្រុមប្រឹក្សាឃុំកំពង់ភ្លុកបានកោតសរសើរយ៉ាងខ្លាំងអំពីស្មារតីសាមគ្គីភាពឯកភាពគ្នាជាធ្លុងមួយរបស់ប្រជាជននៅឃុំនេះ ។ លោកថែមទាំងបញ្ជាក់ទៀតថា អាស្រ័យដោយមានការជឿជាក់លើការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ប្រជាជនឃុំកំពង់ភ្លុកមិនដែលងាករេចិត្ត មិនដែលបាត់បង់ជំនឿទុកចិត្តទៅលើសម្តេចទាំង ៣ ម្តងណាឡើយ ។ ម៉្យាងទៀតនៅពេលដែលបងប្អូនប្រជាជនជួបការលំបាកម្តងៗឃើញមានតែមន្ត្រីគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះដែលបានចុះមកសាកសួរសុខទុក្ខជួយរំលែកការលំបាក និងបានជួយឧបត្ថម្ភសព្វបែបយ៉ាងដល់ប្រជាជនយើង ។ លោកវរសេនីយ៍ឯក ញឹម សីលា អនុប្រធានក្រុមការងារថ្នាក់ខេត្តចុះជួយស្រុកប្រាសាទបាគង និងជាប្រធានក្រុមការងារចុះជួយឃុំកំពង់ភ្លុក ហើយលោកក៏ជាមេបញ្ជាការរងកងរាជអាវុធហត្ថខេត្តសៀមរាបបានមានប្រសាសន៍ថា បងប្អូនប្រជាជនយើងនៅទីនេះសុទ្ធតែមានការយល់ដឹងច្បាស់លាស់ណាស់ថា តើអ្នកណាដែលបានជួយពួកគាត់ឱ្យមានជីវភាពធូរធារបែបនេះ ហើយតើអ្នកណាដែលតែងតែមកភូតកុហកបោកប្រាស់។ ក្នុងនាមជាក្រុមការងារយើងតែងសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីចុះជួយប្រជាជនដែលជួបការលំបាក ដូចជាគ្រួសារអ្នកខ្លះដែលមានសមាជិកត្រូវជួបគ្រោះថ្នាក់ដោយលង់ទឹកស្លាប់ ឬក៏ស្ត្រីមេម៉ាយមានកូនតូចៗក្នុងបន្ទុក គឺយើងតែងតែផ្តុំផ្តើមឱ្យគាត់មានមុខរបរនៅក្នុងសហគមន៍ ។ សហគមន៍នេសាទ ក៏ដូចជាសហគមន៍ទេសចរណ៍ បានដើរតួនាទីយ៉ាងសំខាន់ណាស់ជាមួយអាជ្ញាធរមូលដ្ឋានជាមួយគណបក្សប្រជាជនកម្ពុជា និងក្រុមពង្រឹងការងាររបស់យើង ដើម្បីពិនិត្យ និងដោះស្រាយរាល់បញ្ហាទាំងឡាយដែលបានកើតឡើងភ្លាមៗមិនអូសបន្លាយពេលវេលា ។ ប្រជាជននៅឃុំកំពង់ភ្លុក គឺជាអ្នកគោរពច្បាប់ ហើយដោយសារតែមូលហេតុនេះដែរ ដែលធ្វើឱ្យជីវភាពរស់នៅរបស់គាត់រីកចម្រើន ព្រោះត្រីក៏សម្បូរ មិនទទួលរងការនេសាទតាមរបៀបបំផ្លិចបំផ្លាញ ហើយផ្តើមពីនេះទៀត ទេសចរណ៍ជាតិ និងអន្តរជាតិក៏ចង់មកទស្សនា។ លោក ញឹម សីលា បានបញ្ជាក់ទៀតថា រៀងរាល់ពេលយើងតែងពន្យល់ឱ្យគាត់យល់ពីអំពីច្បាប់ជលផល ក៏ដូចជាគោលនយោបាយផ្សេងៗទៀត ដើម្បីការពារសុខសុវត្ថិភាពភូមិឃុំរបស់គាត់ ជួយលើកស្ទួយជីវភាពរស់នៅរបស់គាត់ ។

ប្រជានេសាទឃុំកំពង់ភ្លុកដែលនៅតែគាំទ្រ នៅតែផ្តល់ការជឿទុកចិត្តដល់គណបក្សប្រជាជនកម្ពុជា ដល់សម្តេចអគ្គមហាទាំងបី ជាពិសេស សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សុទ្ធតែបានមើលឃើញនូវអនាគតដ៏ភ្លឺស្វាងសម្រាប់ជីវិតគ្រួសារផង សម្រាប់អនាគតកូនចៅដ៏យូរអង្វែងផង។ ជាការពិតណាស់ ជីវភាពរស់នៅរបស់ប្រជាជនឃុំកំពង់ភ្លុកគឺមានភាពធូធារសម្បូរសប្បាយ និងប្រកបដោយសុភមង្គល។ ទឹកដីឃុំកំពង់ភ្លុកក៏កំពុងតែមានការរីកចម្រើន មានសាលារៀន ផ្ទះពេទ្យ វត្តអារាម ។ ទាំងនេះគឺអាស្រ័យដោយការប្តេជ្ញាចិត្តយ៉ាងមុតមាំបំផុតរបស់ប្រជាជនឃុំកំពង់ភ្លុកដែលបានតស៊ូយ៉ាងអង់អាចអស់រយៈពេល ៣៥ ឆ្នាំ កន្លងមកហើយ ក្រោយប្រទេសជាតិបានរំដោះពីរបបប្រល័យពូជសាសន៍ប៉ុលពត។ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ទឹកដីឃុំកំពង់ភ្លុកដែលជាទឹកដីដែននេសាទដ៏ស្រស់ត្រកាល និងប្រជាជនឃុំកំពង់ភ្លុកដែលជាប្រជានេសាទដ៏ឧស្សាហ៍ព្យាយាម នឹងពិតជាមានអនាគតកាន់តែភ្លឺស្វាងជាងនេះ និងសម្បូររុងរឿងជាងនេះជាមិនខាន។/

## បានរស់

( បទពាក្យ ៧)

បានរស់ ព្រោះបក្សប្រជាជន បានរស់ ព្រោះគុណលោករំដោះ
បានរស់ ផុតទុក្ខគុកឃ្នាងខ្មោះ បានរស់ រីកស្រស់អស់គ្រោះភ័យ ។
បានរស់ បានសើចបានសប្បាយ បានរស់ គ្រប់កាយទាំងប្រុសស្រី
បានរស់ មានសិទ្ធិមានសេរី បានរស់ ជាថ្មីផុតមរណា ។
បានរស់ ដោយសារសម្តេចយើង បានរស់ រំលើងបនប្ញស្សា
បានរស់ ព្រោះលោកប្តូរសង្ខារ បានរស់ ដោយសារបក្សឈ្លាសវៃ ។
បានរស់ ចាកចេញពីផេះផង់ បានរស់ បានសង់លំនៅថ្មី
បានរស់ បានរៀនមានរស្មី បានរស់ ព្រោះអ្វីសូមពិចារ ?[១] ។
បានរស់ បានឆ្ពោះអភិវឌ្ឍន៍ បានរស់ បានវត្តថ្មល់សាលា
បានរស់ បានស្ពានសាងហេដ្ឋា[២] បានរស់ បានស្តារសង្គមជាតិ ។
បានរស់ តទៅត្រូវកុំភ្លេច បានរស់ ជានិច្ចឥតបីឃ្លាត
បានរស់ គ្រប់ប្រាណសន្តានញាតិ បានរស់ តទៀតកុំឃ្លាតគុណ ។
បានរស់ បោះឆ្នោតជូនបក្សយើង បានរស់ រុងរឿងថ្កើងពេកពន់
បានរស់ ព្រោះបក្សប្រជាជន បានរស់ ដោយគុណមហិមា ។
បានរស់ សុខសាន្តបានរីករាយ បានរស់ ទៅនាយពិតធូរធារ
បានរស់ ថ្កុំថ្កើងយើងរួមគ្នា បានរស់ រមនាក្រោមម្លប់បក្ស ។

-----------------------------

(១) - ពិចារណា

(២) - ហេដ្ឋារចនាសម្ព័ន្ធ

*ដោយ សុខ សុធន*




### បានទាំងអស់

ព្រឹកមួយ ពេលបានជួបគ្នា នាង សម សួរនាង សយ ដែលរៀបការមុនបាន ៣ឆ្នាំហើយ :

- មើល៏ សយ ឯងរៀបការច្រើនឆ្នាំហើយ តើបទពិសោធន៏គ្រប់គ្រងគ្រួសារ របស់ឯងយ៉ាងម៉េចខ្លះ?

- គឺម្នាក់គ្រប់គ្រងមួយផ្នែក ឯម្នាក់ទៀតគ្រប់គ្រងទាំងអស់ណា សម ។

- អេហ៏...គ្នាស្តាប់មិនយល់ទេ សយ អើយ ។

-នែ៎...គឺអ៊ីចេះណា៎សម ! គ្នាប្រាប់ប្តីគ្នាថាលុយកាក់និងទ្រព្យសម្បត្តិក្នុងផ្ទះគឺអូនជាអ្នកគ្រប់គ្រង ចំណែកបងគ្រប់គ្រងអូន ដូច្នេះគឺបងបានទាំងមនុស្ស បានទាំងសម្ភារៈ

- អូហ៏...អ៊ីចឹង ? ។

### ចុះបើវាឈប់ធ្វើខុស

ល្ងាចមួយនាយ រ៉ឹង ខឹងពេក ស្ទុះទាញរំពាត់ប្រុងវាយកុមារ រ៉ូច ជាកូន ។ ឃើញដូច្នោះ នាង វ៉ន ជាម្តាយ ស្រែកឃាត់ :

- នែ ពុកវា កូន រ៉ូច ទើបតែខុសម្តងទេ ណែនាំទៅបានហើយចាំ-បាច់អីវាយដំកូនឱ្យឈឺខ្លួន ចាំកូនធ្វើខុសលើកទីពីរ សឹមពុកវាវាយចុះ ខ្ញុំមិនហាមឃាត់ទេ ។

នាយ រ៉ឹង រឹតតែខឹងច្រឡោតស្រែកឡើងៈ

- ចុះបើវាឈប់ធ្វើខុសទៀត តើគិតយ៉ាងម៉េច? ។

### គឺ...ខ្ញុំ

កុមារ ទុយ សួរម្តាយដែលជាអ្នកគ្រូកំពុងបង្រៀនក្រៅម៉ោងក្នុងបន្ទប់មួយនៅផ្ទះរបស់ខ្លួន :

- ម៉ាក់អ្នា៎! អម្បាញ់មិញខ្ញុំបានអនុវត្តតាមសម្តីម៉ាក់ដែលបង្រៀនថា ត្រូវចេះជួយសង្គ្រោះអ្នកជួបការលំបាក តើម៉ាក់សប្បាយចិត្តទេ?

- ល្អណាស់កូន ! តើកូនធ្វើយ៉ាងម៉េចខ្លះ?

- បាទ ខ្ញុំឃើញក្មេងទូសល់នំពងទាមួយ ខ្ញុំក៏យកឱ្យក្មេងម្នាក់កំពុងស្រេកឃ្លាន ។

- អើ កូនប្រុសម៉ាក់ឆ្លាតមែន! ទើបតែបង្រៀនម្តងអនុវត្តបានភ្លាម ។ ចុះតើក្មេងនោះជានរណាកូន?

- បាទ ក្មេងនោះ គឺរូបខ្ញុំនេះឯង ។

### មានត្រចៀកទេ?

ព្រឹកមួយ នាយ ច្រូច បានទៅរកស្រស់ស្រូបអាហារពេលព្រឹកនៅក្នុងហាងមួយ ។ គាប់ជួនពេលនោះមានភ្ញៀវ ចូលយ៉ាងច្រើនខុសធម្មតា អ្នករត់តុឆ្លេឆ្លាម្តងទៅជើង ម្តងទៅត្បូង ។ នាយ ច្រូច ហៅ៤ដងនៅតែអ្នករត់តុមិនឮ ។

លុះហៅលើកទី ៥ ទើបអ្នករត់តុដើរមកសួរ :

- សូមទោស លោកត្រូវការពិសាអី?

ដោយហេតុមួម៉ៅ ដែលហៅច្រើនដងពេក ច្រូច បន្លឺងសំឡេង :

- ខ្ញុំហៅដល់ទៅ ៥ដងទើបមក ប្អូនឯងមានត្រចៀកឬអត់?

- បាទ មាន! លោកត្រូវការក្លែមស្លឹកត្រចៀកគោ ឬស្លឹកត្រចៀកជ្រូក? ។

### បានតើ !

ព្រឹកថ្ងៃអាទិត្យមួយ នាយ កង បានទៅផ្ទះនាយ កយ និយាយស្នើ :

- មើល៏សម្លាញ់ឱ្យខ្ញុំសុំខ្ចីសៀវភៅមេរៀនអានបន្តិចបានទេ ?

- បានតើ! ប៉ុន្តែ កង ឯងត្រូវនៅអង្គុយអានទីនេះ អត់ឱ្យឯងយកទៅផ្ទះឯងទេ ។

ព្រឹកថ្ងៃអាទិត្យបន្ទាប់ នាយ កយ បានទៅផ្ទះនាយ កង ម្តង :

- មើល៏សម្លាញ់ឱ្យខ្ញុំសុំខ្ចីចបកាប់យកទៅជម្រះស្មៅបន្តិចបានទេ ?

- បានតើ! ប៉ុន្តែឯងត្រូវជម្រះស្មៅនៅផ្ទះខ្ញុំ អត់ឱ្យយកទៅជម្រះស្មៅនៅផ្ទះឯងទេ ។

បោះពុម្ពដោយរោងពុម្ព អរិយធម៌ ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខ័ណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៥០

| | | | | | |
|---|---|---|---|---|---|
| ១- | ឯ.ឧ | កែ | គឹមយ៉ាន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ២- | ឯ.ឧ | ចម | ប្រសិទ្ធ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម និងលោកជំទាវ | ២០០ ដុល្លារ |
| ៣- | ឯ.ឧ | មិន | ឃិន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ធួន** | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | អ៊ុក | រ៉ាប៊ុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | ចន្ទ | សារុន | ទេសរដ្ឋមន្ត្រី | ៤០០.០០០៛ |
| ៦- | ឯ.ឧ | ត្រាំ | អ៊ីវតឹក | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | ថោង | ខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | ឆិន | ឃន | សមាជិករដ្ឋសភាមណ្ឌលបាត់ដំបង | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | ហ៊ុន | ណេង | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | ជៀង | អំ | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | ស្បោង | សារ៉ាត | ប្រធានគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | ខូយ | សុខា | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តពោធិសាត់ | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | អូស្មាន | ហាស្សាន់ | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | សរ | ចាំរ៉ុង | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | ផា | សុជាតិវង្ស | អនុប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | ម៉ម | ប៊ុននាង | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | ប្រាក់ | ចំរើន | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៨- | ឯ.ឧ | គង់ | វិបុល | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ១៩- | ឯ.ឧ | យូ | តិរម្យ | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់ | ១០០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | | ១០០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | | ១០០ ដុល្លារ |
| ២២- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | | ៥០ ដុល្លារ |
| ២៣- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | | ៥០ ដុល្លារ |
| ២៤- | ឯ.ឧ | លឹម | គានហោ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ២០០.០០០ ៛ |
| ២៥- | ឯ.ឧ | ឃឹម | សារិទ្ធ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៥០ដុល្លារ |
| ២៦- | ឯ.ឧ | ម៉ម | ប៊ុនហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៧- | ឯ.ឧ | ថា | យ៉ាវ | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ២៨- | ឯ.ឧ | យូ | ស៊ុនឡុង | រដ្ឋមន្ត្រីប្រតិភូអមសម្តេចនាយករដ្ឋមន្ត្រី | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | ជូ | យិនស៊ីម | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | អ៊ុក | ប្រាថ្នា | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ២០០.០០០ ៛ |
| ៣១- | ឯ.ឧ | ប៉ាវ | ហមផាន | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តរតនគិរី | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | សូ | ដុងហួរ | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ៣៣- | ឯ.ឧ | ចាយ | បូរិន្ទ | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣៤- | ឯ.ឧ | នរៈ | រតនៈវឌ្ឍនោ | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣៥- | ឯ.ឧ | ឃួន | រ៉ានីន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣៦- | ឯ.ឧ | ប៊ុន | លឹមហេង | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៣៧- | ឯ.ឧ | សេង | ឆៀង | ជំនួយការផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ២០០.០០០៛ |
| ៣៨- | ឧកញ៉ា | ម៉ក់ | គឹមហុង | ប្រធានអគ្គនាយកចំការកៅស៊ូជប់ | ២០០.០០០៛ |
| ៣៩- | ឯ.ឧ | គឹម | ណាំង | | ១០០.០០០៛ |
| ៤០- | ឯ.ឧ | ម៉ៅ | ប៊ុនណារិន | សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា | ១០០.០០០៛ |
| ៤១- | ឯ.ឧ | ម៉ែន | ស៊ីផាន់ | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៤២- | ឯ.ឧ | សុន | គន្ធរ | រដ្ឋមន្ត្រីប្រតិភូអមសម្តេចនាយករដ្ឋមន្ត្រី | ១០០.០០០៛ |
| ៤៣- | លោកជំទាវ | ស៊ីង | ស៊ីយុត | | ១០០.០០០៛ |
| ៤៤- | ឯ.ឧ | គឹម | ធា | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | គាំម | កុសល | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | ប៊ិច | សុវណ្ណ | | ១០០.០០០៛ |
| ៤៧- | ឯ.ឧបណ្ឌិត | មាស | ប៉ូ | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៤៨- | លោកជំទាវ | និត្យ | ច័ន្ទតារីន | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៩- | ឯ.ឧ | អ៊ុំ | វណ្ណា | | ១០០.០០០៛ |
| ៥០- | ឯ.ឧ | ឆា | ច័ន្ទលីដា | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៥១- | ឯ.ឧ | យិន | សួង | ទីប្រឹក្សាឯកឧត្តម **ខួន ញឿល** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៥២- | ឯ.ឧ | ម៉ែន | វិបុល | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០.០០០៛ |
| ៥៣- | ឯ.ឧ | អោម | ចន | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៥៤- | ឯ.ឧ | ជួន | ថេរ៉ាវ៉ាត | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន | ១០០.០០០៛ |
| ៥៥- | ឯ.ឧ | ម៉ៅ | ឡាំង | ទីប្រឹក្សាឯកឧត្តម **ខួន ញឿល** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៥៦- | ឯ.ឧ | ទន់ | ចន | ទីប្រឹក្សាឯ.ឧរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០.០០០៛ |
| ៥៧- | លោក | ឆាយ | ឬទ្ធិសែន | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងសុរិយោដីរាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥៨- | លោក | សាំ | ពិសិដ្ឋ | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥៩- | ឯ,ឧ | អ៊ុន | ឆាលី | អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង | ១០០.០០០៛ |
| ៦០- | លោក | សុខ | វិសាលសម្បត្តិ | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំព្នៅ១ ស្រុកស៊ីធរកណ្តាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល | ១០០.០០០៛ |
| ៦១- | ឯ,ឧ | ប៉ាន | ប៊ុនធឿន | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៦២- | លោកជំទាវ | ស៊ុន | សារឿន | សមាជិករដ្ឋសភាមណ្ឌលក្រចេះ | ៥០.០០០៛ |
| ៦៣- | ឯ.ឧ | សៀង | សុខយុនឌី | អគ្គនាយកនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៥០

| | | | | | |
|---|---|---|---|---|---|
| ៦៤- | ឯ.ឧ | សាយ | ប្ញុរិន | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ៥០.០០០៛ |
| ៦៥- | ឯ.ឧ | សេង | គឹមសាន | ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** | ៥០.០០០៛ |
| ៦៦- | ឯ.ឧ | ពត | ចាន់នី | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |
| ៦៧- | ឯ.ឧ | សុខ | ឌី | ទីប្រឹក្សារាជរដ្ឋាភិបាល | ៥០.០០០៛ |
| ៦៨- | ឯ.ឧ | ហេង | វណ្ណា | សមាជិកក្រុមការងារគណបក្សចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៩- | លោកជំទាវ | ស៊ឿ | ច័ន្ទថា | | ៥០.០០០៛ |
| ៧០- | លោក | ហួត | ពៅ | ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា | ៥០.០០០៛ |
| ៧១- | កញ្ញា | ផាង | និតហ្វៀរ៍ | មន្ត្រីក្រសួងទេសចរណ៍ | ៥០.០០០៛ |
| ៧២- | លោក | ង៉ោ | ម៉េងជួន | អភិបាលក្រុងប៉ោយប៉ែត | ៥០.០០០៛ |
| ៧៣- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៧៤- | លោក | កែវ | សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ | ៥០.០០០៛ |
| ៧៥- | លោក | ស្លួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៧៦- | លោក | គឹម | ប៊ុណ្ណា | ប្រធានសាខាបក្សមន្ទីរសាធារណៈការ និងដឹកជញ្ជូន ខេត្តសៀមរាប | ៥០.០០០៛ |
| ៧៧- | លោក | គាត | ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្តាល ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៧៨- | ឯ.ឧ | អ៊ឹង | វិបុល | អង្គភាព (Q101) | ៥០.០០០៛ |
| ៧៩- | ឯ.ឧ | វេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០៛ |
| ៨០- | លោក | លី | សាវី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៨១- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៨២- | គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | | ៤០.០០០៛ |
| ៨៣- | ឯ.ឧ | ស៊ិន | វុទ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៨៤- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៨៥- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ | ៣០.០០០៛ |
| ៨៦- | លោក | ចាន់ | សុំណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៨៧- | ឯ.ឧ | ឯម | ប៊ុនធឿន | សមាជិកគណៈកម្មាធិការគណបក្ស ក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៨៨- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៨៩- | លោក | ឆេព | វិសិដ្ឋ | អនុប្រធានសាខាពន្ធដារ ខេត្តព្រះសីហនុ | ២៥.០០០៛ |
| ៩០- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៩១- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៩២- | លោក | លឹម | វីរក្សេ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៩៣- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៩៤- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៩៥- | ឯ.ឧ | ចួង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩៦- | កញ្ញា | កែវ | សុជាតា | មន្ត្រីជំនួយការគណៈកម្មាធិការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៩៧- | ឯ.ឧ | ទេស | ច័ន្ទគិរី | សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប | ២០.០០០៛ |
| ៩៨- | លោក | ទូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩៩- | លោក | ហួង | ជ្រិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | ២០.០០០៛ |
| ១០០- | ឯ.ឧ | វើក | សានតួ | ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** | ២០.០០០៛ |
| ១០១- | លោក | គួច | ចាន់ធីត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ១០២- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ | ១៥.០០០៛ |
| ១០៣- | លោក | អ៊ិច | សាវ៉ន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ | ១៥.០០០៛ |
| ១០៤- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ១០៥- | លោក | ម៉ី | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ១០.០០០៛ |
| ១០៦- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៧- | លោក | ម៉ម | ប្រុស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៨- | លោក | សៅ | សម្ផស្ស | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៩- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១០- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១១- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១២- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៣- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៤- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៥- | លោក | ហួត | ធាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៦- | លោក | ទឹម | វុដ្ឋារី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៧- | លោក | ណុប | រៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៨- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៩- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២០- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២១- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២២- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២៣- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៤- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៥- | លោក | មុំ | វុឌ្ឍា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៦- | លោក | ឡាច | តីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៧ - | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |




**និពន្ធនាយក :**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខៀវ ណារី

២. លោក អ៊ឹម សុន្ទរៈ

៣. លោក វង្ស សារ៉ុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ

២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរៈមុនី

**វិចិត្រករ**

១. លោក ធា សារ៉ុធ

អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

**Address :**

**No 203 Preah**

**Norodom Bld.**

**Phnom Penh Cambodia**

**Tel : 023 219 065**




កម្ពុជាប្រារព្ធទិវាបុណ្យឯករាជ្យជាតិខួប លើកទី ៦០

៣



សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ទទួលគ្រឿងឥស្សរិយយសថ្នាក់ខ្ពស់បំផុតពីព្រះចៅអធិរាជជប៉ុន

៦



សម្តេចចក្រី **ហេង សំរិន** ជួបសវនាការជាមួយប្រធានរដ្ឋសភា......

៧



កម្ពុជា-ជប៉ុន ធ្វើការរួមគ្នាដើម្បីឈានជាបណ្តើរៗទៅជាដៃគូ........

៨



គ្រួសាររងគ្រោះទឹក ជំនន់ ៥៣.៧០១ គ្រួសារទទួលអំណោយពីកាកបាទក្រហមកម្ពុជា

១០



ឯកឧត្តម **សាយ ឈុំ** ណែនាំការងារមួយចំនួនក្នុងពិធីផ្ទេរតំណែងប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ

១២



តុលាការយុត្តិធម៌អន្តរជាតិ បកស្រាយលើសាលដីកាឆ្នាំ ១៩៦២ ពាក់ព័ន្ធនឹងរឿងក្តីប្រាសាទព្រះវិហារ

១៤

## ក្របមុខ

ពិធីបដិសណ្ឋារកិច្ចជូន

ឯកឧត្តម **ស៊ិនហ្សូ អាបេ**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រជប៉ុន

នៅវិមានសន្តិភាព

# មាតិកា

# Contents


វិចារណកថា : ស្មារតី ២ ធ្នូ និងទស្សនៈរបស់យុវវ័យចំពោះប្រវត្តិសាស្ត្រ ........................................ ១

*Editorial : 2-December Spirit and View of Youth on History*..................................................

⇨ សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៦

⇨ លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច....................................................................................១៨

⇨ ថវិកាជាតិ ឆ្នាំ ២០១៤ ជាឧបករណ៍គោលនយោបាយសំខាន់បំផុត ដែលឆ្លើយ .......................... ២០

⇨ សេវាដឹកជញ្ជូនតាមកំពង់ផែកាន់តែមានភាពមមាញឹក បើប្រៀបធៀបនឹងឆ្នាំមុន ..................... ២២

⇨ វប្បធម៌ :ឥទ្ធិពលរបស់សត្វមកលើជីវភាពមនុស្សខ្មែរ.............................................................. ២៤

⇨ ចំណេះដឹងទូទៅ : ទឹកជំនន់នៅអឺរ៉ុបគឺជាគ្រោះមហន្តរាយកំពូលប្រចាំឆ្នាំ ................................ ២៥

⇨ វិទ្យាសាស្ត្រសុខភាព : មើម **រមៀត** ជួយការពារជំងឺមហារីក .................................................. ២៦

⇨ ទឹកដីមាតុភូមិ : ឃុំកំពង់ភ្លុក ទឹកដីដែននេសាទ ដ៏ស្រស់ត្រកាលដែលកំពុងតែពង្រីកខ្លួន............. ២៨

⇨ កំណាព្យ : បានរស់................................................. សំណើច .................................... ៣១

ទស្សនាវដ្ដី

# ប្រជាជន

THE PRACHEACHUN MAGAZINE



ឆ្នាំទី១៣ លេខ ១៥០ ខែវិច្ឆិកា ឆ្នាំ ២០១៣














**រមណីយដ្ឋានទេសចរណ៍ធម្មជាតិ នៃឆ្នេរសមុទ្រកែប**
**កំពុងត្រៀមទទួលភ្ញៀវទេសចរណ៍ចូលរួមក្នុងពិធីបុណ្យសមុទ្រ**

ចែកជូនដោយឥតគិតថ្លៃ